**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

# យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧

**រៀបចំដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

**ខែកុម្ភៈ ឆ្នាំ២០២២**

# អារម្ភកថា

ក្រោមកត្តាសុខសន្តិភាព បូរណភាពទឹកដី សាមគ្គីភាព និងស្ថិរភាពនយោបាយ រាជរដ្ឋាភិបាលកម្ពុជាបានដឹកនាំប្រទេសនិងអនុវត្តគោលនយោបាយជាតិគន្លឹះៗ រួមមានជាអាទិ៍÷ **គោលនយោបាយ«ឈ្នះ-ឈ្នះ» យុទ្ធសាស្ត្រត្រីកោណ យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយជាតិតាមវិស័យ និងកម្មវិធីកែទម្រង់ផ្សេងៗ** ដោយសម្រេចបាននូវការអភិវឌ្ឍជាបន្តបន្ទាប់ជូនជាតិមាតុភូមិនិងប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់ក្នុងរយៈពេលជិតពាទសវត្សរ៍កន្លងមកនេះ។ មូលដ្ឋានគ្រឹះទាំងនេះជាបុរេលក្ខខណ្ឌដែលមិនអាចខ្វះបាន ដែលអនុញ្ញាតឱ្យកម្ពុជាប្រែមុខមាត់លើឆាកអន្តរជាតិនិងសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ៧,៧% ដែលបានរួមចំណែកកាត់បន្ថយអត្រាភាពក្រីក្រ បង្កើតការងារជូនប្រជាពលរដ្ឋពេញផ្ទៃប្រទេស និងជំរុញការអភិវឌ្ឍវិស័យឯកជនផងដែរ។ ជាក់ស្តែង សមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងការអភិវឌ្ឍនិងសមិទ្ធផលជាតិទាំងនេះបានដើរតួជាកាតាលីករ ក្នុងការផ្តល់លទ្ធភាពឱ្យកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាបនិងត្រូវបានធនាគារពិភពលោកទទួលស្គាល់និងចាត់ចូលក្នុងចំណោមប្រទេស«**ឯកឧត្តមកំណើន**» ទាំងប្រាំបីនៅក្នុងពិភពលោកក្នុងឆ្នាំ២០១៥ផងដែរ។

ជាការពិត វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ជាវិស័យអាទិភាពមួយ និងបានចូលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ វិស័យនេះបានវិវត្តខ្លួនជាបន្តបន្ទាប់ក្លាយជាចន្ទល់កំណើនសេដ្ឋកិច្ច ផ្អែកលើកត្តាសុខសន្តិភាពនិងស្ថិរភាពនយោបាយ ប្រាក់ឈ្នួលនិងថ្លៃផលិតកម្មប្រកួតប្រជែង ប្រព័ន្ធអនុគ្រោះផ្ទែកពាណិជ្ជកម្ម និងបរិយាកាសវិនិយោគអំណោយផល ដែលជាឧត្តមភាពប្រកួតប្រជែងរបស់វិស័យនេះ។ ជារួម វិស័យនេះមានសារៈសំខាន់ណាស់សម្រាប់ការនាំចេញរបស់កម្ពុជា និងការទ្រទ្រង់ជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជា យ៉ាងហោចណាស់ពី២,៥ទៅ៣លាននាក់ ដែលអាស្រ័យផលពីវិស័យនេះ។ ជាមួយហេតុផលនេះ ខ្ញុំបានយកចិត្តទុកដាក់ផ្ទាល់ជាពិសេសលើវិស័យនេះ ក្នុងន័យលើកកម្ពស់បរិយាកាសការងារជីវភាពរស់នៅ និងការអភិវឌ្ឍវិស័យនេះទាំងមូល។ ចាប់តាំងពីខែសីហា ឆ្នាំ២០១៧ ខ្ញុំបានចុះជួបសំណេះសំណាលដើម្បីស្វែងយល់ពីសុខទុក្ខនិងជីវភាពរស់នៅរបស់ក្មួយៗកម្មករ និយោជិត រោងចក្រ សហគ្រាសកាត់ដេរ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធចំនួន៧៧លើក ដែលមានការទទួលស្វាគមន៍និងការចូលរួមសរុបប្រមាណមួយលាននាក់។ តាមរយៈវេទិកាទាំងនោះ ខ្ញុំពិតជាមានសេចក្តីរីករាយនិងមោទនភាព ដែលបានចូលរួមដោះស្រាយសំណើ និងបញ្ហាប្រឈមរបស់ក្មួយៗកម្មករ និយោជិត ដោយដាក់ចេញជាបន្តបន្ទាប់នូវវិធានការគោលនយោបាយយ៉ាងប្រទាក់ក្រឡា និងលើកកម្ពស់សុខុមាលភាព ជីវភាពរស់នៅ និងការអភិវឌ្ឍវិស័យនេះ។

ជាមួយគ្នានេះ ខ្ញុំក៏សង្កេតឃើញថា បើទោះជាវឌ្ឍនភាពនៃវិស័យនេះជាសក្ខីភាពនិងជាទីមោទនៈនៃដំណើរការអភិវឌ្ឍន៍ រចនាសម្ព័ន្ធនៃវិស័យនេះក្នុងរយៈពេលជិត៣ទសវត្សរ៍កន្លងមក ពុំទាន់មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅឡើយទេ ដោយនៅតែជាមជ្ឈមណ្ឌលផលិតកម្មមានតម្លៃបន្ថែមទាប។ កម្រិតសមាហរណកម្មនៃឧស្សាហកម្មគាំទ្រនៅក្នុងដំណើរការផ្សេងទៀតនៃខ្សែច្រវាក់ផ្គត់ផ្គង់ និងខ្សែច្រវាក់តម្លៃនៅតិចតួច ហើយកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនៅមិនទាន់មានលក្ខណៈប្រមូលផ្តុំបានគ្រប់គ្រាន់ ដែលទាមទារឱ្យមានការគិតគូរពីការកំណត់នូវទិសដៅអភិវឌ្ឍរួមនៃវិស័យនេះ។

ទន្ទឹមនេះ ត្បិតសេដ្ឋកិច្ចកម្ពុជាបានកំពុងស្ថិតក្នុងស្ថានភាពនៃការខិតខំប្រឹងប្រែងគ្រប់គ្រងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩មកលើសង្គម សេដ្ឋកិច្ចនិងចាកចេញពីវិបត្តិជំងឺកូវីដ-១៩ ការជួបប្រទះនឹងបណ្តាកត្តាខាងក្រៅរួមទាំងករណីសម្រេចព្យួរប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ(EBA) និងបញ្ហាប្រឈមមួយ

ចំនួន ដែលមានចរិតជារចនាសម្ព័ន្ធក្នុងវិស័យនេះក្តី ការសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការរៀបចំនិងដាក់ឱ្យអនុវត្ត «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧**» ជាកិច្ចការអាទិភាព ដែលនឹងមិនត្រឹមតែជាផែនទីបង្ហាញផ្លូវសម្រាប់ភាគីពាក់ព័ន្ធនិងឆ្លើយតបទៅនឹងការទន្ទឹងរង់ចាំរបស់តួអង្គពាក់ព័ន្ធ ជាពិសេស វិស័យឯកជននិងដៃគូអភិវឌ្ឍប៉ុណ្ណោះទេ ប៉ុន្តែការគិតគូរដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រនេះ គឺស្ថិតក្រោមឆ័ត្រនៃការអនុវត្តនូវវិធានការគន្លឹះមួយ ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាលនៅក្នុង«**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ក្នុងចតុកោណទី២ស្តីពីការធ្វើពិពិធកម្មសេដ្ឋកិច្ច**» ផងដែរ។

ជាក់ស្តែង «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧**» នឹងកំណត់នូវចក្ខុវិស័យ គោលបំណង គោលដៅ និងវិធានការជាយុទ្ធសាស្ត្រ សំដៅបន្តពង្រឹងនិងគ្រប់គ្រងការអភិវឌ្ឍវិស័យនេះឱ្យស្របតាមបរិការណ៍កម្ពុជា និងឆ្លើយតបបានកាន់តែប្រសើរទៅនឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៃនិម្នាបនកម្មតំបន់និងពិភពលោក។ ក្នុងដំណើរការនៃការរៀបចំយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលបានពិនិត្យនិងវិភាគលើឯកសារពាក់ព័ន្ធ ដកស្រង់បទពិសោធន៍ជាតិនិងអន្តរជាតិ ទស្សនកិច្ចនៅតាមរោងចក្រ និងពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធក្នុងវិស័យសាធារណៈ ដៃគូអភិវឌ្ឍ កម្មករ និយោជិត សហជីព សមាគមជាតិនិងអន្តរជាតិ ព្រមទាំងវិស័យឯកជន រួមមាន អ្នកវិនិយោគ អ្នកបញ្ជាទិញ ម្ចាស់ម៉ាកផលិតផល និងអ្នកគ្រប់គ្រងរោងចក្រជាដើម។

ជាលទ្ធផល រាជរដ្ឋាភិបាលបានកំណត់ចក្ខុវិស័យនៃយុទ្ធសាស្ត្រនេះ ដែលត្រូវអភិវឌ្ឍវិស័យនេះឱ្យទៅជាឧស្សាហកម្មដែលមានចីរភាពបរិស្ថាន មានភាពធន់ មានតម្លៃបន្ថែមខ្ពស់ ផ្តោតលើផលិតផលថ្លៃខ្ពស់និងមានលក្ខណៈពិសេស មានភាពប្រកួតប្រជែងខ្ពស់ និងជាមូលដ្ឋានគាំទ្រពិពិធកម្មសេដ្ឋកិច្ច។ ត្បិតចក្ខុវិស័យត្រូវបានកំណត់ត្រឹមឆ្នាំ២០២៧ក៏ពិតមែន យុទ្ធសាស្ត្រនេះចាត់ទុកជាឯកសាររស់ ដែលអាចនឹងត្រូវកែសម្រួលជាយថាហេតុដោយរាជរដ្ឋាភិបាល ដើម្បីធានាសង្គតិភាពទៅតាមការវិវត្តជាក់ស្តែង។

ដើម្បីសម្រេចបាននូវចក្ខុវិស័យក្នុងក្របខ័ណ្ឌអនុវត្តយុទ្ធសាស្ត្រនេះ ក៏ដូចជា បន្ថែមលើវិធានការអន្តរាគមន៍សំដៅគ្រប់គ្រងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ និងវិធានការមុតស្រួចជាបន្តបន្ទាប់ ដើម្បីពង្រឹងសមត្ថភាពប្រកួត-ប្រជែង រាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្តវិធានការជាយុទ្ធសាស្ត្រចំនួន ៥ គឺ ១)-បន្តពង្រឹងធនធានមនុស្សដើម្បីបង្កើនផលិតភាពនិងបង្កើតគន្លងអាជីពសម្រាប់កម្មករ និយោជិត ២)-បន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងសុខុមាលភាពរបស់កម្មករ និយោជិត ៣)-លើកកម្ពស់ការវិនិយោគក្នុងស្រុកនិងបរទេសក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ និងផ្តោតលើផលិតផលថ្លៃខ្ពស់និងមានលក្ខណៈពិសេស ៤)-ទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រសម្រាប់បម្រើឱ្យវិស័យនេះ និង៥)-ជំរុញការធ្វើពិពិធកម្មទីផ្សារនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងកាបូប។

ការអនុវត្តយុទ្ធសាស្ត្រនេះនឹងចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមនៅក្នុងវិស័យនេះ ដែលមានចរិតជារចនាសម្ព័ន្ធ និងផ្តល់លទ្ធភាពឱ្យកម្ពុជាត្រៀមខ្លួនចាប់យកកាលានុវត្តភាព ដើម្បីជំរុញការអភិវឌ្ឍនៃវិស័យនេះ ក៏ដូចជាកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍ ប្រកបដោយចីរភាពនិងបរិយាប័ន្ន។ មិនត្រឹមតែប៉ុណ្ណោះ ការសម្រេចបាននូវចក្ខុវិស័យនៃយុទ្ធសាស្ត្រនេះនឹងចូលរួមចំណែកគាំទ្រ បំពេញបន្ថែម និងស្របជាមួយការអនុវត្តឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំខាន់ផ្សេងទៀត រួមមានជាអាទិ៍១-យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ២-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ៣-គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

ឆ្នាំ២០១៥-២០២៥ ៤-គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ ៥-គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ៦-យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០១៩-២០២៣ និង៧-ក្របខ័ណ្ឌយុទ្ធសាស្ត្រនិងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣។

ឆ្លៀតក្នុងឱកាសនេះ តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ និងការកោតសរសើរជូនចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(ក.ប.ស.)** ដែលបានដឹកនាំក្រុមការងារ ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទ រៀបចំយុទ្ធសាស្ត្រនេះឡើង ដោយបានធ្វើការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធ និងសកម្មជាមួយតួអង្គពាក់ព័ន្ធសំខាន់ៗ ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន។

ជាចុងក្រោយ ជាមួយនឹងការអនុម័តដាក់ឱ្យអនុវត្តជាផ្លូវការនូវយុទ្ធសាស្ត្រនេះ ខ្ញុំសូមណែនាំនិងប្រគល់ភារកិច្ចជូន **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ទទួលបន្ទុកដឹកនាំសម្របសម្រួលអន្តរស្ថាប័ន ជំរុញ តាមដាន និងត្រួតពិនិត្យលើការអនុវត្តរាល់វិធានការដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រនេះឱ្យបានជោគជ័យ និងមានប្រសិទ្ធភាព ព្រមទាំងរាយការណ៍ជូនរាជរដ្ឋាភិបាល។ ក្នុងន័យនេះ តាងនាមឱ្យរាជរដ្ឋាភិបាល និងរូបខ្ញុំផ្ទាល់ជឿជាក់ថា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញ ប្រកបដោយការប្តេជ្ញាចិត្ត ភាពសកម្ម អន្តរសកម្ម និងស្មារតីទទួលខុសត្រូវក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ និងដោយប្រកាន់ភ្ជាប់នូវអភិក្រម និងអនុសាសន៍ ដែលខ្ញុំបានដាក់ចេញកន្លងមក«**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និង វះកាត់**» និង «**កែលម្អខាងក្នុង និងបង្កើនមិត្តខាងក្រៅក្នុងស្មារតីពង្រឹងឯករាជ្យនិងអធិបតេយ្យភាពជាតិ**» សំដៅចូលរួមចំណែកក្នុងការបង្កើនសមត្ថភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចរបស់កម្ពុជា ការឆ្លើយតបទៅនឹងការរំពឹងទុកនិងតម្រូវការរបស់ប្រជាជន និងការកសាងមូលដ្ឋានគ្រឹះចាំបាច់ ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវបង្គោលចរឆ្នាំ២០៣០និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ខ្លឹមសារសង្ខេប

ព្រះរាជាណាចក្រកម្ពុជាបានកំពុងក្រេបជញ្ជក់នូវផ្លែផ្កានៃសុខសន្តិភាព បូរណភាពទឹកដី សាមគ្គីភាពនិងស្ថិរភាពនយោបាយ តាមរយៈការអនុវត្តគោលនយោបាយជាតិសំខាន់ៗ ដែលរួមមាន **គោលនយោបាយ «ឈ្នះ-ឈ្នះ» យុទ្ធសាស្ត្រត្រីកោណ យុទ្ធសាស្ត្រចតុកោណ** និង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ ឈរលើមូលដ្ឋានគ្រឹះនេះ ប្រទេសកម្ពុជាបានសម្រេចនូវការអភិវឌ្ឍឥតឈប់ឈរនិងកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ៧,៧%។ កំណើនសេដ្ឋកិច្ចដ៏រឹងមាំនិងឆាប់រហ័សនេះបានជួយកាត់បន្ថយអត្រាភាពក្រីក្រ បង្កើតការងារ និងជំរុញការអភិវឌ្ឍនៃវិស័យឯកជនផងដែរ។ ជាមួយនឹងសមិទ្ធផលគួរជាទីមោទនៈទាំងនេះ ប្រទេសកម្ពុជាបានប្រែខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាប និងត្រូវបានធនាគារពិភពលោកទទួលស្គាល់និងចាត់ចូលក្នុងចំណោមប្រទេស«**ឯកឧត្តមករកំណើន**» ទាំងប្រាំបីនៅក្នុងពិភពលោកក្នុងឆ្នាំ២០១៥។

ជាការពិត វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបបានចូលរួមចំណែកយ៉ាងសំខាន់ដល់ការសម្រេចបានសមិទ្ធផលខាងលើ។ ផ្អែកលើកត្តាសុខសន្តិភាពនិងស្ថិរភាពនយោបាយ ប្រាក់ឈ្នួលនិងថ្លៃផលិតកម្មប្រកួត-ប្រជែង ប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្មនិងបរិយាកាសវិនិយោគអំណោយផលដែលជាឧត្តមភាពប្រកួតប្រជែងរបស់ខ្លួន វិស័យនេះបានរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលក្លាយជាចន្ទល់កំណើនសេដ្ឋកិច្ច។ ជាក់ស្តែង ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៩០រហូតដល់ឆ្នាំ២០០៨ ការនាំចេញនៃវិស័យនេះរួមចំណែកប្រមាណជាង៩៥%នៃការនាំចេញសរុបរបស់កម្ពុជានិងនៅក្រោយវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៩មក ការនាំចេញនៃវិស័យនេះនៅតែរក្សាបានក្នុងកម្រិតខ្ពស់ ជាមធ្យមជាង៧០% ក្នុងបរិបទដែលកម្ពុជាបានធ្វើពិពិធកម្មការនាំចេញផលិតផលផ្សេងទៀតបានមួយកម្រិត ដូចជាកង់ គ្រឿងបន្លាស់រថយន្តនិងគ្រឿងបង្គុំអេឡិចត្រូនិកជាដើម។ ទន្ទឹមនេះ ការនាំចេញផលិតផលធ្វើដំណើរ(ឬជាប្រភេទផលិតផលកាបូប) ដូចជាវ៉ាលីស កាបូបស្ពាយ កាបូបយួរដៃនិងកាបូបលុយទៅកាន់ទីផ្សារសហរដ្ឋអាមេរិកមានកំណើនខ្ពស់គួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅ(Generalized System of Preference - GSP)ដែលកម្ពុជាទទួលបានកាលពីឆ្នាំ២០១៦ ក៏បានជួយទ្រទ្រង់ដល់កំណើននៃវិស័យនេះផងដែរ។

ជាមួយគ្នានេះ ក្នុងរយៈពេលជាង២០ឆ្នាំមកនេះ(១៩៩៧-២០២០) រោងចក្រ សហគ្រាសកាត់ដេរ ផលិតស្បែកជើង និងកាបូប ដែលបានចុះបញ្ជីនៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានកើនពី៦៤មកដល់ចំនួនជាង១ ២០០រាប់បញ្ចូលទាំងរោងចក្រផលិតសម្រាប់នាំចេញផ្ទាល់និងរោងចក្រ សហគ្រាសម៉ៅការបន្ត ដែលគាំទ្រផលិតកម្មដល់រោងចក្រផលិតសម្រាប់នាំចេញ ដូចជាការបោកគក់ ការដេរប៉ាក់ ការជ្រលក់ពណ៌ ការដេរឬការវេចខ្ចប់ជាដើម ខណៈដែលកម្មករ និយោជិតកើនឡើងពីចំនួនប្រមាណ៨ម៉ឺននាក់ដល់ចំនួនជាង៨០ម៉ឺននាក់(ជាង៨០%ជាស្ត្រី) ឬប្រមាណពី២,៥ទៅ៣លាននាក់ បើរាប់បញ្ចូលទាំងប្រជាពលរដ្ឋកម្ពុជា ដែលអាស្រ័យផលដោយប្រយោលពីវិស័យនេះ។

ថ្វីបើវិស័យនេះត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ជាសក្ខីភាពនៃដំណើរការអភិវឌ្ឍន៍ រចនាសម្ព័ន្ធនៃវិស័យនេះ អស់រយៈពេលជិតពាទសវត្សរ៍កន្លងមក មិនទាន់មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ដោយនៅតែជាមជ្ឈមណ្ឌលផលិតកម្មមានតម្លៃបន្ថែមទាប និងសមាហរណកម្មនៃឧស្សាហកម្មគាំទ្រនៅក្នុងដំណើរការផ្សេងទៀតនៃខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃនៅមានកម្រិត។ វិស័យនេះនៅតែជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន មានជាអាទិ៍÷

- កង្វះពលកម្មជំនាញក្នុងស្រុក ទាំងគុណភាពនិងបរិមាណ និងគន្លងអាជីពសម្រាប់កម្មករ និយោជិត
- កង្វះភាពប៉ាន់ប្រមាណបាននិងស្ថិរភាពដែលបណ្តាលមកពីបញ្ហាលក្ខខណ្ឌការងារនិងសុខុមាលភាពកម្មករ និយោជិតដែលកន្លងមកមានភាពល្អប្រសើរ ប៉ុន្តែនៅមានកម្រិតនៅឡើយ
- កង្វះផលិតកម្មតម្លៃបន្ថែមខ្ពស់និងចំនួនម្ចាស់រោងចក្រឬអ្នកវិនិយោគក្នុងស្រុកនៅមានកម្រិតទាប
- កង្វះឧស្សាហកម្មគាំទ្រនៅក្នុងវិស័យនិងបរិយាកាសធុរកិច្ចនៅមានកម្រិត
- ពិពិធកម្មទីផ្សារនៅមានកម្រិតនិងការពឹងផ្អែកខ្លាំងលើប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និង
- កង្វះកិច្ចសម្របសម្រួលអន្តរស្ថាប័ន ក្នុងចំណោមតួអង្គពាក់ព័ន្ធសំខាន់ៗជាដើម។

ទន្ទឹមនេះ ចាប់ពីចុងឆ្នាំ២០១៩ ឆ្នាំ២០២០ និងឆ្នាំ២០២១កន្លងទៅ វិបត្តិជំងឺកូវីដ-១៩ បានបង្កជាបញ្ហាប្រឈមបន្ថែមដល់វិស័យកាត់ដេរនៅកម្ពុជា។ ទាំងរោងចក្រនិងកម្មករ និយោជិតបានជួបការលំបាកធ្ងន់ធ្ងរ ដូចជាមានការផ្អាកដំណើរការផលិតកម្ម ការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតរាប់ម៉ឺននាក់ និងការបិទជាស្ថាពររបស់រោងចក្រមួយចំនួន ដោយសារការរីករាលដាលធ្ងន់ធ្ងរនៃវិបត្តិកូវីដ-១៩ នៅបណ្តាទីផ្សារនាំចេញធំៗរបស់កម្ពុជា រួមមានសហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប។ ការអូសបន្លាយនៃជំងឺកូវីដ-១៩ រហូតមកដល់បច្ចុប្បន្នបង្កជាភាពមិនច្បាស់លាស់នៅក្នុងវិស័យនេះ ជាពិសេសនៅក្នុងទីផ្សារធំៗរបស់កម្ពុជាដែលទាមទារឱ្យកម្ពុជាគិតគូរនិងដោះស្រាយបញ្ហាប្រឈមនៅក្នុងវិស័យនេះ និងត្រៀមខ្លួនចាប់យកកាលានុវត្តភាពដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យនេះឱ្យកាន់តែរឹងមាំនិងមានភាពធន់បន្ថែមទៀត។

បន្ថែមលើចំណុចខាងលើ វិស័យនេះក៏ស្ថិតក្រោមឥទ្ធិពលនៃការប្រែប្រួលនិងការវិវត្តថ្មីៗដែលបណ្តាលមកពីកត្តាខាងក្នុងនិងខាងក្រៅ មានជាអាទិ៍÷

- សក្តានុពលនៃការកែប្រែប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មពីដៃគូពាណិជ្ជកម្មសំខាន់ៗសម្រាប់កម្ពុជា តាមរយៈការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចកម្ពុជាចាកចេញពីឋានៈប្រទេសមានកម្រិតអភិវឌ្ឍន៍តិចតួច(LDCs) នាពេលខាងមុខឬហេតុផលផ្សេងទៀត តួយ៉ាងករណីសម្រេចព្យួរប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ(EBA)
- ការទទួលខុសត្រូវផ្អែកកិច្ចគាំពារបរិស្ថានឬចីរភាពបរិស្ថាន នៅក្នុងឧស្សាហកម្មកាត់ដេរកាន់តែមាននិន្នាការកើនឡើងជាលំដាប់ ជាពិសេសក្នុងចំណោមម្ចាស់ម៉ាកផលិតផលសម្លៀកបំពាក់និងអ្នកបញ្ជាទិញធំៗដែលជាក់ស្តែងមានការចាប់ផ្តើមអនុវត្តកម្មវិធីកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គិសនី ដោយលើកទឹកចិត្តឱ្យរោងចក្រឬអ្នកផលិតពាក់ព័ន្ធក្នុងវិស័យនេះប្រើប្រាស់ថាមពលកកើតឡើងវិញ
- ការផ្លាស់ប្តូរនៅក្នុងវិស័យនេះ តាមរយៈស្វ័យប្រវត្តិកម្មលើការរចនានិងដំណើរការផលិតកម្មចំពោះផលិតផលកាត់ដេរដែលមានលក្ខណៈសាមញ្ញមួយចំនួននៅក្នុងរយៈពេលមធ្យម/វែង និងល្បឿននៃការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មទី៤ កាន់តែមានសម្ពុះខ្លាំងឡើងក្នុងដំណើរការផលិតកម្ម និងខ្សែច្រវាក់ផ្គត់ផ្គង់
- ការប្រកួតប្រជែងកាន់តែកើនឡើងរវាងប្រទេសកម្ពុជា ជាមួយប្រទេសវៀតណាម មីយ៉ាន់ម៉ា បង់ក្លាដែស និងប្រទេសមួយចំនួននៃទ្វីបអាហ្វ្រិកដែលកំពុងទាក់ទាញការវិនិយោគ

- ការផ្លាស់ប្តូរបរិយាកាសពាណិជ្ជកម្ម ជាពិសេសលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី(FTA) រវាងប្រទេសដែលប្រកួតប្រជែងជាមួយកម្ពុជា ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងប្រទេសវៀតណាម និងសហភាពអឺរ៉ុប ជាដើម និង
- ល្បឿននៃនិន្នាការធំៗមួយចំនួនផ្សេងទៀតកាន់តែមានសន្ទុះខ្លាំងឡើងនៅក្នុងវិស័យនេះ មានជាអាទិ៍ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ និងការផ្លាស់ប្តូរដំណើរការពាណិជ្ជកម្ម/អាជីវកម្មនៅក្នុងវិស័យកាត់ដេរសកល រួមមានការផ្លាស់ប្តូរនៃលំនាំសកម្មភាពផលិតកម្ម ការបញ្ជាទិញពីបរិមាណច្រើនមកបរិមាណតិចនិងតាមតម្រូវការរបស់អ្នកបញ្ជាទិញ ល្បឿនបញ្ជូនទំនិញទៅកាន់ទីផ្សារនិងការលក់ទៅតាមតម្រូវការម៉ូដពេញនិយមរបស់អតិថិជនកាន់តែមានរយៈពេលខ្លី និងការលក់តាមពាណិជ្ជកម្មអេឡិចត្រូនិកកាន់តែមានសន្ទុះខ្លាំងឡើង។

ទោះជាស្ថិតក្នុងស្ថានភាពនេះក្តី កម្ពុជាក៏បានសម្លឹងឃើញនូវកាលានុវត្តភាពមួយចំនួនសម្រាប់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប រួមមាន÷

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងការចាត់ទុកឧស្សាហកម្មនេះនៅតែជាវិស័យអាទិភាព សម្រាប់ជំរុញការអភិវឌ្ឍរបស់កម្ពុជា
- ការរៀបចំនិងអនុវត្តយ៉ាងសកម្ម និងប្រទាក់ក្រឡានូវគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិព្រមទាំងតាមរយៈការដាក់ឱ្យអនុវត្តកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងនិងពិពិធកម្មសេដ្ឋកិច្ច
- ការបន្តពង្រឹងឱ្យកាន់តែប្រសើរឡើងនូវឧត្តមភាពប្រកួតប្រជែង ជាអាទិ៍កេរ្តិ៍ឈ្មោះជាគោលដៅផលិតកម្មប្រកបដោយអនុលោមភាពផ្នែកសង្គម ចីរភាពបរិស្ថាន និងក្រមសីលធម៌និងការរក្សាទំនាក់ទំនងពាណិជ្ជកម្មជាច្រើនឆ្នាំជាមួយអ្នកបញ្ជាទិញ និងម្ចាស់ម៉ាកផលិតផលជាដើម
- ការបន្តប្រឹងប្រែងក្នុងការចរចាចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការរក្សាឱ្យអស់លទ្ធភាពនូវប្រព័ន្ធអនុគ្រោះខាងពាណិជ្ជកម្មដែលកម្ពុជាកំពុងទទួលបាន
- ការកើនឡើងនៃថ្លៃផលិតកម្មនៅក្នុងប្រទេសចិនដែលអាចជំរុញឱ្យមានការផ្លាស់ប្តូរទីតាំងរោងចក្រ ទាំងប្រភេទកាត់ដេរ និងបម្រើឱ្យឧស្សាហកម្មគាំទ្រមកប្រទេសក្នុងតំបន់ រួមទាំងកម្ពុជា
- ការរំពឹងទុកនៃការបើកទីផ្សាររបស់ចិននិងកូរ៉េ សម្រាប់ផលិតផលកាត់ដេររបស់កម្ពុជាក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីរវាងកម្ពុជានិងចិន និងរវាងកម្ពុជានិងកូរ៉េ
- ការរំពឹងទុកនៃការបើកទូលាយនៃទីផ្សារតំបន់ ក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់(RCEP)
- ការបន្តគាំទ្រពីដៃគូអភិវឌ្ឍពាក់ព័ន្ធ ដើម្បីអភិវឌ្ឍវិស័យនេះបន្ថែមទៀត និង
- ការងើបឡើងវិញនៃកំណើនតម្រូវការផលិតផលកាត់ដេរសកល បន្ទាប់ពីផលប៉ះពាល់នៃបញ្ហាសកលមួយចំនួន រួមទាំងបញ្ហាជំងឺកូវីដ-១៩ ត្រូវបានថមថយ។

ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាបានពិនិត្យឃើញពីសារៈសំខាន់និងភាពចាំបាច់ ដែលត្រូវរៀបចំនិងដាក់ឱ្យអនុវត្តនូវ«**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧**» សំដៅកំណត់នូវចក្ខុវិស័យរួម គោលបំណង គោលដៅនិងវិធានការជាយុទ្ធសាស្ត្រ ដើម្បីបន្តពង្រឹងនិងគ្រប់គ្រង

ការអភិវឌ្ឍវិស័យនេះឱ្យស្របតាមបរិការណ៍កម្ពុជា ដែលស្ថិតក្នុងស្ថានភាពទ្វេទិស មានទាំងបញ្ហាប្រឈមនិងកាលានុវត្តភាពព្រមទាំងឆ្លើយតបទៅនឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៃនិម្មាបនកម្មតំបន់និងពិភពលោក។ ដើម្បីធានាសមត្ថភាពប្រកួតប្រជែងនិងលើកកម្ពស់វិស័យនេះឱ្យបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការអភិវឌ្ឍន៍ ការរៀបចំនិងអនុវត្តយុទ្ធសាស្ត្រនេះមិនមែនជាការងារដាច់ដោយឡែកនោះទេ ប៉ុន្តែត្រូវបានគិតគូរដោយមានសង្គតិភាពជាមួយគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំខាន់ៗ តាមរយៈការដាក់ចេញនូវវិធានការយុទ្ធសាស្ត្រដែលត្រូវបានបែងចែកជាដំណាក់កាលរយៈពេលខ្លីនិងមធ្យម ព្រមទាំងបានកំណត់នូវយន្តការអន្តរស្ថាប័ននិងស្ថាប័នទទួលខុសត្រូវ ក្នុងការអនុវត្តវិធានការដោយគោរពតាមក្របខ័ណ្ឌពេលវេលា។

ក្នុងន័យនេះ តាមរយៈការអនុវត្តយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលនឹងអភិវឌ្ឍវិស័យកាត់ដេរ ផលិតស្បែកជើងនិងកាបូបនៅកម្ពុជា ឱ្យទៅជាឧស្សាហកម្មដែលមានចីរភាពបរិស្ថាន មានភាពធន់ មានតម្លៃបន្ថែមខ្ពស់ ផ្តោតលើផលិតផលថ្លៃខ្ពស់និងមានលក្ខណៈពិសេស មានភាពប្រកួតប្រជែងខ្ពស់និងជាមូលដ្ឋានគាំទ្រពិពិធកម្មសេដ្ឋកិច្ចនៅមុនដំណាច់ឆ្នាំ២០២៧។ យុទ្ធសាស្ត្រនេះមានគោលបំណងកំណត់នូវទិសដៅអភិវឌ្ឍន៍រួម បង្កើនភាពឯករាជ្យនិងពង្រឹងភាពប៉ាន់ប្រមាណបាននិងស្ថិរភាពនៃវិស័យនេះ ដើម្បីបន្តលើកកម្ពស់ការអភិវឌ្ឍវិស័យនេះប្រកបដោយចីរភាពនិងបរិយាប័ន្ន។ ដើម្បីសម្រេចបាននូវគោលបំណងនិងចក្ខុវិស័យខាងលើ ព្រមទាំងបន្ថែមលើវិធានការមុតស្រួចរបស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា និងវិធានការអន្តរាគមន៍ដើម្បីគ្រប់គ្រងផលប៉ះពាល់ពីជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌអនុវត្តយុទ្ធសាស្ត្រនេះ មានគោលដៅរៀបចំនិងដាក់ឱ្យអនុវត្តវិធានការជាយុទ្ធសាស្ត្រ ដូចខាងក្រោម÷

១)-បន្តពង្រឹងធនធានមនុស្សដើម្បីបង្កើនផលិតភាពនិងបង្កើតគន្លងអាជីពសម្រាប់កម្មករ និយោជិត

២)-បន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនិងសុខុមាលភាពរបស់កម្មករ និយោជិត

៣)-លើកកម្ពស់ការវិនិយោគក្នុងស្រុកនិងបរទេសក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ និងផ្តោតលើផលិតផលថ្លៃខ្ពស់និងមានលក្ខណៈពិសេស

៤)-ទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រសម្រាប់បម្រើឱ្យវិស័យនេះ និង

៥)-ជំរុញការធ្វើពិពិធកម្មទីផ្សារនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងកាបូប។

ដើម្បីរៀបចំយន្តការស្ថាប័នសម្រាប់តាមដានឱ្យបានច្បាស់លាស់នូវការអនុវត្តវិធានការទាំងឡាយខាងលើនិងពង្រឹងកិច្ចសម្របសម្រួលអន្តរស្ថាប័ន រាជរដ្ឋាភិបាលបានពិនិត្យឃើញនូវភាពចាំបាច់ក្នុងការបង្កើត*ក្រុមការងារអន្តរស្ថាប័នទទួលបន្ទុកសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រ(ឬក្រុមការងារអន្តរស្ថាប័ន)* ដែលមានសមាសភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធនិងស្ថិតក្រោមការដឹកនាំនិងសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ*គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(គ.ស.ហ.)*។ បន្ថែមលើនេះ រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពបង្កើត*ក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប* ដែលមានសមាសភាព ជាអាទិ៍ពីតំណាងវិស័យឯកជន ដៃគូអភិវឌ្ឍ ជំនាញការឯករាជ្យ សមាគមនិងសហជីព ដើម្បីផ្តល់នូវប្រភពធាតុចូលមួយបន្ថែមសំដៅជួយគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនេះឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ។

ក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលក៏បានគិតគូរដល់ហានិភ័យ ដែលអាចប៉ះពាល់ដល់វិធានការដែលបានដាក់ចេញ។ ហានិភ័យទាំងនោះ រួមមានជាអាទិ៍គឺ ហានិភ័យខាងក្រៅ ដែលកើតចេញពីការប្រែប្រួលក្នុងតំបន់និងពិភពលោក ដូចជាការជះឥទ្ធិពលនៃការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាលើផលិតកម្មនិងកម្លាំងពលកម្ម ជាពិសេសបច្ចេកវិទ្យាស្វ័យប្រវត្តិកម្មនិងនវានុវត្តន៍ ក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មទី៤ ការបង្អាក់ដល់ខ្សែច្រវាក់ផលិតកម្មនិងខ្សែច្រវាក់ផ្គត់ផ្គង់(ដូចជាការបណ្ដាលមកពីវិបត្តិជំងឺកូវីដ-១៩) ហានិភ័យខាងក្នុងពាក់ព័ន្ធនឹងការគ្រប់គ្រងបញ្ហាម៉ាក្រូសេដ្ឋកិច្ច ដូចជាការកើនឡើងនៃប្រាក់ឈ្នួលអប្បបរមានិងអត្រាអតិផរណា ហានិភ័យដែលកើតចេញពីការប្រែប្រួលនៃនិម្មាបនកម្មនយោបាយនិងឥទ្ធិពលនៃបញ្ហានយោបាយលើឥរិយាបថរបស់អ្នកបញ្ជាទិញនិងទំនុកចិត្តក្នុងទីផ្សារ និងហានិភ័យពាក់ព័ន្ធនឹងកិច្ចសម្របសម្រួលអន្តរស្ថាប័ន។

ជាចុងក្រោយ រាជរដ្ឋាភិបាលជឿជាក់ថាការអនុវត្តយុទ្ធសាស្ត្រនេះនឹងចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមនៅក្នុងវិស័យនេះដែលមានចរិតជារចនាសម្ព័ន្ធនិងផ្តល់លទ្ធភាពឱ្យកម្ពុជាអាចចាប់យកកាលានុវត្តភាពដើម្បីជំរុញការអភិវឌ្ឍនៃវិស័យនេះ ក៏ដូចជាកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍ ប្រកបដោយចីរភាពនិងបរិយាប័ន្ន។ ការសម្រេចបាននូវសមិទ្ធផលនៃយុទ្ធសាស្ត្រនេះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមផ្លាស់ប្តូរវិស័យនេះឱ្យទៅជាឧស្សាហកម្មមួយដែលមានចីរភាពបរិស្ថាន ភាពធន់ តម្លៃបន្ថែមខ្ពស់ កម្លាំងពលកម្មជំនាញ ទីកន្លែងធ្វើការសមរម្យនិងផលិតភាពខ្ពស់ សមាហរណកម្មទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃតំបន់និងពិភពលោក បរិយាកាសធុរកិច្ចល្អ និងភាពជាដៃគូល្អរវាងភាគីរដ្ឋ និយោជក សហជីពនិងតួអង្គផ្សេងទៀត។ យុទ្ធសាស្ត្រនេះក៏នឹងចូលរួមចំណែកក្នុងការបង្កើនសមត្ថភាពប្រកួតប្រជែងនិងជំរុញការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ការឆ្លើយតបទៅនឹងការរំពឹងទុកនិងតម្រូវការរបស់ប្រជាជន និងការកសាងមូលដ្ឋានគ្រឹះចាំបាច់ ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវបង្គោលចរឆ្នាំ២០៣០និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ផងដែរ៕

# មាតិកា

**១. សេចក្តីផ្តើម** ..... ១

**២. ចក្ខុវិស័យ** ..... ៤

**៣. គោលបំណងនិងគោលដៅ** ..... ៤

**៤. បរិការណ៍នៃវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា** ..... ៤

**៥. បញ្ហាប្រឈមនិងកាលានុវត្តភាព** ..... ១៣

**៦. វិធានការជាយុទ្ធសាស្ត្រ** ..... ២១

ក. វិធានការមុតស្រួចរបស់រាជរដ្ឋាភិបាល ..... ២១

ខ. វិធានការអន្តរាគមន៍បន្ទាន់ចំពោះមុខក្នុងបរិការណ៍វិបត្តិជំងឺកូវីដ-១៩ ..... ២៣

គ. វិធានការជាយុទ្ធសាស្ត្រក្រោមក្របខ័ណ្ឌអនុវត្តយុទ្ធសាស្ត្រនេះ ..... ២៤

*៦.១. បន្តពង្រឹងធនធានមនុស្សដើម្បីបង្កើនផលិតភាពនិងបង្កើតគន្លងអាជីពសម្រាប់កម្មករ និយោជិត* ..... ២៤

*៦.២. បន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនិងសុខុមាលភាពរបស់កម្មករ និយោជិត* ..... ២៦

*៦.៣. លើកកម្ពស់ការវិនិយោគក្នុងស្រុកនិងបរទេសក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់* ..... ២៨

*៦.៤. ទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រសម្រាប់បម្រើឱ្យវិស័យនេះ* ..... ៣០

*៦.៥. ជំរុញការធ្វើពិពិធកម្មទីផ្សារសម្រាប់ការនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងកាបូប* ..... ៣១

**៧. ការរៀបចំយន្តការស្ថាប័នសម្រាប់តាមដាននិងវាយតម្លៃការអនុវត្តវិធានការ** ..... ៣២

៧.១. រចនាសម្ព័ន្ធនៃការរៀបចំយន្តការស្ថាប័ន ..... ៣២

៧.២. ក្រុមការងារអន្តរស្ថាប័នទទួលបន្ទុកសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រ ..... ៣៣

៧.៣. ក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ..... ៣៤

**៨. ការគ្រប់គ្រងហានិភ័យ** ..... ៣៤

៨.១. ហានិភ័យខាងក្រៅដែលកើតចេញពីការប្រែប្រួលក្នុងតំបន់និងពិភពលោក ..... ៣៤

៨.២. ហានិភ័យក្នុងស្រុកពាក់ព័ន្ធនឹងការគ្រប់គ្រងបញ្ហាម៉ាក្រូសេដ្ឋកិច្ច ..... ៣៥

៨.៣. ហានិភ័យដែលកើតចេញពីបញ្ហានយោបាយ ..... ៣៥

៨.៤. ហានិភ័យពាក់ព័ន្ធនឹងកិច្ចសម្របសម្រួលអន្តរស្ថាប័ន ..... ៣៦

**៩. សេចក្តីសន្និដ្ឋាន** ..... ៣៦

**បរិសិដ្ឋ: វិធានការជាយុទ្ធសាស្ត្រនិងផែនការសកម្មភាព** ..... ១-១២

## ១. សេចក្តីផ្តើម

ក្នុងរយៈពេលជិតបីទសវត្សរ៍កន្លងមកនេះ កម្ពុជារក្សាបានពេញលេញនូវសន្តិភាព បូរណភាពទឹកដី សាមគ្គីភាពជាតិ និងស្ថិរភាពនយោបាយ តាមរយៈការអនុវត្តគោលនយោបាយជាតិសំខាន់ៗ រួមមាន÷ **គោលនយោបាយ«ឈ្នះ-ឈ្នះ» យុទ្ធសាស្ត្រត្រីកោណ យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ ឈរលើមូលដ្ឋានគ្រឹះនេះ ប្រទេសកម្ពុជាបានសម្រេចនូវការអភិវឌ្ឍឥតឈប់ឈរនិងកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ៧,៧%។ កំណើនសេដ្ឋកិច្ចដ៏រឹងមាំនិងឆាប់រហ័សនេះ បានជួយកាត់បន្ថយអត្រាភាពក្រីក្រ បង្កើតការងារ និងជំរុញការអភិវឌ្ឍនៃវិស័យឯកជនផងដែរ។ ជាមួយនឹងសមិទ្ធផលគួរជាទីមោទនៈទាំងនេះ ប្រទេសកម្ពុជាបានក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាបនិងត្រូវបានធនាគារពិភពលោកចាត់ចូលក្នុងចំណោមប្រទេស«**ឯកឧត្តមកំណើន**» ទាំងប្រាំបីនៅក្នុងពិភពលោកក្នុងឆ្នាំ២០១៥។

ជាការពិត វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបបានចូលរួមចំណែកយ៉ាងសំខាន់ដល់ការសម្រេចបានសមិទ្ធផលខាងលើនេះ។ ផ្អែកលើកត្តាសុខសន្តិភាពនិងស្ថិរភាពនយោបាយ ប្រាក់ឈ្នួលនិងថ្លៃផលិតកម្មប្រកួតប្រជែង ប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្ម និងបរិយាកាសវិនិយោគអំណោយផល វិស័យនេះបានរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយបានក្លាយជាចន្ទល់កំណើនសេដ្ឋកិច្ច។ ជាក់ស្តែង ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៩០ រហូតដល់ឆ្នាំ២០០៨ ការនាំចេញនៃវិស័យនេះមានចំណែកប្រមាណជាង៩៥%នៃការនាំចេញសរុបរបស់កម្ពុជា និងនៅក្រោយវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៩មក ការនាំចេញនៃវិស័យនេះនៅតែរក្សាបានក្នុងកម្រិតខ្ពស់ ជាមធ្យមជាង៧០% ព្រោះថាកម្ពុជាបានធ្វើពិពិធកម្មការនាំចេញផលិតផលផ្សេងទៀតបានមួយកម្រិត មានជាអាទិ៍ដូចជាកង់ គ្រឿងបន្លាស់រថយន្ត និងគ្រឿងបង្គុំអេឡិចត្រូនិកជាដើម។ ទន្ទឹមនេះ ការនាំចេញផលិតផលធ្វើដំណើរ(ឬជាប្រភេទផលិតផលកាបូប) ដូចជាវ៉ាលីស កាបូបស្ពាយ កាបូបយួរដៃ និងកាបូបលុយទៅកាន់ទីផ្សារសហរដ្ឋអាមេរិកមានកំណើនខ្ពស់គួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ ប្រព័ន្ធអនុគ្រោះពន្ធទូទៅ(Generalized System of Preference - GSP) ដែលកម្ពុជាទទួលបានកាលពីឆ្នាំ២០១៦ ក៏បានជួយទ្រទ្រង់ដល់កំណើននៃវិស័យនេះផងដែរ។

ដ្យាក្រាមទី១. ចំណែកការនាំចេញតាមប្រភេទផលិតផល ២០០៨-២០២០




*ប្រភព: អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

**តារាងទី១. ស្ថិតិរោងចក្រ សហគ្រាសកាត់ដេរ ផលិតស្បែកជើង និងកាបូប ១៩៩៧-២០២០**

| ឆ្នាំ | ១៩៩៧ | ២០០៣ | ២០០៨ | ២០១៣ | ១១/២០២០ |
|---|---|---|---|---|---|
| ចំនួនរោងចក្រ សហគ្រាស | ៦៤ | ១៩៧ | ៤៣២ | ៨៨៣ | ១ ២១៨ |
| ចំនួនកម្មករ និយោជិត | ៨២ ០០០ | ២៣៤ ០០០ | ២៨០ ៦០១ | ៥៤៧ ៩៤០ | ៨០៨ ២២៣ |
| ប្រាក់ឈ្នួលអប្បបរមា (ជាដុល្លារអាមេរិក) | ៤០ | ៤៥ | ៥០ | ៨០ | ១៩០ |

*ប្រភព: ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ*

ក្នុងរយៈពេលជាង២០ឆ្នាំមកនេះ(១៩៩៧-២០២០) រោងចក្រ សហគ្រាសកាត់ដេរ ផលិតស្បែកជើង និងកាបូប ដែលបានចុះបញ្ជីនៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកើនពី៦៤ មកដល់ចំនួន ១ ២១៨ ដែលបម្រើឱ្យតម្រូវការក្នុងស្រុកនិងការនាំចេញ រាប់បញ្ចូលទាំងរោងចក្រផលិតសម្រាប់នាំចេញផ្ទាល់និងរោងចក្រ សហគ្រាសម៉ៅការបន្តដែលគាំទ្រផលិតកម្មដល់រោងចក្រផលិតសម្រាប់នាំចេញដូចជាការបោកគក់ ការដេរប៉ាក់ ការជ្រលក់ពណ៌ ការដេរឬការវេចខ្ចប់ជាដើម ខណៈដែលកម្មករ និយោជិតកើនឡើងពីចំនួន៨២ ០០០នាក់ ដល់ចំនួន៨០៨ ២២៣នាក់។ ជារួម វិស័យនេះបានផ្តល់ការងារជាង៨០ម៉ឺនកន្លែងដោយផ្ទាល់ឬប្រមាណពី២,៥ទៅ៣លាននាក់ បើរាប់បញ្ចូលទាំងប្រយោលដល់ប្រជាពលរដ្ឋកម្ពុជា ដែលអាស្រ័យផលពីវិស័យនេះ។ ជាការកត់សម្គាល់ ក្នុងចំណោមរោងចក្រប្រមាណជាង ១ ២១៨ ខាងលើនេះមានរោងចក្រប្រមាណពី៣០០ ទៅ៤០០ ដែលមានកម្មករតិចជាង២០០នាក់ និងជារោងចក្រ សហគ្រាសម៉ៅការបន្តឱ្យរោងចក្រនាំចេញផ្ទាល់[1]។

ទោះបីជាការរីកចម្រើននៃវិស័យនេះជាសក្ខីភាពមួយនៃដំណើរការអភិវឌ្ឍន៍របស់កម្ពុជា រចនាសម្ព័ន្ធនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបនេះ មិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅឡើយទេ។ ឧស្សាហកម្មនេះនៅតែជាមជ្ឈមណ្ឌលផលិតកម្មដែលប្រើប្រាស់កម្មករ និយោជិតមានជំនាញមូលដ្ឋានឬជំនាញមានកម្រិត ពឹងផ្អែកលើការវិនិយោគបរទេសភាគច្រើន និងមានកម្រិតសមាហរណកម្មតភ្ជាប់នៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃនៅមានកម្រិតតិចតួចនៅឡើយ។

ទន្ទឹមនេះ កម្ពុជាក៏កំពុងជួបប្រទះបញ្ហាប្រឈមផ្ទៃក្នុងមួយចំនួនទៀតដែលមានលក្ខណៈជារចនាសម្ព័ន្ធ ជាអាទិ៍ចំណាយផលិតកម្មបានកើនឡើងជាលំដាប់ ដោយសារតែការកើនឡើងនៃប្រាក់ឈ្នួលអប្បបរមា ខណៈកំណើនផលិតភាពនៅមានកម្រិត កម្មករ និយោជិតជំនាញខ្ពស់ក្នុងស្រុកនៅមានចំនួនតិចតួច ភាពប៉ាន់ប្រមាណបាននិងស្ថិរភាពទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងវិស័យនេះនៅបន្តជាបញ្ហាចោទ និងយន្តការសម្របសម្រួលអន្តរស្ថាប័នសម្រាប់ការអភិវឌ្ឍវិស័យនេះនៅមានកម្រិតនៅឡើយ។ ជាមួយគ្នានេះ វិបត្តិជំងឺកូវីដ-១៩ ក៏បានបង្កជាបញ្ហាប្រឈមបន្ថែមដល់វិស័យកាត់ដេរនៅកម្ពុជាផងដែរ។ ទាំងរោងចក្រនិងកម្មករ និយោជិត បានជួបការលំបាកធ្ងន់ធ្ងរ ដូចជាមានការផ្អាកដំណើរការផលិតកម្ម ការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតរាប់ម៉ឺននាក់ និងការបិទជាស្ថាពរ

[1] *ការប្រៀបធៀបរវាងទិន្នន័យបេឡាជាតិរបបសន្តិសុខសង្គមនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម សមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC)។*

របស់រោងចក្រមួយចំនួន ដោយសារវិបត្តិជំងឺកូវីដ-១៩ នៅបណ្តាទីផ្សារនាំចេញធំៗរបស់កម្ពុជា ជាអាទិ៍សហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប ដែលបានធ្វើឱ្យប៉ះពាល់ដល់ការបញ្ជាទិញ ខ្សែច្រវាក់ផ្គត់ផ្គង់ ការផ្លាស់ប្តូរដំណើរការ និងយុទ្ធសាស្ត្រពាណិជ្ជកម្ម/អាជីវកម្ម និងនិន្នាការធំៗនៅក្នុងវិស័យកាត់ដេរតំបន់និងសកល។

នៅក្នុងដំណាក់កាលនៃការអភិវឌ្ឍបច្ចុប្បន្ននេះ កម្រិតនៃការអភិវឌ្ឍនៃវិស័យនេះបានសបញ្ជាក់ថា កម្ពុជាបានឈានមកដល់ចំណុចរបត់មួយ ដែលទាមទារឱ្យមានការត្រួតពិនិត្យឡើងវិញលើទិសដៅនៃការអភិវឌ្ឍវិស័យនេះ ហើយការងារនេះមានសារៈសំខាន់ណាស់សម្រាប់ការនាំចេញរបស់កម្ពុជា និងជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជាពី២,៥ ទៅ៣លាននាក់ ដែលអាស្រ័យផលពីវិស័យនេះ ទាំងដោយផ្ទាល់និងប្រយោល។ ទោះបីជាយ៉ាងនេះក្តី ចំណុចរបត់នេះក៏នៅតែជាកាលានុវត្តភាពមួយក្នុងការអភិវឌ្ឍវិស័យនេះបន្ថែមទៀត និងធ្វើឱ្យវិស័យនេះកាន់តែមានភាពប្រកួតប្រជែងនិងប្រសើរឡើងផ្នែកជំនាញ ផលិតផលនិងផលិតភាព នវានុវត្តន៍ ទំនាក់ទំនងវិជ្ជាជីវៈ ព្រមទាំងសមាហរណកម្មចូលទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃ ដើម្បីជាមូលដ្ឋានក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ចទៅរកវិស័យផ្សេងទៀត។

ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាបានពិនិត្យឃើញពីសារៈសំខាន់និងភាពចាំបាច់ ដែលត្រូវរៀបចំនិងដាក់ឱ្យអនុវត្តនូវ«**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧**» សំដៅកំណត់នូវចក្ខុវិស័យរួម គោលបំណង គោលដៅ និងវិធានការជាយុទ្ធសាស្ត្រ ដើម្បីបន្តពង្រឹងនិងគ្រប់គ្រងការអភិវឌ្ឍវិស័យនេះឱ្យស្របតាមបរិការណ៍កម្ពុជាដែលស្ថិតក្នុងស្ថានភាពទ្វេទិស មានទាំងបញ្ហាប្រឈមនិងកាលានុវត្តភាព ព្រមទាំងឆ្លើយតបទៅនឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៃនិម្មាបនកម្មតំបន់និងពិភពលោក។ ដើម្បីធានាសមត្ថភាពប្រកួតប្រជែងនិងលើកកម្ពស់វិស័យនេះឱ្យបន្តដើរតួនាទីសំខាន់ក្នុងដំណើរការអភិវឌ្ឍន៍កម្ពុជា ការរៀបចំនិងអនុវត្តយុទ្ធសាស្ត្រនេះមិនមែនជាការងារដាច់ដោយឡែកនោះទេ ប៉ុន្តែត្រូវបានគិតគូរដោយមានសង្គតិភាពជាមួយនិងក្រោមក្របខ័ណ្ឌគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំខាន់ៗ ជាអាទិ៍រួមមាន **១-យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ២-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ៣-គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ៤-គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ ៥-គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ៦-យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០១៩-២០២៣ និង៧-ក្របខ័ណ្ឌយុទ្ធសាស្ត្រនិងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣។**

យុទ្ធសាស្ត្រនេះនឹងដាក់ចេញនូវវិធានការរយៈពេលខ្លីនិងមធ្យម ព្រមទាំងកំណត់នូវយន្តការអន្តរស្ថាប័ន និងស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្តវិធានការដែលគោរពតាមក្របខ័ណ្ឌពេលវេលាជាក់លាក់។ យុទ្ធសាស្ត្រនេះចាត់ទុកជាឯកសាររស់ ដែលអាចនឹងត្រូវកែសម្រួលជាយថាហេតុដោយរាជរដ្ឋាភិបាល ដើម្បីធានាសង្គតិភាពទៅតាមការវិវត្តជាក់ស្តែង។

## ២. ចក្ខុវិស័យ

រាជរដ្ឋាភិបាល នឹងអភិវឌ្ឍវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបនៅកម្ពុជា ឱ្យទៅជាឧស្សាហកម្មដែលមានចីរភាពបរិស្ថាន មានភាពធន់ មានតម្លៃបន្ថែមខ្ពស់ ផ្តោតលើផលិតផលថ្លៃខ្ពស់និងមានលក្ខណៈពិសេស មានភាពប្រកួតប្រជែងខ្ពស់ និងជាមូលដ្ឋានគាំទ្រពិពិធកម្មសេដ្ឋកិច្ចនៅមុនដំណាច់ឆ្នាំ២០២៧។ ការសម្រេចបាននូវចក្ខុវិស័យនេះ មិនត្រឹមតែរួមចំណែកដល់ចីរភាពនៃកំណើនសេដ្ឋកិច្ចនិងគោលដៅអភិវឌ្ឍន៍របស់ប្រទេសកម្ពុជានោះទេ ប៉ុន្តែថែមទាំងគាំទ្រ បំពេញបន្ថែម និងស្របជាមួយការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំខាន់ៗ ដូចដែលបានគូសបញ្ជាក់ខាងលើ និងចូលរួមចំណែកគាំទ្រការឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

## ៣. គោលបំណងនិងគោលដៅ

យុទ្ធសាស្ត្រនេះ មានគោលបំណងកំណត់នូវទិសដៅអភិវឌ្ឍន៍រួម បង្កើនភាពឯករាជ្យ និងពង្រឹងភាពប៉ាន់-ប្រមាណបាននិងស្ថិរភាពនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ដើម្បីបន្តលើកកម្ពស់ការអភិវឌ្ឍវិស័យនេះប្រកបដោយចីរភាពនិងបរិយាប័ន្ន។ ដើម្បីសម្រេចបាននូវគោលបំណងនិងចក្ខុវិស័យខាងលើ យុទ្ធសាស្ត្រនេះមានគោលដៅ៖

១)-បន្តពង្រឹងធនធានមនុស្សដើម្បីបង្កើនផលិតភាពនិងបង្កើតគន្លងអាជីពសម្រាប់កម្មករ និយោជិត

២)-បន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនិងសុខុមាលភាពរបស់កម្មករ និយោជិត

៣)-លើកកម្ពស់ការវិនិយោគក្នុងស្រុកនិងបរទេសក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ និងផ្តោតលើផលិតផលថ្លៃខ្ពស់និងមានលក្ខណៈពិសេស

៤)-ទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រសម្រាប់បម្រើឱ្យវិស័យនេះ និង

៥)-ជំរុញការធ្វើពិពិធកម្មទីផ្សារសម្រាប់ការនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងកាបូប។

## ៤. បរិការណ៍នៃវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា

ក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រនេះ ផ្នែកបរិការណ៍ផ្តោតសំខាន់លើ ១-ស្ថានភាពបច្ចុប្បន្ន នៃវិស័យនេះ ២-ចំណុចខ្លាំងនៃវិស័យនេះ និង ៣-បញ្ហាប្រឈមនិងកាលានុវត្តភាព ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ការរៀបចំវិធានការយុទ្ធសាស្ត្រ ឈានទៅសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃយុទ្ធសាស្ត្រនេះ។

### ៤.១ ស្ថានភាព

ដោយឈរលើមូលដ្ឋាននៃប្រាក់ឈ្នួលនិងថ្លៃផលិតកម្មប្រកួតប្រជែង ប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្ម និងបរិយាកាសវិនិយោគអំណោយផល វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា បានទាក់ទាញវិនិយោគិន និងចាប់ផ្តើមដំណើរការអស់រយៈពេលជាងពីរទសវត្សរ៍កន្លងមក ហើយបានវិវត្តខ្លួនជាបន្តបន្ទាប់ ដោយមានលក្ខណ-សម្បត្តិនិងទិដ្ឋភាព ដូចខាងក្រោម៖

## ៤.១.១ និន្នាការទូទៅនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប

វិស័យនេះបានចាប់ផ្តើមនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ក្រោមទម្រង់ជាផលិតកម្មកាត់ ដេរ និងតម្រឹម ឬកាត់ ដេរ និងវេចខ្ចប់(ឬហៅកាត់ថា ស៊ីអិមធី - CMT/CMP) និងបានទាក់ទាញវិនិយោគិនបរទេស ដែលក្នុងនោះភាគច្រើនមកពីប្រទេសចិន(រួមបញ្ចូលទាំងកោះតៃវ៉ាន់និងទីក្រុងហុងកុង) និងសាធារណរដ្ឋកូរ៉េ ដែលបង្កើតនិងគ្រប់គ្រងរោងចក្រផលិតកម្មនៅកម្ពុជា ជាទូទៅមានតម្លៃបន្ថែមទាប ពឹងផ្អែកលើកម្លាំងពលកម្មមានជំនាញទាប និងទទួលបានប្រាក់ចំណេញមានកម្រិតទាប បើប្រៀបធៀបនឹងម៉ូដែលផលិតកម្មផ្សេងទៀត។ និន្នាការនៃការវិនិយោគ និងគ្រប់គ្រងផលិតកម្មភាគច្រើនដោយវិនិយោគិនបរទេស នៅតែបន្តរហូតមកដល់បច្ចុប្បន្ន ដែលវិនិយោគិនបរទេសទាំងនោះជាទូទៅមានស្នាក់ការកណ្តាលនៅប្រទេសដើមរបស់ពួកគេ គ្រប់គ្រងរោងចក្រផលិតកម្មនៅកម្ពុជា ដែលជាផ្នែកមួយនៃក្រុមហ៊ុនធំរបស់ពួកគេ ធ្វើទំនាក់ទំនងជាមួយនឹងអ្នកបញ្ជាទិញនិងម្ចាស់ម៉ាកផលិតផល និងធ្វើការសម្រេចចិត្តនិងគ្រប់គ្រងដំណើរការនានាដោយផ្ទាល់ ដែលសកម្មភាពទាំងនេះមានបន្ថែមតម្លៃខ្ពស់ ដូចជា ការច្នៃម៉ូដផលិតផល លទ្ធកម្មវត្ថុធាតុដើម ការបែងចែកកម្រិតបរិមាណផលិតកម្ម និងការរៀបចំការដឹកជញ្ជូនទំនិញទៅកាន់ទីផ្សារជាដើម។

ជាក់ស្តែង វិនិយោគិនជនជាតិចិន(រួមទាំងវិនិយោគិនមកពីកោះតៃវ៉ាន់ និងទីក្រុងហុងកុង) គឺជាវិនិយោគិនធំជាងគេនៅក្នុងឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូបនៅកម្ពុជា ដែលមានរោងចក្រប្រមាណជិត៧០% នៃរោងចក្រចំនួនប្រមាណជាង៦០០ ដែលផលិតសម្រាប់ការនាំចេញ(ក្នុងនោះរោងចក្រកាត់ដេរស្មើនឹងប្រមាណ ៨២% រោងចក្រផលិតផលស្បែកជើងចំនួន៣% រោងចក្រផលិតផលកាបូប៦% និងរោងចក្រផ្សេងៗប្រមាណ ៩%) ចំណែកម្ចាស់រោងចក្រ ដែលមានសញ្ជាតិកម្ពុជាមានត្រឹមប្រមាណ៥%ប៉ុណ្ណោះ ខណៈដែលជាង៩៥%នៃរោងចក្រត្រូវបានប្រមូលផ្តុំនៅតាមទីតាំង រួមមាន រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ ព្រះសីហនុ ស្វាយរៀង កំពត និងតាកែវ[2]។

ដ្យាក្រាមទី២. ទិន្នន័យសញ្ជាតិវិនិយោគិនឆ្នាំ២០២០




ដ្យាក្រាមទី៣. រោងចក្រកាត់ដេរ ផលិតស្បែកជើង និងកាបូបនៅកម្ពុជា




*ប្រភព: ក្រសួងពាណិជ្ជកម្មនិងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC)*

---

2 *ដោយផ្អែកលើទិន្នន័យក្រសួងពាណិជ្ជកម្មនិងបញ្ជីសមាជិកពីសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) គិតត្រឹមឆ្នាំ២០២០*

ម្ចាស់រោងចក្រផ្សេងទៀតមកពីសាធារណរដ្ឋកូរ៉េ ជប៉ុន ម៉ាឡេស៊ី ហូឡង់ សិង្ហបុរី ថៃ ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក កាណាដា បារាំង អូស្ត្រាលី ឥណ្ឌា ស៊ុយអែត ស្វីស និងប្រទេសផ្សេងទៀត។ ការណ៍នេះបានសបញ្ជាក់ឱ្យឃើញថា ចំនួនសហគ្រិនក្នុងស្រុកក្នុងឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូបនៅមានកម្រិតទាប ទោះបីជាឧស្សាហកម្មនេះបានចាប់បដិសន្ធិអស់រយៈពេលជាងពីរទសវត្សរ៍កន្លងមក ដែលកត្តានេះជាហានិភ័យមួយរបស់កម្ពុជានៅពេលម្ចាស់រោងចក្រ សហគ្រាសជាជនបរទេសចាកចេញពីកម្ពុជា ទៅរកគោលដៅវិនិយោគផ្សេងទៀតមានឧត្តមភាពប្រកួតប្រជែងប្រសើរជាងនៅកម្ពុជា។

### ៤.១.២ ការនាំចេញនិងទីផ្សារនាំចេញសំខាន់ៗ

ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០មក ឧស្សាហកម្មកាត់ដេរនៅកម្ពុជាចាប់ផ្តើមប្រតិបត្តិការនៅពេលដែលអ្នកផលិតផលិតផលកាត់ដេរនិងវាយនភណ្ឌអាស៊ី(Asian Textile and Garment Producers) ដែលរួមមានប្រទេសចិន(រួមទាំងកោះតៃវ៉ាន់និងទីក្រុងហុងកុង) សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី និងសិង្ហបុរី បានមកបណ្តាក់ទុននៅកម្ពុជា ដោយសារកត្តានៃភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម តាមរយៈកូតាការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប គួបផ្សំនឹងកម្លាំងពលកម្ម ដែលមានកម្រិតប្រាក់ឈ្នួលប្រកួតប្រជែង។ ជារួម ទោះបីជាកិច្ចព្រមព្រៀងពាណិជ្ជកម្មលើផលិតផលពហុសរសៃ(Multi Fiber Arrangement 1974-1995) និងកិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌនិងសម្លៀកបំពាក់(Agreement on Textiles and Clothing 1996-2005) បានផុតកំណត់នៅឆ្នាំ១៩៩៥និងឆ្នាំ២០០៥ជាបន្តបន្ទាប់ ហើយកម្ពុជាបានទទួលរងនូវការកម្រិតលើកូតានាំចូលទៅកាន់ទីផ្សារធំៗក្នុងចន្លោះពីឆ្នាំ១៩៩០ទៅឆ្នាំ២០០៤ក៏ពិតមែន តែឧស្សាហកម្មកាត់ដេរបាននិវត្តយ៉ាងឆាប់រហ័ស ហើយការនាំចេញផលិតផលនេះទៅទីផ្សារសហរដ្ឋអាមេរិក កាណាដា និងសហភាពអឺរ៉ុប មានការកើនឡើងជាលំដាប់ រួមផ្សំនឹងការដែលកម្ពុជាទទួលបានភាពអនុគ្រោះផ្នែកពាណិជ្ជកម្មផ្សេងៗ ដែលជាលក្ខខណ្ឌអំណោយផលដល់ការនាំចេញជាអាទិ៍តាមរយៈការទទួលបានឋានៈជាប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត(Most Favored Nations - MFNs) របស់សហរដ្ឋអាមេរិកនៅឆ្នាំ១៩៩៦ ឋានៈជាប្រជាជាតិក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទូទៅ(Generalized System of Preference - GSP) របស់សហភាពអឺរ៉ុបនៅឆ្នាំ១៩៩៧ កិច្ចព្រមព្រៀងពាណិជ្ជកម្មវាយនភណ្ឌរវាងកម្ពុជាសហភាពអឺរ៉ុបនៅឆ្នាំ១៩៩៩ ការចូលជាសមាជិកអាស៊ាននៅឆ្នាំ១៩៩៩ ឋានៈប្រទេសមានកម្រិតអភិវឌ្ឍន៍តិចតួច(LDCs) ក្រោមប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ(EBA) សម្រាប់ទីផ្សារសហភាពអឺរ៉ុបនៅចុងឆ្នាំ២០០១ និងការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក(WTO) នៅខែតុលាឆ្នាំ២០០៤។ ការដែលកម្ពុជាបានចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក(WTO) បានធ្វើឱ្យផលិតផលកាត់ដេររបស់កម្ពុជា រួចផុតពីការកំណត់កូតានានា បន្ទាប់ពីកិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌនិងសម្លៀកបំពាក់ឆ្នាំ១៩៩៦ បានផុតរលត់នៅឆ្នាំ២០០៥។

នៅក្នុងឆ្នាំ២០០១ ចំនួនរោងចក្រមានប្រមាណ១៨៧ និងធ្វើការនាំចេញក្នុងទំហំប្រមាណ១៨៥លានដុល្លារអាមេរិក។ ជាមួយគ្នានេះ មានការរំពឹងទុកថាការនាំចេញរបស់កម្ពុជានឹងត្រូវធ្លាក់ចុះ ដោយសារការផុតសុពលភាពនៃការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មលើផលិតផលពហុសរសៃនៅឆ្នាំ២០០៤។ ប៉ុន្តែឧស្សាហកម្មនេះនៅកម្ពុជាបែរជាមានភាពប្រសើរឡើងជាលំដាប់ ទាំងចំនួនរោងចក្រ ចំនួនការងារដែលត្រូវបានបង្កើត និងបរិមាណផលិតផលនាំចេញ។ នៅអំឡុងពេលនោះ ការនាំចេញនៃផលិតផលនេះបានចូលរួមចំណែកប្រមាណជា៧០% ទៅ៨០%នៃការនាំចេញទំនិញសរុបរបស់កម្ពុជា។ សហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប គឺជាទីផ្សារនាំចេញធំបំផុតដែលក្នុងនោះ អត្រានាំចេញប្រមាណ៦០-៧០% ទៅសហរដ្ឋអាមេរិក និងប្រមាណ២០% ទៅសហភាពអឺរ៉ុប។ ជាការកត់សម្គាល់ តាមរយៈប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ(EBA) ការនាំចេញទៅកាន់ទីផ្សារអឺរ៉ុបមានការកើនឡើងជាបន្តបន្ទាប់ ដែលបានធ្វើឱ្យទីផ្សារសហភាពអឺរ៉ុប(រាប់បញ្ចូលទាំងចក្រភពអង់គ្លេស) ក្លាយជាទីផ្សារនាំចេញធំបំផុតមួយរបស់កម្ពុជា។

ក្នុងឆ្នាំ២០២០ ការនាំចេញផលិតផលកាត់ដេរសរុបរបស់កម្ពុជាមានទឹកប្រាក់ស្មើនឹង៩,៧ប៊ីលានដុល្លារអាមេរិក និងមានអត្រាកំណើនថមថយខ្លាំងក្នុងអត្រាប្រមាណ-៩,៩% ដោយសារតែវិបត្តិជំងឺកូវីដ-១៩ ដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចសកល រួមទាំងកម្ពុជា ដែលពឹងផ្អែកលើទីផ្សារនាំចេញសម្រាប់ផលិតផលកាត់ដេររបស់ខ្លួន។ ក្នុងឆ្នាំ២០១៨និងឆ្នាំ២០១៩វិញ ការនាំចេញផលិតផលកាត់ដេរសរុបមានអត្រាកំណើនរឹងមាំពីរខ្ទង់ ១៥,១%និង១៣% រៀងគ្នា ដែលត្រូវនឹងទឹកប្រាក់ប្រមាណ៩,៥៩និង១០,៨៤ប៊ីលានដុល្លារអាមេរិក។ ទន្ទឹមនេះ ត្បិតផលិតផលស្បែកជើងនៅមានទំហំតូចបើប្រៀបធៀបទៅនឹងផលិតផលកាត់ដេរ ចំណែករបស់ផលិតផលស្បែកជើងបានកើនឡើងជាលំដាប់ហើយវាបានកើនឡើងជាមធ្យមប្រមាណជិត៣០%ក្នុងមួយឆ្នាំ ចន្លោះឆ្នាំ២០០៩ និងឆ្នាំ២០១៩។ ដោយឡែក ការនាំចេញផលិតផលធ្វើដំណើរ(ឬផលិតផលកាបូប) ដូចជា វ៉ាលីស កាបូបស្ពាយ កាបូបយួរដៃ និងកាបូបលុយ ទៅកាន់ទីផ្សារសហរដ្ឋអាមេរិកក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP) ដែលកម្ពុជាទទួលបានក្នុងឆ្នាំ២០១៦ ក៏បានជួយទ្រទ្រង់ដល់ឧស្សាហកម្មនេះ។ ក្នុងឆ្នាំ២០១៦ ការនាំចេញផលិតផលកាបូបមានកំណើនខ្ពស់គួរឱ្យកត់សម្គាល់ប្រមាណពី១៤០លានដុល្លារអាមេរិក ដែលស្មើនឹងប្រមាណ១,៨%នៃតម្លៃនាំចេញសរុបមកប្រមាណ១,០ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹង១០%នៃតម្លៃនាំចេញផលិតផលកាត់ដេរសរុបនៅក្នុងឆ្នាំ២០២០។ ទន្ទឹមនេះ ក្នុងឆ្នាំ២០២០ ការនាំចេញផលិតផលកាត់ដេរកម្ពុជាសរុបទៅកាន់ទីផ្សារសហរដ្ឋអាមេរិកស្មើនឹងប្រមាណ៣៦,៧% សហភាពអឺរ៉ុប៣៤,៩%(រួមទាំងចក្រភពអង់គ្លេសប្រមាណ៧,៤%) ជប៉ុន៨,៩% អាស៊ាន២% និងទីផ្សារផ្សេងទៀត១៧,៥% នៃតម្លៃនាំចេញសរុប[3]។

[3] *យោងតាមទិន្នន័យពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

ដ្យាក្រាមទី៤. កំណើនតម្លៃនាំចេញផលិតផលកាត់ដេរ (គិតជា លានដុល្លារអាមេរិក) ២០០៨-២០២០




ដ្យាក្រាមទី៥. ចំណែកទីផ្សារនៃការនាំចេញផលិតផលកាត់ដេរសរុប ២០០៨-២០២០




*ប្រភព: អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

## ៤.១.៣ ប្រភេទនៃផលិតផលនិងម៉ូដែលផលិតកម្មនៅកម្ពុជា

តម្លៃបន្ថែមពីផលិតកម្មនៃផលិតផលកាត់ដេរនិងផលិតផលស្បែកជើង មានការលំបាកក្នុងការវាស់វែង ប៉ុន្តែត្រូវបានវាយតម្លៃលើមូលដ្ឋាននៃលក្ខណៈឬម៉ូដសាមញ្ញរបស់ផលិតផលដែលត្រូវបានចាត់ទុកថាមានតម្លៃបន្ថែមទាបជាងផលិតផលដែលមានម៉ូដស្មុគស្មាញ។ ផលិតផលកាត់ដេរនិងផលិតផលស្បែកជើងនៅកម្ពុជា នៅមិនទាន់មានភាពស្មុគស្មាញដែលតម្លៃបន្ថែមនៅមានកម្រិតនៅឡើយ។ នៅចន្លោះពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ដល់ឆ្នាំ២០១៥ ការនាំចេញផលិតផលកាត់ដេរត្រូវបានប្រមូលផ្តុំនៅក្នុងប្រភេទទំនិញ០៤ប្រភេទ រួមមាន: ១-ប្រភេទផលិតផលអាវចាក់ពាក់ពីក្រៅ(Sweaters/Pullovers) ២-ប្រភេទផលិតផលខោបុរស(Men's Trousers) ៣-ប្រភេទផលិតផលខោស្ត្រី(Women's Trousers) និង៤-ប្រភេទអាវយឺត(T-Shirts/Singles) [4] ដែលជាប្រភេទផលិតផលសាមញ្ញមានតម្លៃបន្ថែមទាបនិងមធ្យម និងស្មើនឹងប្រមាណ៧៥%នៃចំណែកការនាំចេញផលិតផលកាត់ដេរសរុប។ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ២ភាគ៣នៃផលិតផលកាត់ដេរ នៅតែស្ថិតក្នុងប្រភេទផលិតផលមានតម្លៃបន្ថែមទាបនិងមធ្យម និងបានកើនឡើងជាបរិមាណ។ ចំណែកប្រមាណជិត១ភាគ៣នៃផលិតផលកាត់ដេរផ្សេងទៀតត្រូវបានចាត់ទុកជាផលិតផលមានលក្ខណៈ ឬម៉ូដស្មុគស្មាញ រួមទាំងផលិតផលកាបូប ដែលមានតម្លៃបន្ថែមខ្ពស់។

ដោយឡែក ចំពោះម៉ូដែលផលិតកម្មនៃរោងចក្រនៅកម្ពុជានាពេលបច្ចុប្បន្ន រោងចក្រផលិតសម្រាប់នាំចេញមានប្រមាណ៧០%នៃរោងចក្រនាំចេញប្រមាណ៦០០ ស្ថិតនៅក្នុងម៉ូដែលផលិតកម្មស៊ីអិមធី(CMT) ខណៈរោងចក្រប្រមាណ៣០%ផ្សេងទៀតទទួលបានការបញ្ជាទិញជាម៉ូដែលផលិតកម្មអេហ្វអូប៊ី[5](Free On Board - FOB)។

---

[4] *យោងតាមរបាយការណ៍ការសិក្សាស្រាវជ្រាវរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC)*

[5] *យោងតាមទិន្នន័យពីសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងលទ្ធផលនៃការអង្កេតជាមួយវិនិយោគិន និងអ្នកគ្រប់គ្រងរោងចក្រកាលពីឆ្នាំ២០១៧*

លក្ខណសម្បត្តិខុសគ្នារវាងរោងចក្រស៊ីអិមធី(CMT) និងរោងចក្រអេហ្វអូប៊ី(FOB) គឺស្ថិតត្រង់រោងចក្រអេហ្វអូប៊ី(FOB) ទទួលបានកម្រិតប្រាក់ចំណេញនិងភាពបត់បែនខ្ពស់ជាងរោងចក្រស៊ីអិមធី(CMT) ដោយមានសិទ្ធិសម្រេចចិត្តលើលទ្ធកម្មវត្ថុធាតុដើម(ដូចជាកំណាត់និងផលិតផលបន្ទាប់បន្សំ) និងការដឹកជញ្ជូនពីរោងចក្រទៅកំពង់ផែ បន្ថែមលើចំណាយផ្សេងទៀត ដូចជា កម្លាំងពលកម្ម និងប្រតិបត្តិការផ្សេងៗ។ ជារួម ម៉ូដែលផលិតកម្មស៊ីអិមធី(CMT) ទទួលបានកម្រិតប្រាក់ចំណេញតិចតួចនិងមានតម្លៃបន្ថែមទាបសម្រាប់សេដ្ឋកិច្ចកម្ពុជាជាងរោងចក្រអេហ្វអូប៊ី(FOB) ហើយដំណើរការផលិតកម្មនិងការចរចាថ្លៃត្រូវបានសម្រេចដោយក្រុមហ៊ុនមេ(ស្នាក់ការកណ្តាល) អ្នកផលិត ឬភ្នាក់ងារនៅក្រៅប្រទេសកម្ពុជា។

### ៤.១.៤ ការវិវត្តថ្មី៖ ផលប៉ះពាល់ពីការព្យួរប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ(EBA)និងការរីករាលដាលជំងឺកូវីដ-១៩

ទំនិញនាំចេញពីកម្ពុជាដែលរំពឹងថានឹងរងផលប៉ះពាល់ អាចមានក្នុងទំហំទឹកប្រាក់ចំនួន១,២៧ប៊ីលានដុល្លារអាមេរិក និងត្រូវបង់ពន្ធក្នុងអត្រាចន្លោះពី២,៧%ទៅ១២% ក្រោយពីការសម្រេចព្យួរប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ(EBA) ដោយគណៈកម្មការអឺរ៉ុប។ ការណ៍នេះ អាចនឹងបង្កឱ្យមានផលប៉ះពាល់ទៅដល់រោងចក្រ សហគ្រាសក្នុងកម្រិតផ្សេងៗគ្នា ទៅតាមទំហំនៃការនាំចេញជាក់ស្តែង។ តាមការវាយតម្លៃ រោងចក្រសហគ្រាសចំនួនប្រមាណ១៥% ក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបអាចនឹងទទួលរងនូវផលប៉ះពាល់។

ជាមួយគ្នានេះ ការរីករាលដាលនៃជំងឺកូវីដ-១៩ដែលបានចាប់ផ្តើមមានឥទ្ធិពលតាំងដើមឆ្នាំ២០២០មកបានធ្វើឱ្យរោងចក្រ សហគ្រាសកាត់ដេរមួយចំនួនទទួលរងផលប៉ះពាល់ ដោយមិនអាចនាំចូលនូវវត្ថុធាតុដើមគ្រប់គ្រាន់និងទាន់ពេលដើម្បីផលិតតាមការបញ្ជាទិញ។ រហូតពាក់កណ្តាលឆ្នាំ២០២០ វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបរងផលប៉ះពាល់កាន់តែខ្លាំងឡើង ដោយរោងចក្រដែលបានស្នើសុំផ្អាកដំណើរការផលិតកម្ម ព្យួរកិច្ចសន្យាការងារ ឬបិទជាស្ថាពរបានកើនឡើងជាលំដាប់ ដោយសារតែស្ថានភាពទីផ្សារនៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបដែលជាទីផ្សារធំទាំងពីររបស់កម្ពុជា នៅមិនទាន់មានភាពធូរស្រាលនៅឡើយ មានការផ្អាកការបញ្ជាទិញពីកម្ពុជា មានការលុបចោលការបញ្ជាទិញ ឬមានការបដិសេធមិនទទួលយកទំនិញ ដែលបានផលិតរួចសម្រាប់រោងចក្រមួយចំនួន។ មកដល់ចុងឆ្នាំ២០២០ សភាពការណ៍នៃវិបត្តិជំងឺកូវីដ-១៩ នៅតែមិនទាន់មានភាពល្អប្រសើរនៅឡើយ បើទោះជាមានការអនុញ្ញាតឱ្យប្រើប្រាស់នូវវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជាបន្តបន្ទាប់ក៏ដោយ។

ការថមថយតម្រូវការនៃទីផ្សារធំទាំងពីរនេះរបស់កម្ពុជា បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់វិស័យកាត់ដេរ ប៉ុន្តែជាការកត់សម្គាល់វិស័យកាត់ដេររបស់កម្ពុជានៅតែអាចទប់ទល់និងស្ថិតក្នុងស្ថានភាពដែលអាចគ្រប់គ្រងបានមួយកម្រិត ដោយសារមានការជ្រោមជ្រែងនិងការអន្តរាគមន៍ពីរាជរដ្ឋាភិបាលនិងតួអង្គពាក់ព័ន្ធ គួបផ្សំនឹងកត្តាខាងក្រៅ ដែលបណ្តាប្រទេសប្រកួតប្រជែងមួយចំនួននៅតែបន្តរងផលប៉ះពាល់ធ្ងន់ធ្ងរដោយជំងឺកូវីដ-១៩។ ការអូសបន្លាយនៃជំងឺកូវីដ-១៩ រហូតមកដល់បច្ចុប្បន្ន អាចបង្កឱ្យមានភាពមិនច្បាស់លាស់នៅក្នុងវិស័យនេះ ជាពិសេសការគ្រប់គ្រងនៃការរីករាលដាលនៃជំងឺនេះនៅក្នុងទីផ្សារធំៗរបស់កម្ពុជា ដែលទាមទារឱ្យកម្ពុជាត្រូវគិតគូរនិងដោះស្រាយបញ្ហាប្រឈមនៅក្នុងវិស័យនេះ និងត្រៀមខ្លួនចាប់យកកាលានុវត្តភាព ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យនេះឱ្យកាន់តែរឹងមាំ។

## ៤.២ ចំណុចខ្លាំងនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា

ចាប់តាំងពីការចាប់ផ្តើមនៃឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូបជាងពីរទសវត្សរ៍កន្លងមក ប្រទេសកម្ពុជានៅតែផ្តល់នូវកត្តាទាក់ទាញជាច្រើនសម្រាប់វិនិយោគិន។ ក្នុងនោះ ចំណុចខ្លាំងចំនួន៥ ជាកត្តាទាក់ទាញរួមមាន÷

### ៤.២.១ ការបើកចំហសេដ្ឋកិច្ចនិងបរិយាកាសវិនិយោគអំណោយផល

ការបើកចំហសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ព្រមជាមួយនឹងការផ្តល់នូវរបបនៃការលើកទឹកចិត្តវិនិយោគជូនវិនិយោគិន ទាំងក្នុងស្រុកនិងបរទេសដោយទទួលបានប្រព្រឹត្តិកម្មពុំមានការរើសអើង ការអនុញ្ញាតឱ្យជនបរទេសអាចមានកម្មសិទ្ធិ១០០% លើអាជីវកម្ម និងការកំណត់អត្រាពន្ធលើប្រាក់ចំណូល២០% មានភាពប្រកួតប្រជែងធៀបទៅនឹងប្រទេសក្នុងតំបន់ បានក្លាយជាចំណុចខ្លាំងមួយរបស់កម្ពុជាក្នុងការទាក់ទាញវិនិយោគិន។ របបនៃការលើកទឹកចិត្តវិនិយោគសម្រាប់គម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ស្របតាមការកំណត់ដោយច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិជាធរមាន ក៏ជាការទាក់ទាញដ៏ធំមួយសម្រាប់វិស័យនេះ និងអាស្រ័យលើការអនុវត្តជាក់ស្តែងនៃគម្រោងនិងសកម្មភាពវិនិយោគនីមួយៗ។ ទន្ទឹមនេះ គម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ និងជាប្រភេទឧស្សាហកម្មគាំទ្រក៏មានសិទ្ធិនាំចូល ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម។ ដោយឡែក គម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់បម្រើទីផ្សារក្នុងស្រុកក៏មានសិទ្ធិនាំចូល ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈបរិក្ខារផលិតកម្ម លើកលែងតែធាតុចូលផលិតកម្មត្រូវអនុលោមតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រង និង/ឬអនុក្រឹត្យ។

### ៤.២.២ សមត្ថភាពផលិតកម្ម

តួអង្គពាក់ព័ន្ធជាអាទិ៍វិនិយោគិន អ្នកបញ្ជាទិញ និងម្ចាស់ម៉ាកផលិតផលចាត់ទុកកម្ពុជាជាប្រទេសមានកម្លាំងពលកម្មវ័យក្មេងនិងថ្លៃកម្លាំងពលកម្មប្រកួតប្រជែង ជាមួយនឹងសមត្ថភាពផលិតកម្មគ្រប់គ្រាន់ ដែលអាចឆ្លើយតបទៅនឹងបរិមាណបញ្ជាទិញបាន។ ក្នុងចំណោមប្រជាជនប្រមាណ១៦លាននាក់នៅឆ្នាំ២០១៨ ១០,៧លាននាក់(៦៦%) ត្រូវបានគេប៉ាន់ស្មានថាមានអាយុចន្លោះពី១៥-៦៤ឆ្នាំ។ អ្នកបញ្ជាទិញបានកត់សម្គាល់ឃើញថា រោងចក្រជាច្រើននៅក្នុងប្រទេសកម្ពុជាមានសមត្ថភាពក្នុងការឆ្លើយតបនឹងការបញ្ជាទិញធំៗ ជាពិសេសក្នុងបរិមាណច្រើនដូចនៅក្នុងប្រទេសវៀតណាមនិងបង់ក្លាដែស ដែលមានចំនួនប្រជាជនច្រើនជាងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងនៃតម្រូវការទំនិញម៉ូដពេញនិយម(Fast Fashion) បានដាក់សម្ពាធដល់សមត្ថភាពផលិតកម្មនិងរយៈពេលផលិតកម្ម និងរយៈពេលបញ្ជូនទំនិញទៅទីផ្សារ(Lead Time & Speed to Market) ដែលទាំងនេះគឺជាកត្តាមួយក្នុងលក្ខណវិនិច្ឆ័យសម្រាប់ការសម្រេចលើការបញ្ជាទិញ ដែលកំពុងតែមានសារៈសំខាន់កាន់តែខ្លាំងឡើងចំពោះឧស្សាហកម្មនេះ។

### ៤.២.៣ ការទទួលបានប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្ម

មកដល់បច្ចុប្បន្ន កម្ពុជានាំចេញផលិតផលកាត់ដេរ ផលិតផលស្បែកជើង និងកាបូបទៅកាន់ទីផ្សារធំៗ ចំនួន៦ រួមមាន សហភាពអឺរ៉ុប សហរដ្ឋអាមេរិក កាណាដា ជប៉ុន អាស៊ាន និងទីផ្សារផ្សេងទៀត ដែលក្នុងនោះ ចំណែកទីផ្សាររបស់អឺរ៉ុបនិងសហរដ្ឋអាមេរិករួមបញ្ចូលគ្នា ស្មើនឹងប្រមាណ៧០%នៃតម្លៃនាំចេញសរុបនៃផលិតផល ខាងលើ។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ រហូតដល់មុនឆ្នាំ២០០៥ ទោះបីជាកិច្ចព្រមព្រៀងពាណិជ្ជកម្មលើផលិតផល ពហុសរសៃ(Multi Fiber Arrangement 1974-1995) និងកិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌនិងសម្លៀកបំពាក់ (Agreement on Textiles and Clothing 1996-2005) បានផុតកំណត់នៅឆ្នាំ១៩៩៥ និងឆ្នាំ២០០៥ ជាបន្តបន្ទាប់ ហើយកម្ពុជាបានទទួលរងនូវការកម្រិតលើកូតា នាំចូលទៅកាន់ទីផ្សារធំៗក្នុងចន្លោះពីឆ្នាំ១៩៩០ទៅឆ្នាំ២០០៤ ក៏ពិតមែន តែឧស្សាហកម្មកាត់ដេរបានវិវត្តយ៉ាងឆាប់រហ័ស ហើយការនាំចេញផលិតផលនេះទៅទីផ្សារសហរដ្ឋ អាមេរិក កាណាដា និងសហភាពអឺរ៉ុប មានការកើនឡើងជាលំដាប់ រួមផ្សំនឹងការដែលកម្ពុជាទទួលបានភាពអនុគ្រោះ ផ្នែកពាណិជ្ជកម្មផ្សេងៗ ដែលជាលក្ខខណ្ឌអំណោយផលដល់ការនាំចេញជាអាទិ៍តាមរយៈការទទួលបានឋានៈជា ប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត(Most Favored Nations - MFNs) របស់សហរដ្ឋអាមេរិកនៅឆ្នាំ ១៩៩៦ ឋានៈជាប្រជាជាតិក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទូទៅ(Generalized System of Preference - GSP) របស់សហភាពអឺរ៉ុបនៅឆ្នាំ១៩៩៧ កិច្ចព្រមព្រៀងពាណិជ្ជកម្មវាយនភណ្ឌរវាងកម្ពុជា សហភាពអឺរ៉ុបនៅឆ្នាំ១៩៩៩ ការចូលជាសមាជិកអាស៊ាននៅឆ្នាំ១៩៩៩ ឋានៈប្រទេសមានកម្រិតអភិវឌ្ឍន៍តិចតួច(LDCs) ក្រោមប្រព័ន្ធអនុគ្រោះ ពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ(EBA) សម្រាប់ទីផ្សារសហភាពអឺរ៉ុបនៅចុងឆ្នាំ២០០១។ លើសពីនេះ ការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក(WTO) នៅខែតុលា ឆ្នាំ២០០៤ បានធ្វើឱ្យផលិតផលកាត់ដេរ របស់កម្ពុជា រួចផុតពីការកំណត់កូតានានា បន្ទាប់ពីកិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌនិងសម្លៀកបំពាក់បានផុតរលត់ នៅឆ្នាំ២០០៥។

ដោយឡែក ក្នុងឆ្នាំ២០១៦ ប្រទេសកម្ពុជាក៏បានទទួលនូវប្រព័ន្ធអនុគ្រោះទូទៅ(GSP) សម្រាប់ផលិតផល សម្ភារៈសម្រាប់ធ្វើដំណើរ(ឬផលិតផលកាបូប) ដូចជា វ៉ាលីស កាបូបស្ពាយ កាបូបយួរដៃ និងកាបូបដាក់សម្ភារៈនានា ដែលត្រូវបាននាំចេញទៅសហរដ្ឋអាមេរិកដោយមិនចាំបាច់បង់ពន្ធ ដែលជួយគាំទ្រដល់វិស័យកាត់ដេរ ស្បែកជើង និងកាបូបរបស់កម្ពុជា មានការរីកចម្រើនកាន់តែខ្លាំងថែមទៀត។ ទោះជាយ៉ាងនេះក្តី ការទទួលបានប្រព័ន្ធអនុគ្រោះ ផ្នែកពាណិជ្ជកម្មទាំងនេះ កំពុងរងការគំរាមកំហែង ដោយសារតែការប្រែប្រួលនិម្មាបនកម្មតំបន់និងពិភពលោក ការសម្រេចព្យួរប្រព័ន្ធអនុគ្រោះពន្ធលើទំនិញមួយចំនួនក្រោមប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើក លែងអាវុធ(EBA) របស់សហភាពអឺរ៉ុប ឬតាមរយៈការរំពឹងទុកនៃការឈានទៅចាកចេញពីឋានៈប្រទេសមាន កម្រិតអភិវឌ្ឍន៍តិចតួច(LDCs) ក្នុងរយៈពេលខ្លី ខាងមុខ។

### ៤.២.៤ អនុលោមភាពផ្នែកសង្គមនិងគោលដៅផលិតកម្មប្រកបដោយក្រមសីលធម៌

ការអនុលោមទៅតាមបទប្បញ្ញត្តិការងារនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្ម រវាងកម្ពុជា និងសហរដ្ឋ អាមេរិក(១៩៩៩-២០០៤) បានក្លាយជាកត្តារួមចំណែកមួយ ដល់ការលើកកម្ពស់ឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជា

ដែលបានអនុញ្ញាតឱ្យកម្ពុជាកសាងកេរ្តិ៍ឈ្មោះរបស់ខ្លួន ជាទិសដៅផលិតកម្មប្រកបដោយក្រមសីលធម៌ ជាពិសេសតាមរយៈរបាយការណ៍វាយតម្លៃរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC)[6]។ អនុលោមភាពផ្នែកសង្គម ត្រូវបានអ្នកបញ្ជាទិញចាត់ទុកថាជាលក្ខណវិនិច្ឆ័យមួយសំខាន់ ដូចនឹងអនុលោមភាពផ្នែកបច្ចេកទេសនិងកត្តាតម្លៃផលិតកម្ម។ ប្រទេសកម្ពុជាបានកសាងកេរ្តិ៍ឈ្មោះជាគោលដៅផលិតកម្ម ដែលគោរពនូវបទដ្ឋានល្អនិងលក្ខខណ្ឌការងារនៅក្នុងឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូប តាមរយៈការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាផ្ទាល់ និងការចូលរួមរបស់ដៃគូអភិវឌ្ឍ រួមទាំងការអនុវត្តគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC) ក្នុងការកែលម្អលក្ខខណ្ឌការងារជូនកម្មករ និយោជិត។ ទន្ទឹមនេះ ការកើនឡើងនៃភាពល្អប្រសើរនៃកម្រិតអនុលោមភាពខ្ពស់របស់រោងចក្រនៅកម្ពុជាបានក្លាយជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់អ្នកបញ្ជាទិញ ហើយជាកត្តាសំខាន់មួយក្នុងដំណើរការសម្រេចចិត្តលើការបញ្ជាទិញពីកម្ពុជា ឬ/និងបន្តបញ្ជាទិញពីកម្ពុជា ជាពិសេសក្នុងអំឡុងពេលដែលវិស័យកាត់ដេររបស់កម្ពុជាបានជួបប្រទះបញ្ហាប្រឈមធំៗមួយចំនួនកន្លងមក។

### ៤.២.៥ យន្តការចរចាប្រាក់ឈ្នួលអប្បបរមា

ជាងពីរទសវត្សរ៍កន្លងមក កម្ពុជាបានរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីគ្រប់គ្រងនិងគាំទ្រដល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ជាបន្តបន្ទាប់។ ជាក់ស្តែង កម្ពុជាបានអនុវត្តច្បាប់ស្តីពីការងារដែលកំណត់ថាប្រាក់ឈ្នួលយ៉ាងតិចណាស់ ក៏ត្រូវស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា ហើយប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានានេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារ បន្ទាប់ពីមានការពិនិត្យលើយោបល់របស់គណៈកម្មការប្រឹក្សាការងារ ដែលមានតំណាងមកពីត្រីភាគី រួមមានភាគីរាជរដ្ឋាភិបាល ភាគីនិយោជក និងភាគីកម្មករ និយោជិត/ សហជីព។

យន្តការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ជាយន្តការគំរូមួយ ប្រកបដោយតម្លាភាព ការចូលរួម និងការយកចិត្តទុកដាក់ខ្ពស់លើទំនាក់ទំនងវិជ្ជាជីវៈនិងសុខុមាលភាពរបស់កម្មករ និយោជិត ក៏ដូចជាថ្លឹងថ្លែងពីចីរភាពវិស័យនេះផងដែរ។ ជាក់ស្តែង យន្តការនេះទទួលបានការគាំទ្រ និងទទួលស្គាល់ពីស្ថាប័នអន្តរជាតិធំៗ ជាពិសេស អង្គការពាក់ព័ន្ធនឹងវិស័យការងារនិងម្ចាស់ម៉ាកផលិតផលធំៗ ទូទាំងសកលលោក។ គួររំលឹកផងដែរថា កម្ពុជាបានបង្កើតឱ្យមានយន្តការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមាលើកដំបូងក្នុងឆ្នាំ២០០០ ដែលចាប់ផ្តើមចរចាលើប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យកាត់ដេរពី៤០ដុល្លារអាមេរិក/ខែ ក្នុងឆ្នាំ១៩៩៧ មក១៨២ដុល្លារអាមេរិក/ខែ ក្នុងឆ្នាំ២០១៩ និង១៩០ដុល្លារអាមេរិក/ខែ ក្នុងឆ្នាំ២០២០ ព្រមទាំងកំពុងអនុវត្តប្រាក់ឈ្នួល១៩២ដុល្លារអាមេរិក/ខែ សម្រាប់ឆ្នាំ២០២១។ ជារួម ការកំណត់ប្រាក់ឈ្នួលអប្បបរមា ជាយន្តការត្រីភាគី ដែលមានតំណាងមកពីស្ថាប័នរាជរដ្ឋាភិបាល តំណាងនិយោជក និងភាគីកម្មករ និយោជិត/ សហជីពចូលរួមក្នុងដំណើរការកំណត់អត្រាប្រាក់ឈ្នួលអប្បបរមា តាមពេលវេលាកំណត់។

---

[6] *គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC) បានចាប់ផ្តើមនៅឆ្នាំ១៩៩៩ ជាផ្នែកមួយនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងកម្ពុជា ហើយវាបានក្លាយជាកម្មវិធីទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន/សាជីវកម្ម(CSR) ដ៏សំខាន់មួយសម្រាប់វិស័យនេះមកទល់បច្ចុប្បន្ន។*

លើសពីនេះទៀត ក្នុងឆ្នាំ២០១៨ កម្ពុជាបានអនុម័តនិងដាក់ឱ្យអនុវត្តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមាតែម្តងឱ្យមានលក្ខណៈកាន់តែច្បាស់សម្រាប់វិស័យនេះ ដែលមានគោលបំណងលើកកម្ពស់ជីវភាពរស់នៅសមរម្យថ្លៃថ្នូរ បង្កើតឱកាសការងារ និងបង្កើនផលិតភាពរបស់កម្មករ និយោជិត និងជំរុញឱ្យមានបរិយាកាសវិនិយោគ និងធុរកិច្ចកាន់តែប្រសើរ ប្រកបដោយភាពទាក់ទាញ។ ច្បាប់នេះ បានធានាការកំណត់ប្រាក់ឈ្នួលអប្បបរមា បង្កើតនីតិវិធីកំណត់ប្រាក់ឈ្នួលអប្បបរមាតាមបែបវិទ្យាសាស្ត្រ ដោយផ្អែកលើលក្ខណវិនិច្ឆ័យបែបសង្គម(១-ស្ថានភាពគ្រួសារ ២-អត្រាអតិផរណា និង៣-ការចំណាយក្នុងការរស់នៅ) និងសេដ្ឋកិច្ច(១-ផលិតភាព ២-ភាពប្រកួតប្រជែងរបស់ប្រទេស ៣-ស្ថានភាពទីផ្សារការងារ និង៤-កម្រិតចំណេញរបស់វិស័យ) និងបង្កើតក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាដើម្បីជាយន្តការត្រីភាគី ហើយមានកាលវិភាគសម្រាប់ចរចា ដែលត្រូវប្រព្រឹត្តទៅក្នុងមួយឆ្នាំម្តង តាមការកំណត់និងជូនដំណឹងរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ៥. បញ្ហាប្រឈមនិងកាលានុវត្តភាព

### ក. បញ្ហាប្រឈម

ភាគច្រើននៃបញ្ហាប្រឈមនាពេលបច្ចុប្បន្ន ដែលវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជាកំពុងជួបប្រទះ បណ្តាលមកពីរចនាសម្ព័ន្ធនៃវិស័យនេះពុំទាន់ប្រែប្រួលនិងឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងតម្រូវការអភិវឌ្ឍន៍ និងបណ្តាលមកពីការធ្លាក់ចុះបណ្តើរៗនៃឧត្តមភាពប្រកួតប្រជែងរបស់វិស័យនេះនាពេលបច្ចុប្បន្ន។ កត្តាមួយចំនួនបានធ្វើឱ្យប៉ះពាល់ដល់ការធ្លាក់ចុះបណ្តើរៗនៃឧត្តមភាពប្រកួតប្រជែងរបស់វិស័យនេះ រួមមានការអភិវឌ្ឍជំនាញសម្រាប់កម្មករ និយោជិតក្នុងស្រុកនៅមានកម្រិត វិនិយោគលើឧស្សាហកម្មគាំទ្រដល់ខ្សែច្រវាក់ផ្គត់ផ្គង់ និងខ្សែច្រវាក់តម្លៃ និង/ឬការចាប់ដៃគូជាមួយនឹងសហគ្រិនក្នុងស្រុកនៅពុំទាន់បានគ្រប់គ្រាន់ឬតិចតួចនៅឡើយ ថ្លៃផលិតកម្មមានការកើនឡើងជាលំដាប់ រួមទាំង ប្រាក់ឈ្នួលប្រាក់អប្បបរមា និងការប្រកួតប្រជែងពីខាងក្រៅកាន់តែមានភាពខ្លាំងឡើង។ ក្នុងន័យនេះ ផ្នែកខាងក្រោមបញ្ជាក់អំពីបញ្ហាប្រឈមនិងកាលានុវត្តភាពសំខាន់ៗ ដែលក្នុងនោះមានការរំលេចនូវទិដ្ឋភាពផ្សេងៗ ដែលមានការផ្សារភ្ជាប់គ្នាទៅវិញទៅមក ដូចខាងក្រោម÷

### ៥.១. ភាពងាយរងឥទ្ធិពលពីការប្រែប្រួលនៃឧស្សាហកម្មកាត់ដេរសកល

ចំណែកនៃឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា មានទំហំប្រមាណ២% នៃការផ្គត់ផ្គង់សម្រាប់ទីផ្សារសកល។ ចំណែកផ្គត់ផ្គង់ក្នុងទំហំតូចនេះ បានធ្វើឱ្យឧស្សាហកម្មនេះមានលទ្ធភាពបង្កើនការផ្គត់ផ្គង់បន្ថែមទៀត ប៉ុន្តែក៏ងាយរងផលប៉ះពាល់ពីការប្រែប្រួលនៃឧស្សាហកម្មកាត់ដេរសកលនិងនិន្នាការសកលផ្សេងទៀតមួយចំនួន ជាពិសេស និន្នាការគាំពារនិយម សង្គ្រាមពាណិជ្ជកម្ម ឬក៏ហានិភ័យ និងផលប៉ះពាល់ណាមួយជាយថាហេតុ ដូចជាការបាត់បង់ប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្ម ដោយផ្នែកឬទាំងស្រុងជាយថាហេតុ។ ទន្ទឹមនេះ វិបត្តិជំងឺកូវីដ-១៩ ក៏បានជះឥទ្ធិពលធ្ងន់ធ្ងរជាងការរំពឹងទុកជាពិសេស បានបង្អាក់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់(Disruption to Supply Chains) បានផ្លាស់ប្តូរដំណើរការពាណិជ្ជកម្ម/អាជីវកម្មនៅក្នុងវិស័យកាត់ដេរសកលទាំងមូល(រួមមាន លំនាំនៃផលិតកម្ម ការបញ្ជាទិញ រយៈពេលផលិតកម្ម ការបញ្ជូនទំនិញទៅកាន់ទីផ្សារ និងការប្រែប្រួលនៃយុទ្ធសាស្ត្រ

ទីផ្សារ/ផែនការលក់ជាដើម) និងបានជំរុញល្បឿននៃនិន្នាការធំៗឱ្យមានសម្ទុះកាន់តែខ្លាំង មានអាទិ៍ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ ការផ្តោតសំខាន់កាន់តែខ្លាំងលើចីរភាពបរិស្ថាន(Environmental Sustainability) និងការលើកកម្ពស់កម្មវិធីទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន/សាជីវកម្ម (CSR)។

ដូចដែលបានបញ្ជាក់ខាងលើ រោងចក្រនៅកម្ពុជាប្រមាណ៧០%នៃរោងចក្រនាំចេញប្រមាណ៦០០ ជាប្រភេទរោងចក្រស៊ីអិមធី(CMT) ផលិតទំនិញមានថ្លៃងាយប្រែប្រួល មានតម្លៃបន្ថែមទាប និងមានកម្រិតប្រាក់ចំណេញតិចតួច ដែលធ្វើឱ្យរោងចក្រទាំងនេះងាយរងផលប៉ះពាល់ដោយកត្តាប្រែប្រួលខាងក្រៅ។ ជាក់ស្តែង ថ្លៃដែលរោងចក្រស៊ីអិមធី(CMT) ទទួលបានពីអ្នកបញ្ជាទិញសកល មានការប្រែប្រួលញឹកញាប់ ហើយក៏មាននិន្នាការធ្លាក់ចុះ ដែលបានដាក់សម្ពាធកាន់តែខ្លាំងលើថ្លៃផលិតកម្ម សម្រាប់រោងចក្រស៊ីអិមធី(CMT) នៅកម្ពុជា[7] ផងដែរ។ ករណីនេះទាមទារឱ្យកម្ពុជាត្រូវតែពង្រឹងវិស័យនេះនិងរត់តាមការវិវត្ត ក៏ដូចជានិន្នាការថ្មីៗ តាមរយៈការដាក់ចេញនូវវិធានការគោលនយោបាយនិងវិធានការអន្តរាគមន៍ ដើម្បីគាំទ្រដល់ការអភិវឌ្ឍនៃវិស័យនេះ។

### ៥.២. កំណើនផលិតភាពនៅមានកម្រិតនិងកង្វះកម្លាំងពលកម្មជំនាញក្នុងស្រុក

តួអង្គពាក់ព័ន្ធសំខាន់ៗក្នុងឧស្សាហកម្មនេះ ទទួលស្គាល់ថាកំណើនផលិតភាពមានការកើនឡើងជាលំដាប់ ប៉ុន្តែនៅមានកម្រិតទាបនៅឡើយ ដែលនេះជាបញ្ហាប្រឈមចម្បងមួយ និងដាក់កំហិតដល់លទ្ធភាពនៃឧស្សាហកម្មនេះក្នុងការផលិតនូវផលិតផលមានលក្ខណៈម៉ូដស្មុគស្មាញឬមានតម្លៃបន្ថែមខ្ពស់។ បញ្ហាផលិតភាពទាបអាចបណ្តាលមកពីកត្តាមួយចំនួន ជាអាទិ៍រួមមានការអប់រំទូទៅរបស់កម្មករ និយោជិតនៅមានកម្រិតទាប កង្វះវគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសនិងជំនាញបម្រើឱ្យវិស័យនេះ និងចំនួនថ្ងៃឈប់សម្រាកនៅមានចំនួនច្រើនជាងប្រទេសប្រកួតប្រជែងនឹងកម្ពុជា ដែលអាចបង្អាក់ដល់ផលិតកម្ម និងប៉ះពាល់ដល់កម្រិតផលិតភាព។ ជាក់ស្តែង ក្នុងឆ្នាំ២០១៧ ផលិតភាពកម្រិតរោងចក្រកម្ពុជាអាចឈានដល់ត្រឹមតែប្រមាណ៧០%នៃកម្រិតផលិតភាពរោងចក្រនៅក្នុងប្រទេសចិន និង៨០%នៃប្រទេសវៀតណាមតែប៉ុណ្ណោះ សម្រាប់ការផលិតនូវផលិតផលនិងម៉ូដដូចគ្នា[8]។ ទន្ទឹមនេះ បណ្តារោងចក្រនៅកម្ពុជាក៏ពុំទាន់បានវិនិយោគគ្រប់គ្រាន់ដល់ការបណ្តុះបណ្តាលសមត្ថភាពផ្នែកបច្ចេកទេសនិងជំនាញខ្ពស់នៅនឹងកន្លែងធ្វើការ ក្រៅពីជំនាញ ដូចជាដេរ កាត់ និងតម្រឹម/វេចខ្ចប់ ដែលជាជំនាញមូលដ្ឋានសម្រាប់កម្មករ និយោជិតនៃរោងចក្រស៊ីអិមធី(CMT)។ វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈឬជំនាញបច្ចេកទេសកម្រិតខ្ពស់ ជាអាទិ៍ដូចជាជំនាញវិស្វកម្មឧស្សាហកម្ម ការរចនាម៉ូដ ការគ្រប់គ្រងការបញ្ជាទិញវត្ថុធាតុដើម ឬការត្រួតពិនិត្យគុណភាព គឺពុំមានវគ្គបណ្តុះបណ្តាលគ្រប់គ្រាន់ឬមិនទាន់ឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្មបាននៅឡើយទេ។ ដូច្នេះ កម្លាំងពលកម្មភាគច្រើនខ្វះខាតជំនាញ ដែលពុំអាចឱ្យពួកគាត់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញការងារកម្រិតបច្ចេកទេសខ្ពស់ ឬជំនាញគ្រប់គ្រងថ្នាក់កណ្តាលបាន។ ជាក់ស្តែង ប្រមាណជាង៧០%នៃអ្នកត្រួតពិនិត្យឬបុគ្គលិកដែលមានឋានៈជាអ្នកគ្រប់គ្រងថ្នាក់កណ្តាល គឺជាជនជាតិបរទេស ដែលភាគច្រើនមានសញ្ជាតិដូចទៅនឹងម្ចាស់រោងចក្រ និងរោងចក្រជាង៥០%នៃរោងចក្រទាំងអស់បានជួលជនជាតិបរទេសប្រមាណជាង៩០% ដើម្បីបំពេញតួនាទីជាអ្នកត្រួតពិនិត្យផងដែរ[9]។

---

[7] *យោងតាមការស្រាវជ្រាវរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC)*

[8] *យោងតាមការសិក្សាស្រាវជ្រាវស្តីពីភាពប្រកួតប្រជែង នៃឧស្សាហកម្មកាត់ដេរដោយគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC)*

[9] *យោងតាមការស្ទង់មតិជាមួយវិនិយោគិននិងអ្នកគ្រប់គ្រងរោងចក្រនៅកម្ពុជា*

## ៥.៣. លក្ខខណ្ឌការងារនិងសុខុមាលភាពរបស់កម្មករ និយោជិត

ជាមធ្យម កម្មករ និយោជិតចំណាយដោយសន្សំសំចៃលើអាហារូបត្ថម្ភ ហើយរោងចក្រមួយចំនួនក៏ពុំបានរៀបចំជាកន្លែងអាហារដ្ឋានបានសមរម្យនៅឡើយទេ ដើម្បីឱ្យកម្មករ និយោជិតអង្គុយបរិភោគបានត្រឹមត្រូវនោះទេ[10]។ ជាងនេះទៅទៀត កម្មករ និយោជិតមួយចំនួនត្រូវធ្វើដំណើរដោយឈរលើរថយន្តកែច្នៃ(អាចមានឬគ្មានដំបូល) ក្នុងចម្ងាយឆ្ងាយពីផ្ទះមកកន្លែងធ្វើការ និងងាយប្រឈមនឹងគ្រោះថ្នាក់ចរាចរណ៍។ របាយការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC) ក៏បានបង្ហាញថាប្រមាណជា៧០% នៃរោងចក្រសរុបមានកម្តៅខ្លាំងនៅផ្នែកមួយចំនួននៃកន្លែងធ្វើការនៅក្នុងរោងចក្រ ដែលលក្ខខណ្ឌការងារនេះអាចចូលរួមចំណែកប៉ះពាល់ដល់សុខុមាលភាពរបស់កម្មករ និយោជិត។ ទន្ទឹមនេះ ព័ត៌មានអំពីលក្ខខណ្ឌការងារ និងអនុលោមភាពជាមួយនឹងច្បាប់និងបទប្បញ្ញត្តិជាធរមាន នៅតាមរោងចក្រ សហគ្រាសម៉ៅការបន្តមួយចំនួន ក៏នៅមានកម្រិតនៅឡើយ។ ដូចនេះ ការអនុវត្តឱ្យបានកាន់តែតឹងរ៉ឹងជាងមុន លើការត្រួតពិនិត្យផ្នែកលក្ខខណ្ឌការងារ រួមទាំងសុខភាពនិងសុវត្ថិភាពការងារ(Occupational Safety and Health - OSH) ជាពិសេសនៅតាមរោងចក្រសហគ្រាសម៉ៅការបន្ត ជាការងារមួយសំខាន់ ដែលទាមទារឱ្យមានការពង្រឹងបន្ថែម ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវលក្ខខណ្ឌការងារនិងសុខុមាលភាពជូនកម្មករ និយោជិត និងចូលរួមចំណែកដល់ការលើកកម្ពស់ភាពប៉ាន់ប្រមាណបាននិងស្ថិរភាពនៃវិស័យនេះផងដែរ។

## ៥.៤. ទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប

ភាពមិនទាន់ចាស់ទុំនៃទំនាក់ទំនងវិជ្ជាជីវៈ ក៏ជាបញ្ហាប្រឈមមួយក្នុងវិស័យនេះ ដែលបានបង្អាក់ដំណើរការច្រវាក់ផលិតកម្មរបស់សហគ្រាស គ្រឹះស្ថាន និងបង្កជាវិវាទការងាររវាងកម្មករ និយោជិត និងនិយោជក។ ក្របខ័ណ្ឌគតិយុត្តនិងប្រសិទ្ធភាពនៃក្នុងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការដោះស្រាយវិវាទការងារនៅមានកម្រិត។ កំណើនឡើងយ៉ាងច្រើននៃចំនួនអង្គការវិជ្ជាជីវៈប្រមាណ៥ ០០០ និងការបន្តខ្វះភាពចាស់ទុំនិងក្រមសីលធម៌នៃអង្គការវិជ្ជាជីវៈក្នុងការដោះស្រាយវិវាទការងារនិងការចរចាផ្សេងៗ គឺជាហានិភ័យផ្នែកកេរ្តិ៍ឈ្មោះដល់បណ្តាម្ចាស់ម៉ាកផលិតផលនិងវិនិយោគដែលបញ្ជាទិញពីកម្ពុជា ដែលអាចប៉ះពាល់ដល់ភាពប៉ាន់ប្រមាណបាននិងស្ថិរភាពនៃវិស័យនេះ។ ជារួមយន្តការនៃការដោះស្រាយវិវាទការងារនៅកម្ពុជា ចែកជាដំណាក់កាល ពោលគឺ១-ការផ្សះផ្សាវិវាទដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅប្រឈមនឹងកង្វះខាតមន្ត្រីនិងកិច្ចសហការពីភាគីវិវាទ ២-ក្នុងករណីមិនសះជាក្នុងកម្រិតមន្ត្រីផ្សះផ្សា វិវាទទាំងនោះត្រូវបាននាំមកក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីចាត់ការបន្ត ៣-បើមានភាគីណាមួយមិនអនុវត្តតាមឬបដិសេធ សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីម្ខាងទៀតអាចអនុវត្តវិធានការវិវាទ(Industrial Action) ដូចជាកូដកម្ម ឬឡុកអៅ (Lockout) និង៤-ក្នុងអំឡុងពេលឬក្រោយពេលអនុវត្តវិធានការវិវាទ ភាគីណាមួយអាចប្តឹងទៅតុលាការ ដើម្បីបញ្ជាក់គុណវុឌ្ឍិនៃវិធានការវិវាទនេះឬដើម្បីដោះស្រាយបញ្ចប់ដែលជានីតិវិធីចុងក្រោយ។ ទោះជាយ៉ាងណាក៏ដោយ ជារឿយៗវិវាទការងារទាំងនោះ អាចបង្កជាកូដកម្មនិងបាតុកម្មខុសនីតិវិធីច្បាប់ ដែលធ្វើឱ្យមានការខាតបង់ទាំងភាគីកម្មករ និយោជិត និងភាគីនិយោជកដោយសារការរាំងស្ទះដល់ច្រវាក់ផលិតកម្ម។

---

10 *ផ្អែកលើការសម្ភាសន៍និងការពិគ្រោះយោបល់ជាមួយកម្មករ និយោជិត និងអ្នកគ្រប់គ្រងរោងចក្រ*

### ៥.៥. ភាពជាម្ចាស់និងតម្លៃបន្ថែមទាប

ចំនួនម្ចាស់រោងចក្រក្នុងស្រុកមានចំនួនតិចប្រមាណតែ៥% ខណៈដែលប្រមាណ៩០-៩៥% នៅតែជាការវិនិយោគពីបរទេស ដែលស្ថានភាពនេះធ្វើឱ្យកម្ពុជាងាយរងហានិភ័យនៃការដកចេញយ៉ាងឆាប់រហ័សពីកម្ពុជាទៅកាន់គោលដៅវិនិយោគផ្សេងមានឧត្តមភាពប្រកួតប្រជែងថ្លៃផលិតកម្ម និងមានរបបលើកទឹកចិត្តវិនិយោគប្រសើរជាងកម្ពុជា។ ជាការកត់សម្គាល់ ប្រទេសមួយចំនួនដូចជាប្រទេសថៃ វៀតណាម បង់ក្លាដែស និងស្រីលង្កា ជាប្រទេសដែលបានបង្កើនចំនួនម្ចាស់រោងចក្រក្នុងស្រុក និងភាពជាម្ចាស់គ្រប់គ្រងលើវិស័យកាត់ដេររបស់ខ្លួនបានក្នុងកម្រិតមួយប្រសើរជាងនៅកម្ពុជា។ ទន្ទឹមនេះ កម្រិតការវិនិយោគពីបរទេសខ្ពស់បែបនេះនៅកម្ពុជា និងភាគច្រើនជាលក្ខណៈម៉ូដែលផលិតកម្មស៊ីអិមធី(CMT) បានធ្វើឱ្យតម្លៃបន្ថែមត្រូវបានបង្កើតនិងរក្សាទុកនៅក្រៅប្រទេសដោយក្រុមហ៊ុនមេ ឬស្នាក់ការកណ្តាល ដែលជាអ្នកបែងចែកការបញ្ជាទិញទៅដល់បណ្តារោងចក្រស៊ីអិមធី(CMT)។ ជាក់ស្តែង យោងតាមការប៉ាន់ស្មានរបស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) កម្ពុជាទទួលបានតម្លៃនាំចេញត្រឹមតែប្រមាណ១០%ប៉ុណ្ណោះ តាមរយៈការបញ្ជាទិញផ្ទាល់ពីអ្នកបញ្ជាទិញនៅកម្រិតរោងចក្រ ចំណែកប្រមាណ៩០%ទៀត តាមរយៈក្រុមហ៊ុនភ្នាក់ងារ/អ្នកផលិតនៅបរទេស ដែលអាចជះឥទ្ធិពលលើដំណើរការពាណិជ្ជកម្ម/អាជីវកម្មនៅក្នុងវិស័យនេះ ដ្បិតប៉ុន្មានឆ្នាំកន្លងមានការប្រែប្រួលតិចតួចមកត្រឹមកម្រិត៨០%នៃការបញ្ជាទិញត្រូវបានធ្វើឡើងតាមរយៈភ្នាក់ងារ ចំណែកប្រមាណ៧០%នៃការបញ្ជាទិញធ្វើឡើងតាមរយៈអ្នកផលិតដោយផ្ទាល់។

### ៥.៦. ឧស្សាហកម្មគាំទ្រនិងឧបសគ្គបរិយាកាសធុរកិច្ច

វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជាស្ទើរតែពុំមានឬមានតិចតួចនូវឧស្សាហកម្មគាំទ្រ(ឬប្រមាណក្រោម១០%ប៉ុណ្ណោះ) ដែលបានធ្វើសមាហរណកម្មចូលទៅក្នុងបណ្តាញផ្គត់ផ្គង់នៅក្នុងទម្រង់ជារោងចក្រសហគ្រាសផលិតកំណាត់ វាយនភណ្ឌគាំទ្រផ្សេងទៀត និងផលិតផលបន្ទាប់បន្សំជាដើម។ ក្នុងន័យនេះ រោងចក្រសហគ្រាសត្រូវពឹងផ្អែកលើការនាំចូលវត្ថុធាតុដើមមួយភាគធំឬទាំងស្រុង ដើម្បីបម្រើឱ្យផលិតកម្មរបស់ខ្លួន ដែលនេះជាហានិភ័យមួយអាចប៉ះពាល់ដល់រោងចក្រ សហគ្រាសនៅកម្ពុជាផ្ទាល់តែម្តង ជាពិសេសការខ្វះខាតវត្ថុធាតុដើមនៅពេលមានការបង្អាក់ណាមួយដល់ច្រវាក់ផលិតកម្មនៅក្នុងប្រទេសផ្គត់ផ្គង់ ក្នុងអំឡុងពេលនៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ជាដើម។ ក្នុងទិដ្ឋភាពប្រកួតប្រជែង កម្ពុជាពឹងផ្អែកមួយភាគធំឬស្ទើរទាំងស្រុង លើការនាំចូលវត្ថុធាតុដើមពីប្រទេសនានា ដែលធ្វើឱ្យរោងចក្រនៅកម្ពុជាត្រូវការចំណាយពេលលើផលិតកម្ម ការបញ្ជូនទំនិញ និងល្បឿននៃការបញ្ជូនទំនិញទៅកាន់ទីផ្សារ យូរជាងប្រទេសគូប្រកួតប្រជែង ដូចជាប្រទេសវៀតណាម ឬបង់ក្លាដែស ដែលមានឧស្សាហកម្មគាំទ្រក្នុងស្រុក។ ជាក់ស្តែង កម្ពុជាជាប្រទេសមានរយៈពេលបញ្ជូនទំនិញយូរជាងគេមួយនៅក្នុងតំបន់ដែលត្រូវការពេលវេលាប្រហែល២១ទៅ២៨ថ្ងៃ ដើម្បីទទួលវត្ថុធាតុដើមជាឧទាហរណ៍ពីប្រទេសចិន។

### ដ្យាក្រាមទី៦. តម្លៃនាំចូលវត្ថុធាតុដើម ២០០៨-២០២០(គិតជាលានដុល្លារអាមេរិក)




| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ផលិតផលវាយនភណ្ឌផ្សេងៗ | 2.0 | 1.5 | 27.0 | 1.5 | 3.0 | 11.5 | 53.6 | 104.9 | 310.4 | 353.8 | 405.5 | 479.4 | 448.6 |
| កំណាត់ | 1,128.5 | 1,084.8 | 1,454.1 | 1,765.2 | 2,173.2 | 2,601.2 | 2,747.0 | 3,167.8 | 3,621.2 | 3,916.9 | 4,422.4 | 4,506.8 | 3,902.3 |
| តម្លៃនាំចូលផលិតផលវាយនភណ្ឌសរុប | 1,130.5 | 1,086.3 | 1,481.1 | 1,766.7 | 2,176.3 | 2,612.7 | 2,800.6 | 3,272.7 | 3,931.6 | 4,270.7 | 4,827.9 | 4,986.2 | 4,350.9 |
| តម្លៃនាំចូលសរុប | 4,451.2 | 4,322.0 | 5,230.0 | 6,237.1 | 7,418.6 | 8,762.0 | 10,308.2 | 11,627.8 | 12,243.4 | 14,223.8 | 17,264.2 | 20,170.8 | 18,938.2 |
| %ក្រណាត់នៃតម្លៃនាំចូលផលិតផលវាយនភណ្ឌសរុប | 99.83% | 99.86% | 98.18% | 99.92% | 99.86% | 99.56% | 98.09% | 96.79% | 92.11% | 91.72% | 91.60% | 90.39% | 89.69% |
| %តម្លៃនាំចូលផលិតផលវាយនភណ្ឌសរុបនៃតម្លៃនាំចូលសរុប | 25.40% | 25.13% | 28.32% | 28.33% | 29.34% | 29.82% | 27.17% | 28.15% | 32.11% | 30.03% | 27.96% | 24.72% | 22.97% |

*ប្រភព: អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

ជាមធ្យម កម្ពុជាត្រូវការចំនួន៨៧ថ្ងៃឬជិត៣ខែ សម្រាប់ការបញ្ជូនទំនិញទៅទីផ្សារ ដែលរយៈពេលនេះត្រូវបានបែងចែកជាសកម្មភាព៣ធំៗ÷ ២៨ថ្ងៃសម្រាប់ទទួលការផ្គត់ផ្គង់វត្ថុធាតុដើម ៣១ថ្ងៃសម្រាប់ដំណើរការផលិតកម្ម និង២៧ថ្ងៃសម្រាប់ដឹកជញ្ជូនទៅកាន់ទីផ្សារ។ ទន្ទឹមនេះ ការទាក់ទាញការវិនិយោគលើផលិតកម្មកំណាត់ជាការងារលំបាក ដោយសារតែរចនាសម្ព័ន្ធស្មុគស្មាញនៃបណ្តាញផ្គត់ផ្គង់កំណាត់តំបន់និងសកល ទំហំតម្រូវការតូចសម្រាប់វិស័យនេះនៅកម្ពុជា និងកត្តាលក្ខខណ្ឌវិនិយោគមួយចំនួនផ្សេងៗ ដូចជាតម្រូវការប្រើប្រាស់ថាមពលអគ្គិសនីច្រើន កង្វះកម្លាំងពលករជំនាញក្នុងស្រុក កង្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងបញ្ហានិយតកម្មផ្សេងទៀត។ បើទោះបីជាចំណាយលើថ្លៃអគ្គិសនីគ្រាន់តែជាសមាសធាតុតូចមួយ ត្រឹមតែប្រមាណ២%ទៅ៣%នៃចំណាយផលិតកម្មក្នុងស្រុកទាំងមូលសម្រាប់រោងចក្រស៊ីអិមធី(CMT) វាជាឧបសគ្គមួយចំពោះការវិនិយោគនៅក្នុងរោងចក្រផលិតកំណាត់និងផលិតផលបន្ទាប់បន្សំ ដោយសាររោងចក្រទាំងនេះមានចរិតជាឧស្សាហកម្មប្រើប្រាស់គ្រឿងម៉ាស៊ីនច្រើន ដែលត្រូវការបរិមាណអគ្គិសនីច្រើននិងស្ថិរភាពនៃការផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់ ដើម្បីធានាស្ថិរភាពផលិតកម្មនិងសមត្ថភាពប្រកួតប្រជែងរបស់រោងចក្រទាំងនោះ។

## ៥.៧. ពិពិធកម្មទីផ្សារនាំចេញនិងការពឹងផ្អែកខ្លាំងលើប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

បច្ចុប្បន្ន ការនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងកាបូបរបស់កម្ពុជាត្រូវបានប្រមូលផ្តុំទៅកាន់គោលដៅទីផ្សារ៦ រួមមានសហភាពអឺរ៉ុប សហរដ្ឋអាមេរិក កាណាដា ជប៉ុន អាស៊ាន និងទីផ្សារផ្សេងៗទៀត ដែលក្នុងនោះចំណែក នៃទីផ្សាររបស់សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ជាមធ្យមស្មើនឹងប្រមាណ៧០-៨០%នៃចំណែកទីផ្សារផលិតផលកាត់ដេរសរុបរបស់កម្ពុជា។ ជាកត្តាសត្យានុម័ត ការនាំចេញទៅកាន់ទីផ្សារធំទាំងពីរនេះបានជួយជំរុញកំណើននៃវិស័យនេះ ប៉ុន្តែការពឹងផ្អែកខ្លាំងលើប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្មនិងពិពិធកម្មទីផ្សារនាំចេញនៅពុំទាន់មានភាពទូលំទូលាយ អាចធ្វើឱ្យកម្ពុជាប្រឈមនឹងហានិភ័យនៃការប្រែប្រួលមួយចំនួន ដូចជាការព្យួរប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ(EBA)របស់សហភាពអឺរ៉ុប និងភាពមិនច្បាស់លាស់ឬ

លទ្ធភាពបាត់បង់ជាយថាហេតុនៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP) របស់សហរដ្ឋអាមេរិកលើផលិតផលធ្វើដំណើរ ដោយសារការវិវត្តឈានឡើងនៃសេដ្ឋកិច្ចកម្ពុជា និងការឈានទៅចាកចេញពីឋានៈប្រទេសមានកម្រិតអភិវឌ្ឍន៍តិចតួច(LDCs) នៅក្នុងរយៈពេលខាងមុខ។

ទោះបីជាលទ្ធភាពនៃការកាត់បន្ថយឬការបាត់បង់ប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្មរបស់កម្ពុជា អាចជាឥទ្ធិពលនៃកត្តាខាងក្រៅមួយ ក្នុងបរិបទនៃការប្រែប្រួលនិម្មាបនកម្មពាណិជ្ជកម្មអន្តរជាតិក្តី ក៏បទពិសោធន៍នេះបានឆ្លុះបញ្ចាំងថា កម្ពុជាត្រូវតែគិតគូរឱ្យបានវែងឆ្ងាយប្រកបដោយភាពបុរេសកម្មនិងសកម្ម ដើម្បីបន្តលើកកម្ពស់ការអភិវឌ្ឍវិស័យនេះ ព្រមទាំងត្រៀមខ្លួនសម្រាប់រាល់ផលប៉ះពាល់/ហានិភ័យ ដែលអាចកើតចេញពីកត្តាខាងក្រៅ ការប្រែប្រួលនៃនិន្នាការតំបន់និងពិភពលោកនិងមានលទ្ធភាពអាចចាត់វិធានការឱ្យសមស្រប ដើម្បីបន្តពង្រឹងសមត្ថភាពប្រកួតប្រជែងនិងជំរុញការធ្វើពិពិធកម្មទីផ្សារនាំចេញ។

### ៥.៨. បញ្ហាប្រឈមថ្មីៗដែលបង្កឡើងដោយវិបត្តិជំងឺកូវីដ-១៩

វិបត្តិជំងឺកូវីដ-១៩ បានបង្កការលំបាកធ្ងន់ធ្ងរដល់វិស័យកាត់ដេរនៅកម្ពុជា។ រោងចក្រជាច្រើន បានស្នើសុំផ្អាកដំណើរការផលិតកម្ម មានការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតរាប់ម៉ឺននាក់ និងមានការបិទជាស្ថាពរសម្រាប់រោងចក្រមួយចំនួន។ លើសពីនេះទៀត ជំងឺនេះបានបង្កជាបញ្ហាប្រឈមថ្មីៗ រួមមានការបង្អាក់ខ្សែច្រវាក់ផ្គត់ផ្គង់ និងការផ្លាស់ប្តូរដំណើរការពាណិជ្ជកម្ម/អាជីវកម្មនៅក្នុងវិស័យកាត់ដេរសកលទាំងមូល ដូចជាការផ្លាស់ប្តូរនៃលំនាំសកម្មភាពផលិតកម្ម ការបញ្ជាទិញពីបរិមាណច្រើនមកបរិមាណតិចនិងតាមតម្រូវការ(Shift to Small and Customized Orders) ល្បឿនបញ្ជូនទំនិញទៅកាន់ទីផ្សារ(Lead Time & Speed to Market) រយៈពេលកាន់តែខ្លីនៃតម្រូវការម៉ូដពេញនិយម(Fast Fashion) និងការបិទហាងសម្លៀកបំពាក់រូបវន្តមួយចំនួនរបស់ម្ចាស់ម៉ាកផលិតផលធំៗមួយចំនួននិងការជំរុញការលក់តាមពាណិជ្ជកម្មអេឡិចត្រូនិក(Closure of Physical Stores and Shift to E-Commerce)។ ទន្ទឹមនេះ វិបត្តិនេះបានជំរុញល្បឿននៃនិន្នាការធំៗ ដូចជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ ការផ្តោតសំខាន់កាន់តែខ្លាំងលើចីរភាពផ្នែកបរិស្ថាន រួមមានការប្រើប្រាស់ថាមពលកកើតឡើងក្នុងដំណើរការផលិតកម្ម ព្រមទាំងការលើកកម្ពស់កម្មវិធីទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន/សាជីវកម្ម(CSR) ដែលអាចដាក់សម្ពាធផ្នែកថ្លៃផលិតកម្មនិងភាពប្រកួតប្រជែង។

### ៥.៩. កិច្ចសម្របសម្រួលអន្តរស្ថាប័ន

កិច្ចសម្របសម្រួលអន្តរស្ថាប័ន ជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់វិស័យនេះ។ ក្រសួង ស្ថាប័នពាក់ព័ន្ធសំខាន់ៗ បានដើរតួនាទីនិងមានការទទួលខុសត្រូវផ្សេងៗគ្នាទាក់ទងនឹងវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប រួមមាន ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ការអនុវត្តវិធានការ និងការដោះស្រាយបញ្ហាប្រឈមនៅក្នុងវិស័យនេះនៅមិនទាន់មានប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពពេញលេញនៅឡើយ ដោយសារតែការងារនិងការទទួលខុសត្រូវបានធ្វើឡើងដោយពុំទាន់មានសុខដុមនីយកម្ម និងកិច្ចសម្របសម្រួលអន្តរស្ថាប័ននៅតែជាកិច្ចការដែលត្រូវពង្រឹងបន្ថែម។ កត្តានេះ

បានដាក់កំហិតលើសមត្ថភាពរបស់ក្រសួង ស្ថាប័ន ក្នុងការដោះស្រាយបញ្ហាកង្វល់រួមឬបញ្ហាប្រឈមក្នុងវិស័យនេះ ដែលរាជរដ្ឋាភិបាលកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមដោះស្រាយវិវាទឬការខ្វែងគំនិតណាមួយនៅក្នុងទំនាក់ទំនងវិជ្ជាជីវៈនានា ព្រមទាំងគ្រប់គ្រងការអភិវឌ្ឍវិស័យនេះ។ ទន្ទឹមនេះ កម្ពុជាក៏ពុំមានយន្តការអន្តរ-ស្ថាប័នជាក់លាក់មួយ គាំទ្រដល់វិស័យនេះបានពេញលេញ ដែលធ្វើឱ្យមានការលំបាកក្នុងការរៀបចំ និងអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រនានា ដើម្បីគ្រប់គ្រងនិងបម្រើឱ្យវិស័យនេះបានកាន់តែប្រសើរនិងមានប្រសិទ្ធភាពខ្ពស់ជាងមុន។

ជារួម ថ្វីបើវិស័យនេះត្រូវបានអភិវឌ្ឍខ្លួនជាបន្តបន្ទាប់ ដោយផ្អែកលើចំណុចខ្លាំងដែលជាឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជា ដូចដែលបានបញ្ជាក់ខាងលើ វិស័យនេះបានជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម÷

- កង្វះពលកម្មជំនាញក្នុងស្រុក ទាំងគុណភាពនិងបរិមាណ និងគន្លងអាជីព(Career Path) សម្រាប់កម្មករនិយោជិត
- កង្វះភាពប៉ាន់ប្រមាណបាននិងស្ថិរភាពដែលបណ្តាលមកពីបញ្ហាលក្ខខណ្ឌការងារនិងសុខុមាលភាពកម្មករនិយោជិតដែលកន្លងមកមានភាពល្អប្រសើរ ប៉ុន្តែនៅមានកម្រិតនៅឡើយ
- កង្វះផលិតកម្មតម្លៃបន្ថែមខ្ពស់និងចំនួនម្ចាស់រោងចក្រឬអ្នកវិនិយោគក្នុងស្រុកនៅមានកម្រិតទាបនៅឡើយ
- កង្វះឧស្សាហកម្មគាំទ្រនៅក្នុងវិស័យនេះនិងបរិយាកាសធុរកិច្ចនៅមានកម្រិត
- ពិពិធកម្មទីផ្សារនៅមានកម្រិតនិងការពឹងផ្អែកខ្លាំងលើប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្ម និង
- កង្វះកិច្ចសម្របសម្រួលអន្តរស្ថាប័ន ក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗជាដើម។

បន្ថែមលើចំណុចខាងលើនេះ វិស័យនេះក៏ស្ថិតក្រោមឥទ្ធិពលនៃការប្រែប្រួលនិងការវិវត្តថ្មីៗ ដែលបណ្តាលមកពីកត្តាខាងក្នុងនិងខាងក្រៅមានជាអាទិ៍÷

- សក្តានុពលនៃការកែប្រែប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្មពីដៃគូពាណិជ្ជកម្មសំខាន់ៗសម្រាប់កម្ពុជា តាមរយៈការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចកម្ពុជាចាកចេញពីឋានៈប្រទេសមានកម្រិតអភិវឌ្ឍន៍តិចតួច(LDCs) នាពេលខាងមុខ ឬហេតុផលផ្សេងទៀត ដូចយ៉ាងការសម្រេចព្យួរភាពអនុគ្រោះពន្ធលើទំនិញមួយចំនួនក្រោមប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ(EBA) ចំពោះកម្ពុជានាពេលកន្លងមក
- ការទទួលខុសត្រូវផ្នែកកិច្ចគាំពារបរិស្ថានឬចីរភាពបរិស្ថាន នៅក្នុងឧស្សាហកម្មកាត់ដេរកាន់តែមាននិន្នាការកើនឡើងជាលំដាប់ ជាពិសេស ក្នុងចំណោមម្ចាស់ម៉ាកផលិតផលនិងអ្នកបញ្ជាទិញធំៗ ដែលបានចាប់ផ្តើមអនុវត្តកម្មវិធីកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គិសនីដែលប៉ះពាល់ដល់បរិស្ថានដោយលើកទឹកចិត្តឱ្យរោងចក្រឬអ្នកផលិតពាក់ព័ន្ធក្នុងវិស័យនេះប្រើប្រាស់ថាមពលកកើតឡើងវិញ
- ការផ្លាស់ប្តូរនៅក្នុងវិស័យនេះ តាមរយៈស្វ័យប្រវត្តិកម្មលើការរចនានិងដំណើរការផលិតកម្មចំពោះផលិតផលកាត់ដេរ ដែលមានលក្ខណៈសាមញ្ញមួយចំនួននៅក្នុងរយៈពេលមធ្យម/វែង និងល្បឿននៃការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មទី៤ កាន់តែមានសម្ទុះខ្លាំងឡើងក្នុងដំណើរការផលិតកម្មនិងខ្សែច្រវាក់ផ្គត់ផ្គង់

- ការប្រកួតប្រជែងកាន់តែកើនឡើងរវាងប្រទេសកម្ពុជាជាមួយប្រទេសវៀតណាម មីយ៉ាន់ម៉ា បង់ក្លាដែស និងប្រទេសមួយចំនួននៃទ្វីបអាហ្វ្រិកដែលកំពុងទាក់ទាញការវិនិយោគ និង
- ការផ្លាស់ប្តូរបរិយាកាសពាណិជ្ជកម្ម ជាពិសេសលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី(FTA) រវាងប្រទេសដែលប្រកួតប្រជែងជាមួយកម្ពុជា ដូចជា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងប្រទេសវៀតណាម និងសហភាពអឺរ៉ុបជាដើម។

## ខ. កាលានុវត្តភាព

ឈរលើមូលដ្ឋាននៃបញ្ហាប្រឈមនិងការវិវត្តខាងលើ រាជរដ្ឋាភិបាលនឹងអភិវឌ្ឍវិស័យកាត់ដេរ ផលិត-ស្បែកជើង និងកាបូប ឱ្យទៅជាឧស្សាហកម្មមានចីរភាពបរិស្ថាន មានភាពធន់ មានតម្លៃបន្ថែមខ្ពស់ និងផ្តោតលើផលិតផលថ្លៃខ្ពស់និងមានលក្ខណៈពិសេស មានមូលដ្ឋានគាំទ្រពិពិធកម្ម និងមានភាពប្រកួតប្រជែង ដោយឈរលើមូលដ្ឋាននៃកាលានុវត្តភាពមួយចំនួន រួមមាន៖

- ការប្តេជ្ញាចិត្តនិងចាត់ទុកឧស្សាហកម្មនេះ ជាវិស័យអាទិភាពសម្រាប់ការអភិវឌ្ឍ
- ការរៀបចំនិងអនុវត្តយ៉ាងសកម្ម និងប្រទាក់ក្រឡានូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំខាន់ៗ ជាអាទិ៍រួមមាន**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០១៩-២០២៣ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣** ដើម្បីឈានទៅសម្រេចបាននូវប្រទេសមានឋានៈចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០និងចំណូលខ្ពស់នៅឆ្នាំ២០៥០ ព្រមទាំងតាមរយៈការដាក់ឱ្យអនុវត្តកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងនិងពិពិធកម្មសេដ្ឋកិច្ច
- ការបន្តពង្រឹងឱ្យកាន់តែប្រសើរនូវឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជា ដែលរួមមានការគិតគូរលើការកើនឡើងនៃថ្លៃកម្លាំងពលកម្មនិងផលិតកម្មឱ្យនៅកម្រិតមួយសមស្រប ការបន្តផ្តល់នូវរបបការលើកទឹកចិត្តវិនិយោគអំណោយផល ការបន្តលើកកម្ពស់កេរ្តិ៍ឈ្មោះជាគោលដៅផលិតកម្ម ប្រកបដោយអនុលោមភាពផ្នែកសង្គម ក្រមសីលធម៌ និងចីរភាពបរិស្ថាន ការរក្សាទំនាក់ទំនងពាណិជ្ជកម្មជាច្រើនឆ្នាំជាមួយអ្នកបញ្ជាទិញនិងម្ចាស់ម៉ាកផលិតផល ការចរចាចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការប្រឹងប្រែងរក្សាឱ្យអស់លទ្ធភាពនូវប្រព័ន្ធអនុគ្រោះខាងពាណិជ្ជកម្មដែលកម្ពុជាកំពុងទទួលបាន
- ការកើនឡើងថ្លៃផលិតកម្មនៅក្នុងប្រទេសចិន ដែលអាចជំរុញឱ្យមានការផ្លាស់ប្តូរទីតាំងរោងចក្រ ទាំងរោងចក្រប្រភេទកាត់ដេរ និងបម្រើឱ្យឧស្សាហកម្មគាំទ្រមកប្រទេសក្នុងតំបន់ រួមទាំងកម្ពុជា ក្នុងគោលបំណងធ្វើពិពិធកម្មខ្សែច្រវាក់ផ្គត់ផ្គង់របស់ខ្លួនផង និងទទួលបានអត្ថប្រយោជន៍ពីថ្លៃកម្លាំងពលកម្មនិងផលិតកម្មប្រកួតប្រជែង និងឧត្តមភាពប្រកួតប្រជែងផ្សេងៗទៀតរបស់វិស័យនេះនៅកម្ពុជា

- ការរំពឹងទុកនៃការពង្រីកទីផ្សារចិននិងកូរ៉េសម្រាប់ផលិតផលកាត់ដេររបស់កម្ពុជា បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីរវាងកម្ពុជានិងចិន និងរវាងកម្ពុជានិងកូរ៉េ
- ការរំពឹងទុកនៃការពង្រីកទីផ្សារតំបន់ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់(RCEP)
- ការបន្តគាំទ្រពីដៃគូអភិវឌ្ឍដែលពាក់ព័ន្ធ ដើម្បីអភិវឌ្ឍវិស័យនេះបន្ថែមទៀត
- ការងើបឡើងវិញនៃកំណើនតម្រូវការនៃផលិតផលកាត់ដេរសកល បន្ទាប់ពីផលប៉ះពាល់នៃបញ្ហាមួយចំនួនរួមទាំងបញ្ហាជំងឺកូវីដ-១៩ ត្រូវបានថមថយ។

## ៦. វិធានការជាយុទ្ធសាស្ត្រ

ផ្នែកវិធានការជាយុទ្ធសាស្ត្រ ត្រូវបានបែងចែកជា៣ផ្នែក គឺវិធានការមុតស្រួចរបស់រាជរដ្ឋាភិបាលដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា វិធានការអន្តរាគមន៍បន្ទាន់ចំពោះមុខក្នុងបរិការណ៍វិបត្តិជំងឺកូវីដ-១៩ និងវិធានការជាយុទ្ធសាស្ត្រក្រោមក្របខ័ណ្ឌអនុវត្តយុទ្ធសាស្ត្រក្នុងរយៈពេលខ្លីនិងមធ្យម ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា២០២២-២០២៧។

### ក. វិធានការមុតស្រួចរបស់រាជរដ្ឋាភិបាល

ក្នុងរយៈពេលថ្មីៗកន្លងមកនេះ រាជរដ្ឋាភិបាលបានប្រឹងប្រែងជំរុញការងារកែទម្រង់ជាច្រើន ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា ដែលក្នុងនោះវិធានការនៃការធ្វើឱ្យប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្ម កាត់បន្ថយចំណាយដឹកជញ្ជូននិងឡូជីស្ទីក និងអគ្គិសនី សំដៅបង្កលក្ខណៈឱ្យរោងចក្រ សហគ្រាសក្នុងវិស័យនេះមានលទ្ធភាពកាត់បន្ថយថ្លៃដើម និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ខ្លួន។ ជាក់ស្តែង រាជរដ្ឋាភិបាល ក្នុងវេទិការាជរដ្ឋាភិបាលផ្នែកឯកជនលើកទី១៨ បានដាក់ចេញនូវវិធានការមុតស្រួចជាកញ្ចប់មួយចំនួន ជាអាទិ៍ រួមមាន÷

- ការរំកិលកាំកុងត្រូលចេញពីច្រកទ្វារព្រំដែននិងការលុបកាំសាបតី ការបញ្ចប់តួនាទីអចិន្ត្រៃយ៍របស់អគ្គនាយកដ្ឋានកាំកុងត្រូល ក្នុងការត្រួតពិនិត្យទំនិញនាំចូលពីច្រកទ្វារអន្តរជាតិ និងការរំលាយចោលនូវស្ថាប័នកាំសាប មានគោលបំណងកាត់បន្ថយបន្ទុកចំណាយនិងបន្ទុករត់ការឯកសារ ជួយឱ្យចំណេញពេលវេលា និងផ្តល់ការសម្រួលជាអតិបរមានៅក្នុងដំណើរការពាណិជ្ជកម្មនិងការនាំចេញ នាំចូល។
- ការលុបចោលនូវការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពទំនិញ(CO) សម្រាប់ប្រទេសមិនមានតម្រូវការ ដើម្បីសម្រួលដល់ការនាំចេញ ទាំងពេលវេលា និងការចំណាយនានា ជាពិសេស សម្រាប់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប។
- ការកាត់បន្ថយចំណាយឡូជីស្ទីក ថ្លៃសេវាលើកដាក់ និងថ្លៃសេវាផែ÷ កំពង់ផែស្វយ័តរដ្ឋទាំងពីរបានបញ្ចុះថ្លៃសេវាមួយចំនួន រួមមានថ្លៃលើសេវាកម្មលើក ដាក់ពីនាវា ទីលាន(Stevedoring Charge) ថ្លៃច្រកទ្វារ (Gate fee) ការអនុគ្រោះថ្លៃស្តុកទុកកុងតឺន័រចំនួន២ថ្ងៃបន្ថែមទៀតសម្រាប់កុងតឺន័រនាំចេញ(Export Container) សេវាកម្មដឹកជញ្ជូនកុងតឺន័រ និងថ្លៃសេវាLo-Lo Scan ជាដើម។ បន្ថែមលើនេះ ក្រសួង

សាធារណការ និងដឹកជញ្ជូនបន្តចរចាជាមួយក្រុមហ៊ុននាវាចរ(Shipping lines) ដើម្បីបញ្ចុះថ្លៃសេវាស្រប តាមឆន្ទៈរបស់រដ្ឋ ដែលក្នុងនោះរួមមានថ្លៃលើក ដាក់នៅចំណត(Terminal Handling Charge-THC) និងថ្លៃសេវាសម្រាប់ភាពមិនសមតុល្យគ្នារវាងកុងតឺន័រចេញ ចូល(Container Imbalance Charge-CIC) ថ្លៃដឹកជញ្ជូនតាមផ្លូវសមុទ្រ(Ocean Freight Charge-OFC) និងថ្លៃទប់ទល់នៅពេលប្រេងឡើងថ្លៃខ្ពស់ (Emergency Bunker Charge-EBC)។

- ការកាត់បន្ថយថ្លៃអគ្គិសនី៖ ចាប់តាំងពីការសម្រេចក្នុងវេទិកានេះមក ថ្លៃអគ្គិសនីត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ ពោលគឺកាត់បន្ថយប្រមាណ២សេន/គីឡូវ៉ាត់ម៉ោង សម្រាប់អ្នកប្រើប្រាស់ទូទៅក្នុងឆ្នាំ២០១៩ និងកាត់បន្ថយ១សេន/គីឡូវ៉ាត់ម៉ោងបន្ថែមទៀតសម្រាប់អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្មក្នុងឆ្នាំ២០២០។ បន្ថែមលើនេះ ក៏មានការគិតគូរកត់អត្រាថ្លៃខុសគ្នារវាងការប្រើប្រាស់ពេលយប់និងពេលថ្ងៃដើម្បីលើកទឹកចិត្តអ្នកប្រើប្រាស់ពេលយប់ដែលមានបរិមាណសល់ច្រើន។
- វិធានការសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រួមមានការកំណត់ជាក់លាក់នៃកម្រៃសេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងកាត់បន្ថយ៥០% នូវថ្លៃស្កែនកុងតឺន័រទំនិញនាំចេញ នាំចូល និងកែសម្រួលគោលការណ៍និងនីតិវិធីកំណត់មុខសញ្ញាកុងតឺន័រដែលត្រូវស្កែន និងការជំរុញការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ដើម្បីចំណេញពេលវេលានិងកាត់បន្ថយចំណាយផ្សេងៗ។
- វិធានការសម្រួលពាណិជ្ជកម្មដែលស្ថិតក្រោមសមត្ថកិច្ចអគ្គនាយកដ្ឋានពន្ធដារ រួមមាន១-ដំណើរការប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែមក្នុងគោលដៅគ្រប់គ្រងការបង្វិលសងនិងការប្រើប្រាស់ឥណទានអាករលើតម្លៃបន្ថែម(Online-VAT Refund and Online-VAT Credit) និងលុបបំបាត់ការចុះធ្វើសវនកម្មជាន់គ្នារវាងអង្គភាពជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ ២-ការកាត់បន្ថយពេលវេលាកំណត់ពន្ធឡើងវិញ ចំពោះការធ្វើសវនកម្មពេញលេញ ដោយកំណត់ត្រឹម៣ឆ្នាំថយក្រោយប៉ុណ្ណោះ ធៀបនឹងបទប្បញ្ញត្តិច្បាប់ជាធរមាន ដែលអនុញ្ញាតឱ្យធ្វើសវនកម្មពេញលេញរយៈពេល១០ឆ្នាំថយក្រោយ និង៣-កាត់បន្ថយអត្រាទោសទណ្ឌលើការបង់ប្រាក់ពន្ធពីកម្រិត២%ក្នុងមួយខែមកត្រឹម ១,៥%ក្នុងមួយខែវិញ។
- កាត់បន្ថយថ្ងៃឈប់សម្រាកបុណ្យនិងទិវា៖ ក្នុងឆ្នាំ២០២០ រាជរដ្ឋាភិបាលបានសម្រេចកាត់បន្ថយថ្ងៃឈប់សម្រាកបុណ្យនិងទិវាចំនួន៦ថ្ងៃ ដើម្បីរួមចំណែកលើកកម្ពស់ផលិតភាពការងារ។
- ការពិនិត្យនិងរៀបចំបញ្ជីស្ថាប័ន និងពេលវេលាចុះត្រួតពិនិត្យនៅតាមរោងចក្រ៖ ជំហានដំបូងគឺការច្របាច់បញ្ចូលគ្នាទៅជាក្រុមតែមួយនិងចុះតែមួយលើកក្នុងមួយឆ្នាំចំពោះគោលដៅមួយសម្រាប់ក្រសួង ស្ថាប័នមួយ និងជំហានបន្ទាប់គឺ កំណត់ក្រុមការងារអធិការកិច្ចអន្តរស្ថាប័នតែមួយក្រុមនិងចុះតែមួយលើកក្នុងមួយឆ្នាំចំពោះគោលដៅមួយ។ មកទល់នឹងបច្ចុប្បន្ននេះ ដោយមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន ការចុះធ្វើអធិការកិច្ចទៅតាមរោងចក្រ សហគ្រាស កំពុងត្រូវបានអនុវត្តតាមការសម្រេចខាងលើ។

- កំណត់អត្រាភាគទាននៃរបបសោធន និងការកំណត់នូវពេលវេលានិងចំនួនថ្ងៃបើកប្រាក់បំណាច់អតីតភាពការងារ÷ ក្រៅពីការកំណត់នូវអត្រាច្បាស់លាស់មួយ(អត្រាភាគទានត្រឹម៤% ដោយមានការកែសម្រួលរៀងរាល់៥ឆ្នាំម្តង) ថ្មីៗនេះរាជរដ្ឋាភិបាលបានបង្ហាញនូវកាយវិការទន់ភ្លន់មួយកម្រិតទៀតតាមរយៈការពន្យារពេលអនុវត្តកម្មវិធីគាំពារសង្គមផ្សេងទៀត។ បន្ថែមលើនេះ បានពន្យារពេលការបើកប្រាក់រំលឹកបំណាច់អតីតភាពការងារសម្រាប់វិស័យកាត់ដេរ មុនឆ្នាំ២០១៩ទៅអនុវត្តក្នុងខែមករាឆ្នាំ២០២១ ដើម្បីបន្ធូរបន្ថយសម្ពាធដល់វិនិយោគិនក្នុងវិស័យកាត់ដេរ ជាពិសេសការលំបាកនៃលំហូរសាច់ប្រាក់។

## ខ. វិធានការអន្តរាគមន៍បន្ទាន់ចំពោះមុខក្នុងបរិការណ៍វិបត្តិជំងឺកូវីដ-១៩

ក្នុងបរិការណ៍វិបត្តិជំងឺកូវីដ-១៩នេះ រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃនិងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានគិតគូរពីការរៀបចំនិងដាក់ឱ្យអនុវត្តកញ្ចប់វិធានការអន្តរាគមន៍បន្ទាន់ចំពោះមុខជាបន្តបន្ទាប់(ជុំទី១០) ដើម្បីគ្រប់គ្រងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ចំពោះវិស័យនេះដែលបានទទួលរងឥទ្ធិពលផលប៉ះពាល់។ ជាក់ស្តែង វិធានការអន្តរាគមន៍មានលក្ខណៈប្រទាក់ក្រឡា សំដៅជួយបណ្តារោងចក្រ សហគ្រាសនិងកម្មករ និយោជិត ដែលទទួលផលប៉ះពាល់ជាអាទិ៍ដូចខាងក្រោម÷

- ពិនិត្យផ្តល់ជូនការលើកលែងពន្ធ(Tax Holiday) អាចពី៦ខែទៅ១ឆ្នាំ សម្រាប់រោងចក្រ សហគ្រាស នីមួយៗ ដែលទទួលរងផលប៉ះពាល់ទៅតាមកម្រិតនៃផលប៉ះពាល់ធ្ងន់ធ្ងរ ត្រូវបានកំណត់ជា២ កម្រិតគឺ១-លើកលែងពន្ធលើប្រាក់ចំណូលរយៈពេល៦ខែ សម្រាប់រោងចក្រ សហគ្រាសដែលរងផលប៉ះពាល់កម្រិតពី២០%ទៅ៣៩%ដោយលើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំចំនួន៥០%នៃប្រាក់ពន្ធត្រូវបង់សរុប និង២-លើកលែងពន្ធលើប្រាក់ចំណូលរយៈពេល១ឆ្នាំ សម្រាប់រោងចក្រ សហគ្រាសដែលរងផលប៉ះពាល់កម្រិតពី៤០%ទៅ១០០%ដោយលើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំចំនួន១០០%នៃប្រាក់ពន្ធត្រូវបង់សរុប
- សម្រួលនីតិវិធីនិងបង្កភាពងាយស្រួលដល់ការនាំចូលវត្ថុធាតុដើម ដែលបម្រើដល់ផលិតកម្ម(ឱ្យមានដំណើរការឡើងវិញ) ដោយរៀបចំជាច្រកបៃតង(Green Lane) ជាដើម
- សម្រាប់រោងចក្រ សហគ្រាស ដែលផ្អាកសកម្មភាពផលិតរយៈពេលខ្លីដោយសារខ្វះវត្ថុធាតុដើម រោងចក្រសហគ្រាសត្រូវចេញប្រាក់ខែចំនួន៤០% នៃប្រាក់ខែអប្បបរមារបស់កម្មករ និយោជិត(ដែលមានចំនួន ១៩០ ដុល្លារអាមេរិក សម្រាប់ឆ្នាំ២០២០) ខណៈរាជរដ្ឋាភិបាលចូលរួមចំណែក២០%នៃប្រាក់ខែអប្បបរមាបន្ថែម (សរុប៦០%នៃប្រាក់ខែអប្បបរមា)។ ដើម្បីបានទទួលនូវការឧបត្ថម្ភនេះ កម្មករ និយោជិតត្រូវចូលរួមវគ្គបណ្តុះបណ្តាលខ្លីៗរវាងពី១ទៅ២សប្តាហ៍ ដែលរៀបចំដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមបណ្តារោងចក្រ សហគ្រាស
- ផ្តល់សេវាជួយរកការងារឱ្យកម្មករ និយោជិតធ្វើ តាមរយៈទីភ្នាក់ងារជាតិមុខរបរនិងការងារ(NEA) ដែលអាចជួយជំរុញកម្មករ និយោជិត ដែលបាត់បង់ការងារឱ្យចាប់យកការងារថ្មីបានឆាប់រហ័ស
- បណ្តុះបណ្តាលជំនាញទន់(Soft Skills) រយៈពេលខ្លីពី១ដល់២សប្តាហ៍ដល់កម្មករ និយោជិត ដែលបាត់បង់

ការងារនិងមិនទាន់រកការងារធ្វើឡើងវិញបាន

- បណ្ដុះបណ្ដាលជំនាញបច្ចេកទេសរយៈពេល៤ខែ ដើម្បីបំពាក់ជំនាញថ្មីនិងផ្តល់ភាពងាយស្រួលក្នុងការរកការងារធ្វើក្នុងវិស័យមិនមែនកាត់ដេរ
- អនុញ្ញាតឱ្យរោងចក្រមិនបង់ប្រាក់វិភាគទានធានារ៉ាប់រងរបបហានិភ័យការងារនិងថែទាំសុខភាព(បសស) ក្នុងអំឡុងពេលរោងចក្រព្យួរអាជីវកម្ម
- ផ្តល់ប្រាក់ឧបត្ថម្ភ៤០ដុល្លារអាមេរិកក្នុង១ខែសម្រាប់កម្មករ និយោជិត១នាក់ ចំណែករោងចក្រ សហគ្រាស ត្រូវបន្ថែមចំនួន៣០ដុល្លារអាមេរិក សម្រាប់កម្មករ និយោជិត១នាក់(ដូចនេះ ជាសរុបកម្មករ និយោជិតម្នាក់ទទួលបាន៧០ដុល្លារអាមេរិក ក្នុងមួយខែ) រហូតដល់ដំណាច់ខែធ្នូ ឆ្នាំ២០២១
- ការអនុវត្តរបបសន្តិសុខសង្គមផ្នែកសោធន ត្រូវបានបន្តពន្យារពេល រហូតដល់ឆមាសទី២ ឆ្នាំ២០២២។ ការពន្យារពេលនេះ នឹងត្រូវផ្អែកលើការវាយតម្លៃជាបន្តបន្ទាប់នូវស្ថានភាពសេដ្ឋកិច្ច សង្គម
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវសហការជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) និងដៃគូពាក់ព័ន្ធ ដើម្បីជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីលទ្ធផលការងាររបស់«គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC)» ដើម្បីឱ្យអ្នកបញ្ជាទិញបានដឹងថាទំនិញពីកម្ពុជាមានការគោរពនូវសិទ្ធិមនុស្ស សិទ្ធិការងារ មានលក្ខខណ្ឌការងារល្អប្រសើរ និងមិនមានការប្រើប្រាស់ពលកម្មកុមារ។

## គ. វិធានការជាយុទ្ធសាស្ត្រក្រោមក្របខ័ណ្ឌអនុវត្តយុទ្ធសាស្ត្រនេះ

បន្ថែមលើវិធានការមុតស្រួចរបស់រាជរដ្ឋាភិបាលនិងវិធានការអន្តរាគមន៍បន្ទាន់ដែលបានដាក់ឱ្យអនុវត្តកន្លងមកខាងលើ ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា២០២២-២០២៧ រាជរដ្ឋាភិបាលបានរៀបចំនិងដាក់ឱ្យអនុវត្តវិធានការជាយុទ្ធសាស្ត្រក្នុងរយៈពេលខ្លីនិងរយៈពេលមធ្យម ដើម្បីអភិវឌ្ឍវិស័យនេះឱ្យក្លាយទៅជាឧស្សាហកម្ម ដែលមានចីរភាពបរិស្ថាន មានភាពធន់ មានតម្លៃបន្ថែមខ្ពស់ មានមូលដ្ឋានគាំទ្រពិពិធកម្ម និងមានភាពប្រកួតប្រជែង ដូចខាងក្រោម÷

### ៦.១. បន្តពង្រឹងធនធានមនុស្សដើម្បីបង្កើនផលិតភាពនិងបង្កើតគន្លងអាជីពសម្រាប់កម្មករ និយោជិត

ជំនាញក្នុងស្រុក ប្រកបដោយគុណភាពនិងបរិមាណ គឺជាកត្តាគាំទ្រដល់ផលិតកម្មដែលមានលក្ខណៈស្មុគស្មាញម៉ូដប្លែកៗដែលមានថ្លៃខ្ពស់ តម្លៃបន្ថែមខ្ពស់ និងជួយបង្កើនផលិតភាពរបស់កម្មករ និយោជិត។ ការអភិវឌ្ឍធនធានមនុស្សមានសារៈសំខាន់សម្រាប់ការពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ឧស្សាហកម្មនេះ ដោយសារការពឹងផ្អែកលើកម្លាំងពលកម្មបរទេស រួមមានអ្នកគ្រប់គ្រង អ្នកបច្ចេកទេស ឬជំនាញការ បានរួមចំណែកធ្វើឱ្យថ្លៃផលិតកម្មខ្ពស់។ ដូច្នេះ យុទ្ធសាស្ត្រនេះមានគោលដៅផ្តល់នូវឱកាសកាន់តែប្រសើរជូនកម្មករ និយោជិតដែលជាកម្លាំងពលកម្មក្នុងស្រុកឱ្យមានលទ្ធភាពក្លាយជាអ្នកគ្រប់គ្រង អ្នកបច្ចេកទេស និងជំនាញការផ្សេងៗ ដោយផ្តោតទៅលើការអភិវឌ្ឍជំនាញ តាមរយៈកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ(TVET) និងកម្មវិធីអប់រំថ្នាក់ឧត្តមសិក្សាសម្រាប់បម្រើឱ្យវិស័យនេះផងដែរ។ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការជា

យុទ្ធសាស្ត្រ ដូចខាងក្រោម៖

**វិធានការរយៈពេលខ្លី ២០២២-២០២៤៖**

- អនុវត្តការផ្ទេរតួនាទីអ្នកគ្រប់គ្រងថ្នាក់កណ្តាល អ្នកបច្ចេកទេស និងជំនាញការផ្សេងៗជូនកម្លាំងពលកម្មក្នុងស្រុក ក្នុងរយៈពេល៣ឆ្នាំ ឬស្របតាមការកំណត់ដោយច្បាប់ស្តីពីការងារ ឬ/និងក្របខ័ណ្ឌតំបន់និងអន្តរជាតិ ដោយជំរុញការវិនិយោគលើការអភិវឌ្ឍជំនាញនិងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដើម្បីបង្កើនចំនួនកម្មករ និយោជិតក្នុងស្រុកដែលកាន់តួនាទីទាំងនោះ តាមរយៈការផ្តល់ការលើកទឹកចិត្តវិនិយោគស្របតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានិងបទប្បញ្ញត្តិពាក់ព័ន្ធ។
- រៀបចំនិងអនុវត្តបទដ្ឋានស្តង់ដារ/ក្របខ័ណ្ឌសមត្ថភាព(Competency Standards/Framework) ក្នុងការវាយតម្លៃកម្រិតសមត្ថភាពនិងផ្តល់ការលើកទឹកចិត្តការងារជូនកម្មករ និយោជិតតាមកម្រិតសមត្ថភាព។
- សិក្សាពីតម្រូវការជំនាញ(Skills Mapping)នៅក្នុងវិស័យនេះក្នុងពេលបច្ចុប្បន្ននិងការសិក្សាពីការរំពឹងទុកនៃតម្រូវការជំនាញ(Skills Anticipation) ក្នុងរយៈពេល៥-១០ឆ្នាំទៅមុខ ដើម្បីផ្តល់លទ្ធភាពឱ្យឧស្សាហកម្មនេះ និងជាពិសេសកម្មករ និយោជិតអាចធ្វើការសម្របខ្លួនជាមួយនឹងនិន្នាការសំខាន់ៗ រួមមានស្វ័យប្រវត្តិកម្មលើខ្សែច្រវាក់ផលិតកម្មនិងការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថលផ្សេងៗជាដើម។
- ជំរុញនិងបង្កើនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ជំនាញ(SDF) ដើម្បីលើកកម្ពស់ជំនាញបច្ចេកទេសជំនាញគ្រប់គ្រងនិងជំនាញផ្សេងៗទៀតដែលចាំបាច់សម្រាប់គាំទ្រដល់វិស័យនេះជាពិសេស ដោយផ្អែកលើលទ្ធផលសិក្សាតម្រូវការជំនាញនិងការសិក្សាការរំពឹងទុកនៃតម្រូវការជំនាញខាងលើ។
- បង្កើនការវិនិយោគនិងបន្តលើកកម្ពស់តួនាទីរបស់វិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា(CGTI) បន្ថែមទៀតឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការអនុវត្តយន្តការគាំទ្រដែលមានស្រាប់ឬ/និងដែលត្រូវការបង្កើតថ្មី ដូចជាកម្មវិធីអាហារូបករណ៍ពិសេស ដោយមានការសហការជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) សមាគមស្បែកជើងកម្ពុជា(CFA) បណ្តារោងចក្រ និងភាគីពាក់ព័ន្ធ សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់វិស័យនេះបានមួយកម្រិតទៀតនិងកាន់តែប្រសើរ។
- សហការជាមួយភាគីពាក់ព័ន្ធ ជាពិសេសដៃគូអភិវឌ្ឍនិងវិនិយោគិនបរទេស ដើម្បីពិនិត្យលទ្ធភាពបង្កើតស្ថាប័នអភិវឌ្ឍជំនាញនិងបណ្តុះបណ្តាលវិជ្ជាជីវៈបន្ថែមទៀត ដូចជាវិទ្យាស្ថាន/មជ្ឈមណ្ឌល/សាលា-បណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ស្របតាមតម្រូវការឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូប។
- ជំរុញនិងលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធ ជាពិសេសបណ្តារោងចក្រ ដើម្បីជំរុញការអភិវឌ្ឍជំនាញ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់កម្មករ និយោជិតនៅតាមរោងចក្រផ្ទាល់(In-housing/On-the-job Trainings) និងតាមរយៈការប្រើប្រាស់សេវាកម្មរបស់ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ ដើម្បីផ្តល់ការបណ្តុះបណ្តាលលើជំនាញនិងវគ្គវិញ្ញាបនបត្របច្ចេកទេសវិជ្ជាជីវៈតាមកម្រិត រួមមាន៖ កម្មវិធីបណ្តុះ-បណ្តាលភាសា ជំនាញការបញ្ជាទិញ ឡូជីស្ទីក ការគ្រប់គ្រងច្រវាក់ផ្គត់ផ្គង់ ចំណេះដឹងបច្ចេកវិទ្យាឌីជីថល ភាពជាអ្នកដឹកនាំ ការគ្រប់គ្រង ការត្រួតពិនិត្យ និងទំនាក់ទំនង ព្រមទាំងទំនាក់ទំនងវិជ្ជាជីវៈ ជាដើម។

- ជំរុញការអនុវត្តវិធានការពាក់ព័ន្ធនឹងវិស័យនេះនៅក្នុង**គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥**។

**វិធានការរយៈពេលមធ្យម ២០២៥-២០២៧÷**

- លើកទឹកចិត្តដល់គ្រឹះស្ថានឧត្តមសិក្សានិងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទាំងសាធារណៈនិងឯកជន ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាដែលជាតម្រូវការសម្រាប់វិស័យនេះ ដូចជា÷ ជំនាញផ្នែកវាយនភណ្ឌ ជំនាញរចនា ជំនាញវិស្វកម្មឧស្សាហកម្ម ជំនាញការបញ្ជាទិញ ឡូជីស្ទីក ការគ្រប់គ្រងច្រវាក់ផ្គត់ផ្គង់ និងជំនាញភាពជាអ្នកដឹកនាំនិងគ្រប់គ្រងជាដើមឬសហការជាមួយសាកលវិទ្យាល័យ ឬវិទ្យាស្ថានដែលផ្តល់កម្មវិធីឬវគ្គសិក្សានេះស្រាប់ ទាំងនៅក្នុងស្រុក និងនៅក្រៅប្រទេស។
- លើកទឹកចិត្តនិងពិនិត្យលទ្ធភាពក្នុងការគាំទ្រផ្នែកធនធានហិរញ្ញវត្ថុក្នុងការបញ្ជូននិស្សិតនិងនិយោជិតកម្ពុជាដែលមានសក្តានុពលទៅបន្តការសិក្សាជំនាញចាំបាច់ក្នុងវិស័យនេះ នៅសាកលវិទ្យាល័យនិងវិទ្យាស្ថាននៅក្រៅប្រទេស។
- បន្តពង្រឹងវិធានការរយៈពេលខ្លីពាក់ព័ន្ធខាងលើ ក្នុងគោលបំណងលើកកម្ពស់ធនធានមនុស្ស ដើម្បីបង្កើនផលិតភាពនិងបង្កើតគន្លងអាជីពសម្រាប់កម្មករ និយោជិត។

### ៦.២. បន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនិងសុខុមាលភាពរបស់កម្មករ និយោជិត

ការបន្តធ្វើឱ្យល្អប្រសើរនូវលក្ខខណ្ឌការងារនិងសុខុមាលភាពរបស់កម្មករ និយោជិតជាកត្តាសំខាន់ក្នុងការពង្រឹងភាពប៉ាន់ប្រមាណបាននិងស្ថិរភាពនៃវិស័យនេះ។ ភាពប្រសើរនៃលក្ខខណ្ឌការងារនិងសុខុមាលភាពជាផ្នែកមួយដ៏សំខាន់សម្រាប់ម្ចាស់ម៉ាកផលិតផលសម្រេចចិត្តដាក់ការបញ្ជាទិញរបស់ខ្លួន សម្រាប់លើកកម្ពស់កេរ្តិ៍ឈ្មោះនៃឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូប និងសម្រាប់ការពារទំនុកចិត្តរបស់អ្នកប្រើប្រាស់និងអ្នកផលិតនៅកម្ពុជាឱ្យបន្តវិនិយោគរយៈពេលវែងផងដែរ។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្តេជ្ញាធ្វើឱ្យល្អប្រសើរនូវសុខុមាលភាពរបស់កម្មករ និយោជិតបន្ថែមទៀត តាមរយៈការអនុវត្តវិធានការកន្លងមក រួមមាន÷ ការពង្រឹងយន្តការសន្តិសុខសង្គមដោយឥតគិតថ្លៃដែលគ្របដណ្តប់លើការថែទាំសុខភាពនិងគ្រោះថ្នាក់ ការលើកទឹកចិត្តពិសេសជូនកម្មករ និយោជិត ដែលមានផ្ទៃពោះ រៀបចំការផ្តល់សេវាចាំបាច់ឱ្យខិតជិតកម្មករ និយោជិត អនុវត្តការត្រួតពិនិត្យលើការជួលកន្លែងស្នាក់នៅនិងថ្លៃទឹក ភ្លើងឱ្យស្ថិតក្នុងកម្រិតសមរម្យសម្រាប់កម្មករ និយោជិត ផ្តល់ជូនសេវារថយន្តក្រុងសាធារណៈដោយឥតគិតថ្លៃរយៈពេលពីរឆ្នាំសម្រាប់កម្មករ និយោជិត ដែលរស់នៅតាមបណ្តោយផ្លូវរថយន្តក្រុង និងដាក់ឱ្យអនុវត្តរបបសោធននិវត្តន៍ជាដើម។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺដើម្បីបន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងសុខុមាលភាពកម្មករ និយោជិត ប៉ុន្តែការបំពេញលក្ខខណ្ឌទាំងនេះឱ្យបានពេញលេញនៅតែជាបញ្ហាប្រឈម និងទាមទារនូវការចូលរួមចំណែកពីតួអង្គពាក់ព័ន្ធ។ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០២២-២០២៤÷**

- បន្តពង្រឹងវប្បធម៌អនុលោមភាពក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប តាមរយៈការប្រើប្រាស់របាយការណ៍វាយតម្លៃរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរបស់គម្រោងរោងចក្រកាន់តែ

ប្រសើរនៅកម្ពុជា(BFC) និងការធ្វើវិចារណកម្មអធិការកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដើម្បីបន្តពង្រឹងការអនុវត្តវិធានការអធិការកិច្ចការងារឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

- បន្តជំរុញការកសាងសមត្ថភាពនិងការផ្លាស់ប្តូរចំណេះដឹងរវាងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងឆ្លើយតបទៅនឹងបរិការណ៍កម្ពុជា។
- ពង្រឹងតួនាទីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងស្ថាប័នពាក់ព័ន្ធ ក្នុងយន្តការផ្សះផ្សាវិវាទនៅកម្រិតរោងចក្រ សហគ្រាស និងកម្រិតក្រសួង និងលើកកម្ពស់ការចូលរួមប្រកបដោយវិជ្ជាជីវៈរបស់តំណាងភាគីវិវាទ ជាពិសេសភាគីកម្មករ និយោជិតក្នុងការដោះស្រាយវិវាទការងារ។
- ផ្តល់លំហសម្រាប់ការចរចាអនុសញ្ញារួម(CBA) រវាងសហជីពកម្មករ និយោជិតនិងនិយោជក ក្នុងកម្រិតសហគ្រាស រោងចក្រនិងក្រុមម្ចាស់ម៉ាកផលិតផល តាមតម្រូវការនិងលទ្ធភាពជាក់ស្តែង។
- ជំរុញនិងលើកកម្ពស់សមត្ថភាពនិងការយល់ដឹងរបស់ប្រតិភូបុគ្គលិក ថ្នាក់ដឹកនាំសហជីព ជាពិសេសថ្នាក់ដឹកនាំសហជីពមូលដ្ឋាននៅតាមរោងចក្រ សហគ្រាស ក៏ដូចជាអ្នកគ្រប់គ្រងធនធានមនុស្សនិងរដ្ឋបាលរបស់រោងចក្រ សហគ្រាស។
- បន្តពង្រឹងតួនាទីនិងផ្តល់ការគាំទ្រចាំបាច់ដល់យន្តការនិងដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីឱ្យបន្តស្ថិតនៅជាស្ថាប័ន ប្រកបដោយវិជ្ជាជីវៈ អព្យាក្រឹត និងឯករាជ្យ ក្នុងការដោះស្រាយវិវាទការងារស្របតាមស្មារតីនៃការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារពាក់ព័ន្ធនឹងការដោះស្រាយវិវាទការងារ រួមទាំងវិវាទការងារបុគ្គលផងដែរ។
- ពង្រឹងសុវត្ថិភាពនិងផាសុកភាពនៃមធ្យោបាយដឹកជញ្ជូនកម្មករ និយោជិត តាមរយៈការបង្កើតយន្តការគាំទ្រមួយជាក់លាក់ រួមមាន ការពិនិត្យលទ្ធភាពផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដោយត្រង់ពីនិយោជកដល់អ្នកផ្តល់សេវាដឹកជញ្ជូនដែលប្រើប្រាស់មធ្យោបាយដឹកជញ្ជូនថ្មីមានលក្ខខណ្ឌសុវត្ថិភាពប្រសើរជាងមុន ផ្តល់កម្ចីដែលមានការប្រាក់ទាបសមរម្យជូនអ្នកផ្តល់សេវាបើកបរឱ្យមានលទ្ធភាពប្រើប្រាស់រថយន្តដឹកជញ្ជូនកម្មករ និយោជិត ប្រកបដោយសុវត្ថិភាពនិងតម្រូវឱ្យមានធានារ៉ាប់រង និងផ្តល់ការលើកទឹកចិត្តផ្នែកពន្ធគយសម្រាប់ការនាំចូលមធ្យោបាយដឹកជញ្ជូន ដើម្បីបម្រើឱ្យវិស័យនេះជាដើម។
- ពង្រឹងសុវត្ថិភាពការដឹកជញ្ជូនកម្មករ និយោជិត តាមរយៈការពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ ដោយធ្វើការសម្របសម្រួលចរាចរណ៍នៅមុខរោងចក្រ ជាពិសេសនៅអំឡុងពេលចេញនិងចូលធ្វើការ ដើម្បីកាត់បន្ថយការកកស្ទះនិងគ្រោះថ្នាក់ និងការផ្តល់នូវវគ្គបណ្តុះបណ្តាលសម្រាប់អ្នកបើកបរអំពីការអនុវត្តការបើកបរសុវត្ថិភាព/គ្មានសុវត្ថិភាព បញ្ហាសុវត្ថិភាពចរាចរណ៍ និងអាកប្បកិរិយាដែលមានការទទួលខុសត្រូវក្នុងចំណោមអ្នកបើកបរនិងកម្មករ និយោជិតជាដើម។
- ពង្រឹងការគ្រប់គ្រងការបញ្ចេញសំណល់រឹង រាវ និងឧស្ម័ន ដើម្បីរួមចំណែកក្នុងកិច្ចគាំពារបរិស្ថាននិងសុខុមាលភាពប្រជាពលរដ្ឋ។

- ពង្រឹងសុខភាពនិងសុវត្ថិភាពការងារ(OSH) នៅតាមរោងចក្រ សហគ្រាស ដើម្បីលើកកម្ពស់លក្ខខណ្ឌការងារ រួមមានសុវត្ថិភាពផ្នែកសំណង់ ផ្នែកសារធាតុគីមី ផ្នែកអគ្គីភ័យ ផ្នែកជំងឺឆ្លងរាលដាល និងការត្រៀមខ្លួនពេលមានអាសន្នណាមួយជាដើម។
- ពង្រឹងសុខុមាលភាពនៅកន្លែងធ្វើការងាររបស់កម្មករ និយោជិត តាមរយៈការធ្វើឱ្យប្រសើរឡើងនូវខ្យល់បរិយាកាសនៅក្នុងអគារការងារ និងការគ្រប់គ្រងការបញ្ចេញសំណល់រឹង រាវ និងឧស្ម័នពីរោងចក្រ រួមទាំងការបោះចោលសំណល់និងសំរាមពីសំណាក់កម្មករ និយោជិត។
- ពង្រឹងសុខុមាលភាពអាហារូបត្ថម្ភរបស់កម្មករ និយោជិត តាមរយៈការផ្តោតសំខាន់លើទិដ្ឋភាព÷ សេវាកម្មផ្គត់ផ្គង់តម្រូវការអាហារូបត្ថម្ភ ថ្លៃសមរម្យនៃអាហារូបត្ថម្ភ និងការផ្តល់កន្លែងអាហារដ្ឋានស្តង់ដារមួយតាមរយៈការអនុវត្តការសាងសង់អាហារដ្ឋាននៅតាមរោងចក្រឱ្យបានតឹងរ៉ឹង។
- ជំរុញនិងលើកទឹកចិត្តភាគីពាក់ព័ន្ធឱ្យគាំទ្រដល់ការអនុវត្តគម្រោងលំនៅឋានតម្លៃសមរម្យ ជាពិសេសផ្តល់ការលើកទឹកចិត្តដល់កម្មករ និយោជិតឱ្យមានលទ្ធភាពទិញលំនៅឋានតម្លៃសមរម្យ ដើម្បីទទួលបានកន្លែងស្នាក់នៅសមរម្យនិងលើកកម្ពស់ការធានាបានផ្នែកការងារ ស្របតាម**គោលនយោបាយស្តីពីការលើកទឹកចិត្តនិងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ**។

**វិធានការរយៈពេលមធ្យម ២០២៥-២០២៧÷**

- ពិនិត្យលទ្ធភាពពង្រីកវិសាលភាពនៃការផ្តល់របបសន្តិសុខសង្គម ដែលផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម(បសស)បច្ចុប្បន្ន ជូនកម្មករ និយោជិត តាមការវិវត្តជាក់ស្តែងនៃវិស័យនេះ រួមមានការគិតគូរពីលទ្ធភាពនៃការផ្តល់អត្ថប្រយោជន៍ធានារ៉ាប់រងការងារជូនកម្មករ និយោជិតជាដើម។
- បន្តពង្រឹងវិធានការរយៈពេលខ្លីពាក់ព័ន្ធខាងលើ ដើម្បីលើកកម្ពស់លក្ខខណ្ឌការងារនិងសុខុមាលភាពរបស់កម្មករ និយោជិត។

### ៦.៣. លើកកម្ពស់ការវិនិយោគក្នុងស្រុកនិងបរទេសក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់

វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបបានរីកចម្រើនយ៉ាងខ្លាំងក្នុងរយៈពេលជិត៣ទសវត្សរ៍កន្លងមកដោយពឹងផ្អែកលើការវិនិយោគបរទេស។ ប៉ុន្តែ ដូចដែលបានបញ្ជាក់នៅក្នុងផ្នែកបញ្ហាប្រឈម វិស័យនេះត្រូវតែផ្លាស់ប្តូរពីការផលិតនូវផលិតផលដែលមានលក្ខណៈឬម៉ូដសាមញ្ញ ទៅផលិតផលដែលមានភាពស្មុគស្មាញដែលមានតម្លៃបន្ថែមខ្ពស់ ហើយវិស័យនេះចាំបាច់ត្រូវតែចាក់ឫសឱ្យបានរឹងមាំនៅកម្ពុជា។ រោងចក្រស៊ីអិមធី(CMT) ដែលមានប្រមាណ៧០%នៃរោងចក្រនាំចេញសរុបនៅក្នុងប្រទេសកម្ពុជា មានឱកាសតិចតួចក្នុងការទទួលការបញ្ជាទិញតាមម៉ូដែលផលិតកម្មអេហ្វអូប៊ី(FOB) ដោយសាររចនាសម្ព័ន្ធរបស់រោងចក្រទាំងនោះជាផ្នែកនៃរោងចក្រមេនិងដោយសារអ្នកបញ្ជាទិញពុំទាន់មានការជឿជាក់គ្រប់គ្រាន់ក្នុងការផ្តល់ការបញ្ជាទិញជាប្រភេទអេហ្វអូប៊ី(FOB) នៅក្នុងប្រទេសកម្ពុជាបានច្រើននៅឡើយ។ ជាទូទៅ ម្ចាស់រោងចក្រក្នុងស្រុកអាចបង្កើនឱកាស ដើម្បីទាក់ទាញការបញ្ជាទិញតាមម៉ូដែលអេហ្វអូប៊ី(FOB) ប៉ុន្តែរហូតមកដល់ពេលនេះ ម្ចាស់រោងចក្រក្នុងស្រុកនៅមានចំនួនតិចតួចក្នុងចំណោមអ្នកផ្គត់ផ្គង់លំដាប់ថ្នាក់ទី១(Tier One Supplier - រោងចក្រនាំចេញ)។ ម្ចាស់រោងចក្រក្នុងស្រុកក្នុងចំណោមរោងចក្រ

ម៉ៅការបន្ត/អ្នកផ្គត់ផ្គង់លំដាប់ថ្នាក់ទី២(Tier Two Supplier-រោងចក្រម៉ៅការបន្ត) មានសារៈសំខាន់ ដើម្បីធ្វើឱ្យរោងចក្រមានលទ្ធភាពធ្វើការជាមួយម្ចាស់រោងចក្រក្នុងស្រុកទាំងនេះ ដើម្បីអភិវឌ្ឍនិងបង្កើនជំនាញរបស់ខ្លួន មានលទ្ធភាពទទួលបានហិរញ្ញប្បទាន និងទាក់ទងជាមួយម្ចាស់ម៉ាកផលិតផល ក្នុងគោលបំណងជួយប្រែក្លាយរោងចក្រសហគ្រាសទាំងនោះទៅជាអ្នកផ្គត់ផ្គង់លំដាប់ទី១ ដែលមានទំនាក់ទំនងពាណិជ្ជកម្មដោយផ្ទាល់ជាមួយអ្នកបញ្ជាទិញ។ ការងារនេះ ទាមទារឱ្យបន្តពង្រឹងបរិយាកាសធុរកិច្ច ដែលទាក់ទាញវិនិយោគិនបន្ថែមទៀត ដើម្បីផលិតនូវផលិតផលមានថ្លៃខ្ពស់ មានតម្លៃបន្ថែមខ្ពស់ និងមានលក្ខណៈពិសេស ក្នុងទម្រង់ម៉ូដែលផលិតកម្មអេហ្វអូប៊ី(FOB)កាន់តែច្រើនឡើង ពីចំនួនបច្ចុប្បន្នប្រមាណពី២៥%ក្នុងឆ្នាំ២០១៨ឱ្យកើនដល់៥០%នៅឆ្នាំ២០២៧។ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

**វិធានការរយៈពេលខ្លី ២០២២-២០២៤៖**

- សិក្សាជាយុទ្ធសាស្ត្រស្ដីពីតម្រូវការទីផ្សារនិងតម្រូវការវិនិយោគ(ទាំងការវិនិយោគថ្មីនិងការវិនិយោគឡើងវិញ) លើការផលិតនូវផលិតផលកាត់ដេរ ឬ/និងផលិតផលគាំទ្រមានថ្លៃខ្ពស់ មានតម្លៃបន្ថែមខ្ពស់ និងមានលក្ខណៈពិសេស ដើម្បីរៀបចំសកម្មភាពទាក់ទាញវិនិយោគិនមានសក្តានុពលទាំងនោះមកកម្ពុជា។
- ជំរុញនិងលើកកម្ពស់ការវិនិយោគលើរោងចក្រកែច្នៃរោមសត្វ ផលិតផលស្បែក និងផលិតផលមានសក្តានុពលផ្សេងទៀត សម្រាប់បម្រើឱ្យឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូប និងទីផ្សារបរទេស ដូចជាទីផ្សារប្រទេសចិនជាដើម។
- រៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រទំនាក់ទំនងនិងទីផ្សារ ដើម្បីបន្តលើកកម្ពស់កេរ្តិ៍ឈ្មោះនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា តាមរយៈការផ្សព្វផ្សាយពីការវិវត្តវិជ្ជមាននៅក្នុងវិស័យនេះឱ្យបានទូលំទូលាយនៅលើប្រព័ន្ធផ្សព្វផ្សាយ ការបោះពុម្ពផ្សាយនិងការចេញសេចក្តីប្រកាសព័ត៌មាន និងក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិទៅកាន់វិនិយោគិនសក្តានុពល និងតួអង្គពាក់ព័ន្ធក្នុងវិស័យនេះ។
- ជំរុញការតភ្ជាប់កាន់តែប្រសើររវាងរោងចក្រនាំចេញនិងរោងចក្រ សហគ្រាសម៉ៅការបន្តក្នុងវិស័យនេះ ដូចជាការវិនិយោគរួមគ្នា តាមរយៈយន្តការលើកទឹកចិត្តដែលមានស្រាប់និងថ្មី ដោយសហការយ៉ាងជិតស្និទ្ធជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) សមាគមស្បែកជើងកម្ពុជា(CFA) ម្ចាស់ម៉ាកផលិតផល ម្ចាស់រោងចក្រ និងតួអង្គពាក់ព័ន្ធ។
- ពិនិត្យលទ្ធភាពរៀបចំយន្តការគាំទ្រផ្នែកហិរញ្ញប្បទាន បច្ចេកទេស និងធុរកិច្ច សម្រាប់រោងចក្រ សហគ្រាសកាត់ដេរខ្នាតតូចនិងមធ្យម តាមរយៈធនាគារអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព និងមជ្ឈមណ្ឌលបណ្តុះបណ្តាលធុរកិច្ចថ្មីតេជោ ដើម្បីជួយគាំទ្រដល់ការរៀបចំផែនការការគ្រប់គ្រង ការពង្រីក ឬ/និងការបើករោងចក្រ សហគ្រាសជាដើម។
- ពិនិត្យលទ្ធភាពរៀបចំនិងដាក់ឱ្យអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រចីរភាពបរិស្ថាន ដើម្បីពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃ កាត់បន្ថយផលប៉ះពាល់ និងអាចសម្របខ្លួនទៅនឹងការវិវត្តនៃឧស្សាហកម្មនេះ។
- ពង្រឹងការផ្តល់ការលើកទឹកចិត្តលើការវិនិយោគមូលធន ការផ្ទេរបច្ចេកវិទ្យា ឬ/និងការប្រើប្រាស់ថាមពលកកើតឡើងវិញជាដើម ស្របតាមការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធ។

**វិធានការរយៈពេលមធ្យម ២០២៥-២០២៧÷**

- បន្តលើកកម្ពស់កេរ្តិ៍ឈ្មោះនៃឧស្សាហកម្មនេះនៅកម្ពុជា ជាគោលដៅផលិតកម្មប្រកបដោយអនុលោមភាពក្រមសីលធម៌ ចីរភាពបរិស្ថាន និងជាគោលដៅនៃការបញ្ជាទិញសម្រាប់ផលិតផលមានតម្លៃបន្ថែមខ្ពស់។
- ផ្តល់យន្តការលើកទឹកចិត្តដែលមានស្រាប់និងថ្មី ដល់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យនេះ ឱ្យវិនិយោគលើទំនើបកម្មផលិតកម្មរបស់ខ្លួន ដើម្បីពង្រឹងគុណភាពផលិតផល បង្កើនផលិតភាព និងឈានទៅប្រែខ្លួនទៅជារោងចក្រនាំចេញជាដើម។
- លើកទឹកចិត្តឱ្យរោងចក្រ សហគ្រាសមានបំណងប្រែក្លាយខ្សែច្រវាក់ផលិតកម្មរបស់ខ្លួន ទៅជាការផលិតនូវផលិតផលពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ និងផលិតផលមានលក្ខណៈពិសេស តាមលទ្ធភាពនិងតម្រូវការជាក់ស្តែង។
- បន្តពង្រឹងវិធានការរយៈពេលខ្លីពាក់ព័ន្ធខាងលើ ដើម្បីលើកកម្ពស់ការវិនិយោគក្នុងស្រុកនិងបរទេសដែលផលិតនូវផលិតផលមានបន្ថែមតម្លៃខ្ពស់។

### ៦.៤. ទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រសម្រាប់បម្រើឱ្យវិស័យនេះ

កត្តាចំនួន៤ដែលរួមចំណែកចម្បងដល់ការវិនិច្ឆ័យសម្រាប់ការសម្រេចចិត្តបញ្ជាទិញ រួមមាន÷ លក្ខខណ្ឌការងារ ថ្លៃប្រកួតប្រជែង គុណភាពផលិតផល និងរយៈពេលបញ្ជូនទំនិញ។ ក្នុងនោះ រយៈពេលបញ្ជូនទំនិញកាន់តែមានសារៈសំខាន់ខ្លាំងឡើងចំពោះឧស្សាហកម្មនេះ ជាពិសេសសម្រាប់ផលិតផលម៉ូដពេញនិយម ដែលម្ចាស់ម៉ាកផលិតផលត្រូវការប្រញាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់។ ដើម្បីរួមចំណែកលើកកម្ពស់វិស័យនេះឱ្យមានភាពឆ្លើយតប អាចផលិតនូវផលិតផលមានតម្លៃបន្ថែមខ្ពស់និងមានភាពប្រកួតប្រជែង រួមមានរោមសត្វនិងផលិតផលស្បែកជាដើម កម្ពុជាចាំបាច់ត្រូវគិតគូរពីលទ្ធភាពជំរុញការវិនិយោគលើឧស្សាហកម្មគាំទ្រ ដើម្បីបម្រើដល់វិស័យនេះ ជាអាទិ៍ត្រូវផ្តោតលើការវិនិយោគលើឧស្សាហកម្មផលិតកំណាត់ និងរោងចក្រសហគ្រាសផលិតផលវាយនភណ្ឌផ្សេងទៀត ដើម្បីបម្រើឱ្យវិស័យនេះ។ បន្ថែមលើនេះទៀត កម្ពុជាក៏ត្រូវជំរុញការវិនិយោគលើឧស្សាហកម្មបន្ទាប់បន្សំផងដែរ។ លទ្ធភាពក្នុងការវិនិយោគលើឧស្សាហកម្មបន្ទាប់បន្សំ ត្រូវបានបែងចែកទៅជា៣ប្រភេទសំខាន់ៗ ដូចជា១-ឧស្សាហកម្មបន្ទាប់បន្សំមូលដ្ឋាន រាប់បញ្ចូលអំបោះ ខ្សែរូត ឡេវយីហោបិទលើទំនិញ ក្បាច់ ខ្សែយឺត និងប៊ូជាដើម ២-ឧស្សាហកម្មបន្ទាប់បន្សំជាសម្ភារៈតុបតែង រាប់បញ្ចូលគ្រឿងតុបតែង ខ្សែរន្ធឡេវ និងខ្សែដេរភ្ជាប់ជាដើម និង៣-ឧស្សាហកម្មបន្ទាប់បន្សំសម្រាប់បញ្ចប់ការផលិតឬសម្ភារៈវេចខ្ចប់ រាប់បញ្ចូលស្លាកតម្លៃ ចង់ប្លាស្ទិក កាតុង និងបន្ទះការក្រដាស ឬផ្ទាំងប្លាស្ទិកជាដើម។ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការ ដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០២២-២០២៤÷**

- ជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសសម្រាប់រោងចក្រផលិតកំណាត់និងរោងចក្រផលិតផលវាយនភណ្ឌផ្សេងទៀត ដើម្បីបម្រើឱ្យវិស័យនេះនិងតម្រូវការទីផ្សារក្នុងតំបន់ ដោយមានយន្តការលើកទឹកចិត្តវិនិយោគពិសេស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការរៀបចំក្របខ័ណ្ឌនិយតកម្មច្បាស់លាស់ រួមមានការគ្រប់គ្រងប្រព័ន្ធប្រព្រឹត្តិកម្មសំណល់ឧស្សាហកម្មនិងគ្រោះថ្នាក់ ដើម្បីកិច្ចការពារបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព។

- ជំរុញការបង្កើតរោងចក្រឧស្សាហកម្មបន្ទាប់បន្សំ ដើម្បីគាំទ្រដល់វិស័យនេះ តាមរយៈការផ្តល់ការលើកទឹកចិត្តដែលមានស្រាប់និងថ្មី ស្របតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានិងបទប្បញ្ញត្តិពាក់ព័ន្ធ។
- លើកកម្ពស់ការប្រើប្រាស់ធនធាននៅក្នុងឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូប ស្របតាមមូលដ្ឋានសេដ្ឋកិច្ចក្រា(Circular Economy) និងការកែច្នៃឡើងវិញលើកំណាត់ សម្ភារៈបន្ទាប់បន្សំ និងវត្ថុធាតុដើមផ្សេងទៀត ប្រកបដោយប្រសិទ្ធភាពនិងចីរភាព។
- ធ្វើឱ្យប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្មនៅតាមច្រកពាណិជ្ជកម្មអន្តរជាតិ ជាអាទិ៍ផ្លូវអាកាស ផ្លូវគោក និងផ្លូវទឹក ព្រមទាំងកាត់បន្ថយចំណាយធុរកិច្ច ស្របតាមការអនុវត្តវិធានការកែទម្រង់ស៊ីជម្រៅពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។
- លើកទឹកចិត្តនិងជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញតាមជម្រើសមួយ ដែលមានប្រសិទ្ធភាព និងបន្តពិនិត្យថ្លៃអគ្គិសនីបន្តទៀត តាមពេលវេលាសមស្រប។
- ផ្តល់ការគាំទ្រដល់ឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូបក្នុងការសម្របខ្លួន និងឆ្លើយតបទៅនឹងការប្រែប្រួលទីផ្សារ និងតម្រូវការបច្ចេកវិទ្យាក្នុងក្របខ័ណ្ឌបដិវត្តន៍ឧស្សាហកម្មទី៤ ដែលអាចប៉ះពាល់យ៉ាងខ្លាំងដល់ខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃនៅក្នុងវិស័យកាត់ដេរសកលនិងនៅកម្ពុជា។

**វិធានការរយៈពេលមធ្យម ២០២៥-២០២៧៖**

- បន្តផ្តល់ការគាំទ្រដល់ឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូប ក្នុងការសម្របខ្លួន និងឆ្លើយតបទៅនឹងការប្រែប្រួលទីផ្សារ និងតម្រូវការបច្ចេកវិទ្យាក្នុងក្របខ័ណ្ឌបដិវត្តន៍ឧស្សាហកម្មទី៤។
- បន្តពង្រឹងវិធានការរយៈពេលខ្លីខាងលើ ដើម្បីទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រ សម្រាប់បម្រើឱ្យវិស័យនេះ។

### ៦.៥. ជំរុញការធ្វើពិពិធកម្មទីផ្សារសម្រាប់ការនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងកាបូប

ការធ្វើពិពិធកម្មទីផ្សារសម្រាប់ការនាំចេញផលិតផលកាត់ដេរ ផលិតផលស្បែកជើង និងកាបូប ដើម្បីពង្រីកការនាំចេញទៅកាន់ទីផ្សារបន្ថែមទៀត និងកាត់បន្ថយការពឹងផ្អែកលើសលប់លើទីផ្សារមួយចំនួន។ រហូតមកដល់ពេលនេះ ផលិតផលកម្ពុជាពុំទាន់បានពង្រីកខ្លួនចូលទីផ្សារធំៗ និងប្រកបដោយសក្តានុពលផ្សេងទៀតដែលមានតម្រូវការខ្លាំងឱ្យបានទូលំទូលាយនៅឡើយទេ ដូចជាប្រទេសជប៉ុន កូរ៉េខាងត្បូង កាណាដា និងទីផ្សារដែលកំពុងរីកលូតលាស់ រួមមានចិន ឥណ្ឌា និងប្រេស៊ីលជាដើម។ ដោយយោងទៅតាមការវិវត្តថ្មីៗ ជាពិសេសពាក់ព័ន្ធនឹងការព្យួរភាពអនុគ្រោះពន្ធលើទំនិញមួយចំនួន ក្រោមប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ(EBA) និងភាពមិនច្បាស់លាស់នៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP) ដោយសារការឈានឡើងនៃសេដ្ឋកិច្ចកម្ពុជាឬហេតុផលផ្សេងទៀត ការប្រកួតប្រជែងមានការកើនឡើងពីប្រទេសវៀតណាម មីយ៉ាន់ម៉ា បង់ក្លាដែស និងបណ្តាប្រទេសនៅទ្វីបអាហ្វ្រិកមួយចំនួន និងរួមទាំងបញ្ហាប្រឈមដទៃទៀតរបស់កម្ពុជា រាជរដ្ឋាភិបាលចាំបាច់ត្រូវត្រៀមខ្លួនដោះស្រាយបញ្ហាប្រឈមនិងចាប់យកកាលានុវត្តភាព។ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

**វិធានការរយៈពេលខ្លី ២០២២-២០២៤៖**

- សិក្សាពីនិន្នាការតំបន់និងសកលលើតម្រូវការទីផ្សារនៃផលិតផលកាត់ដេរ ស្បែកជើង និងកាបូប ដែលមានមូលដ្ឋានផលិតកម្មនិងការបញ្ជាទិញនៅកម្ពុជា ព្រមទាំងសិក្សាលើសមត្ថភាពប្រកួតប្រជែងរបស់វិស័យនេះនៅកម្ពុជា ដើម្បីជាមូលដ្ឋានក្នុងការពិនិត្យលទ្ធភាពរៀបចំនិងស្នើសុំអាណត្តិធ្វើការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី(FTA)។
- ត្រៀមលក្ខណសម្បត្តិចរចាជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីរក្សានូវប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP)។
- ជំរុញការអនុវត្តវិធានការពាក់ព័ន្ធនឹងវិស័យនេះនៅក្នុង**យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០១៩-២០២៣** សម្រាប់គាំទ្រការធ្វើពិពិធកម្មទីផ្សារនាំចេញរបស់កម្ពុជា។

**វិធានការរយៈពេលមធ្យម ២០២៥-២០២៧៖**

- ពិនិត្យលទ្ធភាពស្នើសុំចរចាជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីដាក់បញ្ចូលផលិតផលប្រភេទស្បែកជើងទៅក្នុងប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP) ដែលបច្ចុប្បន្នផ្តល់ជាចម្បងលើផលិតផលធ្វើដំណើរ។
- បង្កើនលទ្ធភាពក្នុងការបន្តចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី(FTA) ដើម្បីជំរុញការធ្វើពិពិធកម្មទីផ្សារនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងកាបូបកម្ពុជា។

## ៧. ការរៀបចំយន្តការស្ថាប័នសម្រាប់តាមដាននិងវាយតម្លៃការអនុវត្តវិធានការ

វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជាបានឈានមកដល់បរិបទមួយ ដែលផ្តល់ជាកាលានុវត្តភាពក្នុងការកែប្រែរចនាសម្ព័ន្ធ និងពង្រឹងមូលដ្ឋានពិពិធកម្មនិងសមត្ថភាពប្រកួតប្រជែង ដើម្បីបង្កើនការចូលរួមចំណែកដល់គោលដៅអភិវឌ្ឍន៍កាន់តែប្រសើរ។ ការខកខានមិនបានអនុវត្តវិធានការបានដាក់ចេញក្នុងយុទ្ធសាស្ត្រនេះ ដើម្បីចាប់យកកាលានុវត្តភាពខាងលើ អាចជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍកម្ពុជាក្នុងបរិការណ៍នៃការប្រែប្រួលយ៉ាងឆាប់រហ័សនៃនិម្មាបនកម្មតំបន់និងពិភពលោក។

ជាកត្តាសត្យានុម័ត កិច្ចសម្របសម្រួលអន្តរស្ថាប័នជាមួយតួអង្គពាក់ព័ន្ធជាកត្តាចាំបាច់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រនេះដោយជោគជ័យ។ ការរៀបចំយន្តការស្ថាប័នប្រកបដោយកិច្ចសម្របសម្រួល ដែលមានប្រសិទ្ធភាពនិងមានភាពប្រទាក់ក្រឡា ជាបុរេលក្ខខណ្ឌដើម្បីឈានទៅសម្រេចចក្ខុវិស័យនៃយុទ្ធសាស្ត្រនេះ។ ដោយឡែកដោយមិនរាប់បញ្ចូលនូវវិធានការខាងលើក្នុង***<u>ចំណុច ក.</u>*** *ពាក់ព័ន្ធនឹងការលើកកម្ពស់ភាពប្រកួតប្រជែង* និង***<u>ចំណុច ខ.</u>*** *ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ដែលមានក្របខ័ណ្ឌតាមដានការអនុវត្តដាច់ដោយឡែក* ការអនុវត្តវិធានការជាយុទ្ធសាស្ត្រខាងលើក្នុង***<u>ចំណុច គ.</u>*** ទាមទារឱ្យមានការកំណត់យន្តការអន្តរស្ថាប័ននិងការទទួលខុសត្រូវតាមក្រសួង ស្ថាប័នពាក់ព័ន្ធច្បាស់លាស់។

### ៧.១. រចនាសម្ព័ន្ធនៃការរៀបចំយន្តការស្ថាប័ន

រាជរដ្ឋាភិបាលបានពិនិត្យឃើញនូវភាពចាំបាច់ក្នុងការរៀបចំយន្តការអន្តរស្ថាប័នទទួលបន្ទុកសម្របសម្រួលនិងតាមដានការអនុវត្តយុទ្ធសាស្ត្រសម្រាប់វិស័យនេះ ក្រោមការដឹកនាំរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(គ.ស.ហ.) ដែលនឹងធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធលើការអនុវត្ត

វិធានការ ផ្តល់អនុសាសន៍ និងរាយការណ៍ពីវឌ្ឍនភាពជូនប្រមុខរាជរដ្ឋាភិបាល។ ក្នុងដំណាក់កាលអនុវត្តវិធានការ ក្រសួង ស្ថាប័នទទួលបន្ទុកត្រូវរៀបចំផែនការសកម្មភាពជាក់លាក់និងពេលវេលាកំណត់ជាក់លាក់ តាមមុខសញ្ញាសកម្មភាពនៃវិធានការនីមួយៗ ក្រោមការត្រួតពិនិត្យរបស់គ.ស.ហ. និងមានការសម្របសម្រួលដោយក្រុមការងារអន្តរស្ថាប័នទទួលបន្ទុកសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រ ដែលជាផ្នែកមួយនៃយន្តការអន្តរស្ថាប័ន។

រាជរដ្ឋាភិបាល ក៏នឹងពិនិត្យលទ្ធភាពអនុញ្ញាតឱ្យមានការបង្កើតក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ដែលមានសមាសភាពពីតំណាងវិស័យឯកជន ដៃគូអភិវឌ្ឍ ជំនាញការឯករាជ្យ តំណាងសមាគម និងសហជីពជាដើម ដើម្បីផ្តល់នូវប្រភពធាតុចូលមួយបន្ថែមទៀតសំដៅជួយសម្រួលដល់ការអនុវត្តយុទ្ធសាស្ត្រនេះឱ្យបានគ្រប់ជ្រុងជ្រោយផងដែរ។




## ៧.២. ក្រុមការងារអន្តរស្ថាប័នទទួលបន្ទុកសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រ

ក្រុមការងារអន្តរស្ថាប័នទទួលបន្ទុកសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រ ឬ «ក្រុមការងារអន្តរស្ថាប័ន» នឹងត្រូវបង្កើតឡើង ដោយមានសមាជិកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការដឹកនាំនិងសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន**គ.ស.ហ.** និងមានតួនាទីនិងភារកិច្ច ដូចខាងក្រោម÷

- សម្របសម្រួលនិងជំរុញការរៀបចំសូចនាករសមិទ្ធកម្មគន្លឹះ(KPIs) និងក្របខ័ណ្ឌពេលវេលារបស់ក្រសួង ស្ថាប័នទទួលបន្ទុក ក្នុងគោលបំណងរៀបចំផែនការសកម្មភាពលម្អិត ដើម្បីអនុវត្ត និងសម្រេចវិធានការនៅក្នុងយុទ្ធសាស្ត្រនេះ
- សហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុក ដើម្បីផ្តល់ការគាំទ្រដល់**គ.ស.ហ.** ក្នុងការរៀបចំយន្តការ/ក្របខ័ណ្ឌតាមដាននិងវាយតម្លៃ(M&E) នៃការអនុវត្តយុទ្ធសាស្ត្រនេះ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នទទួលបន្ទុកក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប តាមយន្តការដែលមានស្រាប់ មុននឹងបញ្ជូនសំណើទៅ**គ.ស.ហ.** ដើម្បីពិនិត្យ និងបន្តនីតិវិធីជាធរមាន

- សម្របសម្រួលជាមួយក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ដើម្បីពិភាក្សាការងារនិងដោះស្រាយរាល់កង្វល់និងបញ្ហាប្រឈមក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប
- បំពេញតួនាទីជាច្រកចេញ ចូលមួយនៃទំនាក់ទំនងសាធារណៈជាមួយដៃគូពាក់ព័ន្ធក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប
- រាយការណ៍ជូន**គ.ស.ឃ.** អំពីវឌ្ឍនភាពការងារនិងការអនុវត្តយុទ្ធសាស្ត្រ
- ស្នើសុំការពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រនេះ ក្នុងករណីចាំបាច់
- បំពេញភារកិច្ចដទៃទៀត។

### ៧.៣. ក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប

ក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប គឺជាក្រុមការងារចំពោះកិច្ចមួយដែលអាចនឹងត្រូវបានបង្កើតឡើង ដើម្បីផ្តល់ប្រភពធាតុចូលមួយផ្សេងទៀត សំដៅជួយសម្រួលដល់ការអនុវត្តយុទ្ធសាស្ត្រនេះឱ្យមានប្រសិទ្ធភាព។ ក្រុមការងារនេះ ក៏នឹងបំពេញមុខងារជាផ្នែកមួយនៃប្រព័ន្ធប្រតិគុលភាព និងបំពេញបន្ថែម ជាពិសេសការផ្តល់មតិយោបល់និងអនុសាសន៍ជូន**គ.ស.ឃ.** លើការអនុវត្តយុទ្ធសាស្ត្រនេះ។ ក្រុមការងារនេះ មានតួនាទីនិងភារកិច្ចដូចតទៅ÷

- ផ្តល់មតិយោបល់និងអនុសាសន៍ជូន**គ.ស.ឃ.**
- សហការជាមួយក្រុមការងារអន្តរស្ថាប័ន និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ធាតុចូល ដើម្បីរៀបចំផែនការសកម្មភាព សម្រាប់ការអនុវត្តយុទ្ធសាស្ត្រនេះ
- ចូលរួមរៀបចំយន្តការ/ក្របខ័ណ្ឌតាមដាននិងវាយតម្លៃ(M&E) សម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ
- ចូលរួមកិច្ចប្រជុំ ដើម្បីតាមដានលើវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រនេះ
- កៀរគរការគាំទ្រពីភាគីពាក់ព័ន្ធ ទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្រនេះ
- បំពេញភារកិច្ចដទៃទៀត។

## ៨. ការគ្រប់គ្រងហានិភ័យ

ការប្រែប្រួលនិម្មាបនកម្មតំបន់និងពិភពលោក រួមជាមួយលក្ខខណ្ឌក្នុងស្រុក អាចបង្កហានិភ័យ ដែលអាចប៉ះពាល់ដោយផ្ទាល់និងប្រយោលដល់ការអនុវត្ត**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧**នេះ។ ការណ៍នេះ តម្រូវឱ្យរាជរដ្ឋាភិបាលត្រូវត្រៀមលក្ខណសម្បត្តិប្រកបដោយភាពបុរេសកម្ម ការប្រុងប្រយ័ត្ន និងការយកចិត្តទុកដាក់លើហានិភ័យធំៗមួយចំនួន ដែលអាចជះឥទ្ធិពលដល់វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រនេះ។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ហានិភ័យធំៗ ជាអាទិ៍ដូចខាងក្រោម÷

### ៨.១. ហានិភ័យខាងក្រៅដែលកើតចេញពីការប្រែប្រួលក្នុងតំបន់និងពិភពលោក

ចរិតសកលនៃខ្សែច្រវាក់ផ្គត់ផ្គង់ឬខ្សែច្រវាក់តម្លៃផលិតផលកាត់ដេរ ស្បែកជើង និងកាបូប រួមជាមួយនឹងការបើកចំហនៃសេដ្ឋកិច្ចកម្ពុជា បានធ្វើឱ្យវិស័យនេះអាចងាយទទួលរងឥទ្ធិពលពីការប្រែប្រួលនិម្មាបនកម្មតំបន់

និងពិភពលោក។ ហានិភ័យ អាចកើតចេញពីនិន្នាការកើនឡើងនៃឥរិយាបថគាំពារនិយមក្នុងពាណិជ្ជកម្មអន្តរជាតិ បញ្ហាសន្តិសុខថាមពល ការបង្វែរលំហូរនៃការវិនិយោគផ្ទាល់បរទេសពីកម្ពុជាទៅប្រទេសដែលជាគូប្រកួតប្រជែងរបស់កម្ពុជា ការបង្អាក់ដល់ខ្សែច្រវាក់ផលិតកម្ម(ជាអាទិ៍ការខ្វះវត្ថុធាតុដើមនិងការផ្អាក/បិទរោងចក្រ សហគ្រាសដែលបណ្តាលមកពីការឆ្លងរាលដាលជំងឺកូវីដ-១៩) បម្រែបម្រួលលក្ខខណ្ឌអាកាសធាតុ និងភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយជាដើម។ បន្ថែមលើហានិភ័យនៃការព្យួរប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់លើកលែងអាវុធ(EBA) លើទំនិញមួយចំនួនដោយសហភាពអឺរ៉ុប ស្ថានភាពមិនច្បាស់លាស់នៃប្រព័ន្ធអនុគ្រោះGSP របស់សហរដ្ឋអាមេរិក ក៏អាចត្រូវកើតមានជាយថាហេតុមកលើវិស័យនេះផងដែរ។

ក្រៅពីហានិភ័យខាងលើ វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា អាចនឹងជួបប្រទះហានិភ័យបច្ចេកវិទ្យា ដែលជះឥទ្ធិពលលើផលិតកម្ម និងកម្លាំងពលកម្មក្នុងរយៈពេលមធ្យមនិងវែង ជាពិសេសបច្ចេកវិទ្យាស្វ័យប្រវត្តិកម្ម និងនវានុវត្តន៍នៃបដិវត្តន៍ឧស្សាហកម្មទី៤ មួយចំនួនដូចជាការប្រើប្រាស់ការបោះពុម្ព3D(3D printing) បច្ចេកវិទ្យាស្កេនរាងកាយ ការរចនាម៉ូដដោយកុំព្យូទ័រ(CAD) និងម៉ាស៊ីនស្វ័យប្រវត្តិ ដែលអាចជំនួសកម្លាំងពលកម្មមានជំនាញទាប និងផ្តល់លទ្ធភាពឱ្យរោងចក្រឬអ្នកផលិតកែប្រែយ៉ាងឆាប់រហ័សលើផលិតផលឱ្យស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់។ ហានិភ័យទាំងនេះ អាចដាក់សម្ពាធខ្លាំងលើលទ្ធភាពនៃការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច សមត្ថភាពប្រកួតប្រជែង ផលិតភាព និងអនាគតនៃការអភិវឌ្ឍនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ប្រកបដោយចីរភាពនិងបរិយាប័ន្នផងដែរ។

### ៨.២. ហានិភ័យក្នុងស្រុកពាក់ព័ន្ធនឹងការគ្រប់គ្រងបញ្ហាម៉ាក្រូសេដ្ឋកិច្ច

វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបក៏ជួបប្រទះនឹងហានិភ័យបាត់បង់ជាបណ្តើរៗនៃឧត្តមភាពប្រកួតប្រជែង ជាពិសេសលើថ្លៃផលិតកម្ម ដោយសារការកើនឡើងជាលំដាប់នៃប្រាក់ឈ្នួលអប្បបរមា ក្នុងករណីការកើនឡើងនេះមិនត្រូវបានប៉ះប៉ូវដោយការកើនឡើងនៃកម្រិតផលិតភាពបានសមស្របនោះទេ។ ដើម្បីគ្រប់គ្រងហានិភ័យនេះ រាជរដ្ឋាភិបាលត្រូវបន្តជំរុញឱ្យមានកំណើនប្រាក់ឈ្នួលដែលអាចប៉ាន់ប្រមាណបាន និងត្រូវចាត់វិធានការផ្សេងទៀតលើបញ្ហាថ្លៃម្ហូបអាហារ ដើម្បីរក្សាអត្រាអតិផរណាឱ្យនៅក្នុងកម្រិតសមរម្យ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏ត្រូវជំរុញការធ្វើកំណែទម្រង់វិស័យអប់រំបន្ថែមទៀត វិនិយោគលើការអភិវឌ្ឍជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ឱ្យស្របតាមនិងបំពេញបន្ថែមដល់ការអនុវត្ត**គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥** និងបន្តធ្វើឱ្យបរិយាកាសធុរកិច្ចទាំងមូលប្រសើរឡើង តាមរយៈការអនុវត្តវិធានការកែទម្រង់ស៊ីជម្រៅ ដើម្បីទាក់ទាញការវិនិយោគដែលមានគុណភាពនិងមានតម្លៃបន្ថែមខ្ពស់លើវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប។

### ៨.៣. ហានិភ័យដែលកើតចេញពីបញ្ហានយោបាយ

ការប្រែប្រួលនៃនិម្មាបនកម្មនយោបាយនិងឥទ្ធិពលនៃបញ្ហានយោបាយលើឥរិយាបថរបស់អ្នកបញ្ជាទិញ អាចមានផលប៉ះពាល់យ៉ាងខ្លាំងដល់ការវិវត្តនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប។ ស្ថិរភាពនយោបាយជាបុរេលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍ ដែលមិនអាចមើលស្រាលនិងមើលរំលងបានឡើយ ព្រោះទំនុកចិត្តរឹងមាំរបស់

វិនិយោគិនចាក់ឫសនឹងស្ថិរភាពនយោបាយ។ ផ្ទុយទៅវិញ បញ្ហានយោបាយដូចជាអស្ថិរភាពនយោបាយក្នុងទម្រង់ជាការចលាចល ការងើបឡើងបះបោរ ឬការរំខានជាហានិភ័យមួយ ដែលអាចជះឥទ្ធិពលអវិជ្ជមានដល់កិច្ចប្រឹងប្រែងអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ព្រមទាំងគោលដៅអភិវឌ្ឍន៍រយៈពេលវែងរបស់កម្ពុជាផងដែរ។ ការណ៍នេះតម្រូវឱ្យរាជរដ្ឋាភិបាលគ្រប់គ្រងហានិភ័យនយោបាយនិងផ្តល់នូវធនធានឱ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់អាទិភាពវិធានការគោលនយោបាយ ដែលត្រូវដាក់ចេញក្នុងយុទ្ធសាស្ត្រនេះនិងបញ្ចៀសផលប៉ះពាល់ពីបញ្ហានយោបាយជាអតិបរមា។

### ៨.៤. ហានិភ័យពាក់ព័ន្ធនឹងកិច្ចសម្របសម្រួលអន្តរស្ថាប័ន

ការអនុវត្តយុទ្ធសាស្ត្រដោយជោគជ័យ អាស្រ័យលើសមត្ថភាពនៃការចូលរួមរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តវិធានការ ដែលមានការសម្របសម្រួលដោយក្រុមការងារអន្តរស្ថាប័ន ក្រោមការដឹកនាំដោយ **គ.ស.ហ.** ជាមួយក្រសួង ស្ថាប័ន និងតួអង្គពាក់ព័ន្ធនានា ដើម្បីសម្រេចនូវការអនុវត្តយុទ្ធសាស្ត្រនេះ។ ក្នុងន័យនេះ ដើម្បីជៀសវាងហានិភ័យនៃបញ្ហាដែលកើតចេញពីកង្វះកិច្ចសម្របសម្រួលអន្តរស្ថាប័នមិនមានប្រសិទ្ធភាព តម្រូវឱ្យមានការយកចិត្តទុកដាក់លើសមត្ថភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ការប្តេជ្ញា និងឆន្ទៈនយោបាយក្នុងការធ្វើការរួមគ្នា និងធ្វើកិច្ចអន្តរាគមន៍ ដើម្បីសម្រេចនូវចក្ខុវិស័យនៃយុទ្ធសាស្ត្រនេះ។

## ៩. សេចក្តីសន្និដ្ឋាន

ដើម្បីពង្រឹងពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចនិងសមត្ថភាពប្រកួតប្រជែង រាជរដ្ឋាភិបាលសម្រេចដាក់ចេញ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២ - ២០២៧**។ យុទ្ធសាស្ត្រនេះផ្តល់នូវទិសដៅរួមសម្រាប់ការអភិវឌ្ឍវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបបន្ថែមទៀត ប្រកបដោយចីរភាព និងបរិយាប័ន្ន និងជាផ្នែកមួយនៃកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ និងឆ្លើយតបទៅនឹងវិធានការគោល-នយោបាយដែលដាក់ចេញនៅក្នុង **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** ព្រមទាំងក្របខ័ណ្ឌគោលនយោបាយផ្សេងទៀតផងដែរ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃយុទ្ធសាស្ត្រនេះ ការអនុវត្តវិធានការ តម្រូវឱ្យមានកិច្ចសម្របសម្រួលអន្តរស្ថាប័នប្រសើរជាងមុន ការប្តេជ្ញា ការចូលរួមយ៉ាងសកម្ម អន្តរសកម្ម និងស្មារតីទទួលខុសត្រូវខ្ពស់ពីក្រសួង ស្ថាប័ន និងគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ដោយប្រកាន់ភ្ជាប់នូវអភិក្រមនិងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជាៈ **ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់** និង**កែទម្រង់ខាងក្នុងនិងបង្កើនមិត្តខាងក្រៅក្នុងស្មារតីពង្រឹងឯករាជ្យនិងអធិបតេយ្យភាពជាតិ**។

ការសម្រេចបាននូវសមិទ្ធផលនៃយុទ្ធសាស្ត្រនេះ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមផ្លាស់ប្តូរវិស័យនេះឱ្យទៅជាឧស្សាហកម្មមួយ ដែលមានចីរភាពបរិស្ថាន ភាពធន់ តម្លៃបន្ថែមខ្ពស់ កម្លាំងពលកម្ម ជំនាញ ទីកន្លែងធ្វើការសមរម្យនិងផលិតភាពខ្ពស់ សមាហរណកម្មទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃតំបន់និងពិភពលោក បរិយាកាសធុរកិច្ចល្អនិងភាពជាដៃគូល្អរវាងភាគីរដ្ឋ និយោជក សហជីព និងតួអង្គផ្សេងទៀត។ យុទ្ធ-សាស្ត្រនេះក៏នឹងចូលរួមចំណែកក្នុងការបង្កើនសមត្ថភាពប្រកួតប្រជែង ជំរុញការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះចាំបាច់ឆ្ពោះទៅសម្រេចបាននូវបង្គោលចរឆ្នាំ២០៣០និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ផងដែរ៕

## បរិសិដ្ឋៈ វិធានការជាយុទ្ធសាស្ត្រនិងផែនការសកម្មភាព

| វិធានការ | សកម្មភាព | | ក្រសួង ស្ថាប័នទទួលបន្ទុក |
|---|---|---|---|
| ១. បន្តពង្រឹងធនធានមនុស្សដើម្បីបង្កើនផលិតភាពនិងបង្កើតគន្លងអាជីពសម្រាប់កម្មករ និយោជិត | ២០២២-២០២៤ | - អនុវត្តការផ្ទេរតួនាទីអ្នកគ្រប់គ្រងថ្នាក់កណ្ដាល អ្នកបច្ចេកទេស និងជំនាញការផ្សេងៗជូនកម្លាំងពលកម្មក្នុងស្រុក ក្នុងរយៈពេល៣ឆ្នាំ ឬស្របតាមការកំណត់ដោយច្បាប់ស្ដីពីការងារ ឬ/និងក្របខ័ណ្ឌតំបន់និងអន្តរជាតិ ដោយជំរុញការវិនិយោគលើការអភិវឌ្ឍជំនាញនិងការបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈ ដើម្បីបង្កើនចំនួនកម្មករ និយោជិតក្នុងស្រុកដែលកាន់តួនាទីទាំងនោះ តាមរយៈការផ្ដល់ការលើកទឹកចិត្តវិនិយោគស្របតាមច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានិងបទប្បញ្ញត្តិពាក់ព័ន្ធ។ | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - រៀបចំនិងអនុវត្តបទដ្ឋានស្តង់ដារ/ ក្របខ័ណ្ឌសមត្ថភាព(Competency Standards/ Framework) ក្នុងការវាយតម្លៃកម្រិតសមត្ថភាពនិងផ្ដល់ការលើកទឹកចិត្តការងារជូនកម្មករ និយោជិតតាមកម្រិតសមត្ថភាព។ | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - សិក្សាពីតម្រូវការជំនាញ(Skills Mapping) នៅក្នុងវិស័យនេះក្នុងពេលបច្ចុប្បន្ននិងការសិក្សាពីការរំពឹងទុកនៃតម្រូវការជំនាញ(Skills Anticipation) ក្នុងរយៈពេល៥-១០ឆ្នាំទៅមុខ ដើម្បីផ្ដល់លទ្ធភាពឱ្យឧស្សាហកម្មនេះ និងជាពិសេសកម្មករ និយោជិតអាចធ្វើការសម្របខ្លួនជាមួយនឹងនិន្នាការសំខាន់ៗ រួមមានស្វ័យប្រវត្តិកម្មលើខ្សែច្រវាក់ផលិតកម្មនិងការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថលផ្សេងៗជាដើម។ | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - ជំរុញនិងបង្កើនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ជំនាញ(SDF) ដើម្បីលើកកម្ពស់ជំនាញបច្ចេកទេសជំនាញគ្រប់គ្រងនិងជំនាញផ្សេងៗទៀតដែលចាំបាច់សម្រាប់គាំទ្រដល់វិស័យនេះជាពិសេស ដោយផ្អែកលើលទ្ធផលសិក្សាតម្រូវការជំនាញនិងការសិក្សា | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | | ការរំពឹងទុកនៃតម្រូវការជំនាញខាងលើ។ | - ក្រុមការងារអន្តរស្ថាប័ន |
| | | - បង្កើនការវិនិយោគនិងបន្តលើកកម្ពស់តួនាទីរបស់វិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា(CGTI) បន្ថែមទៀតឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការអនុវត្តយន្តការគាំទ្រដែលមានស្រាប់ឬ/និងដែលត្រូវការបង្កើតថ្មី ដូចជាកម្មវិធីអាហារូបករណ៍ពិសេស ដោយមានការសហការជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) សមាគមស្បែកជើងកម្ពុជា(CFA) បណ្តារោងចក្រ និងភាគីពាក់ព័ន្ធ សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់វិស័យនេះបានមួយកម្រិតទៀតនិងកាន់តែប្រសើរ។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន<br>- ដៃគូអភិវឌ្ឍពាក់ព័ន្ធ |
| | | - សហការជាមួយភាគីពាក់ព័ន្ធ ជាពិសេសដៃគូអភិវឌ្ឍនិងវិនិយោគិនបរទេស ដើម្បីពិនិត្យលទ្ធភាពបង្កើតស្ថាប័នអភិវឌ្ឍជំនាញនិងបណ្តុះបណ្តាលវិជ្ជាជីវៈបន្ថែមទៀត ដូចជាវិទ្យាស្ថាន/ មជ្ឈមណ្ឌល/ សាលាបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ស្របតាមតម្រូវការឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូប។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន<br>- ដៃគូអភិវឌ្ឍពាក់ព័ន្ធ |
| | | - ជំរុញនិងលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធ ជាពិសេសបណ្តារោងចក្រ ដើម្បីជំរុញការអភិវឌ្ឍជំនាញ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់កម្មករ និយោជិតនៅតាមរោងចក្រផ្ទាល់(In-housing/On-the-job Trainings) និងតាមរយៈការប្រើប្រាស់សេវាកម្មរបស់ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ ដើម្បីផ្តល់ ការបណ្តុះបណ្តាលលើជំនាញនិងវគ្គវិញ្ញាបនបត្របច្ចេកទេសវិជ្ជាជីវៈតាមកម្រិត រួមមាន÷ កម្មវិធីបណ្តុះបណ្តាលភាសា ជំនាញការបញ្ជាទិញ ឡូជីស្ទីក ការគ្រប់គ្រងច្រវាក់ផ្គត់ផ្គង់ ចំណេះដឹងបច្ចេកវិទ្យាឌីជីថល ភាពជាអ្នកដឹកនាំ ការគ្រប់គ្រង ការត្រួតពិនិត្យ និងទំនាក់ទំនងព្រមទាំងទំនាក់ទំនងវិជ្ជាជីវៈ ជាដើម។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |

| | | | |
|---|---|---|---|
| | | - ជំរុញការអនុវត្តវិធានការពាក់ព័ន្ធនឹងវិស័យនេះនៅក្នុង**គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥**។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | ២០២៥-២០២៧ | - លើកទឹកចិត្តដល់គ្រឹះស្ថានឧត្តមសិក្សានិងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទាំងសាធារណៈនិងឯកជន ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាដែលជាតម្រូវការសម្រាប់វិស័យនេះ ដូចជា÷ ជំនាញផ្នែកវាយនភណ្ឌ ជំនាញរចនា ជំនាញវិស្វកម្មឧស្សាហកម្ម ជំនាញការបញ្ជាទិញ ឡូជីស្ទីក ការគ្រប់គ្រងច្រវាក់ផ្គត់ផ្គង់ និងជំនាញភាពជាអ្នកដឹកនាំនិងគ្រប់គ្រងជាដើមឬសហការជាមួយសាកលវិទ្យាល័យ ឬវិទ្យាស្ថានដែលផ្តល់កម្មវិធីឬវគ្គសិក្សានេះស្រាប់ ទាំងនៅក្នុងស្រុក និងនៅក្រៅប្រទេស។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - លើកទឹកចិត្តនិងពិនិត្យលទ្ធភាពក្នុងការគាំទ្រផ្នែកធនធានហិរញ្ញវត្ថុក្នុងការបញ្ជូននិស្សិតនិងនិយោជិតកម្ពុជាដែលមានសក្តានុពលទៅបន្តការសិក្សាជំនាញចាំបាច់ក្នុងវិស័យនេះនៅសាកលវិទ្យាល័យនិងវិទ្យាស្ថាននៅក្រៅប្រទេស។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - បន្តពង្រឹងវិធានការរយៈពេលខ្លីពាក់ព័ន្ធខាងលើ ក្នុងគោលបំណងលើកកម្ពស់ធនធានមនុស្ស ដើម្បីបង្កើនផលិតភាពនិងបង្កើតគន្លងអាជីពសម្រាប់កម្មករ និយោជិត។ | - ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| ២. បន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនិងសុខុមាលភាពរបស់កម្មករនិយោជិត | ២០២២-២០២៤ | - បន្តពង្រឹងវប្បធម៌អនុលោមភាពក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប តាមរយៈការប្រើប្រាស់របាយការណ៍វាយតម្លៃរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC) និងការធ្វើវិចារណកម្មអធិការកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដើម្បីបន្តពង្រឹងការអនុវត្តវិធានការអធិការកិច្ចការងារឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន<br>- ដៃគូអភិវឌ្ឍពាក់ព័ន្ធ |
| | | - បន្តជំរុញការកសាងសមត្ថភាពនិងការផ្លាស់ប្តូរចំណេះដឹងរវាងគម្រោងរោងចក្រកាន់តែ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | |
|---|---|---|---|
| | | ប្រសើរនៅកម្ពុជា(BFC) និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងឆ្លើយតបទៅនឹងបរិការណ៍កម្ពុជា។ | - ក្រុមការងារអន្តរស្ថាប័ន<br>- ដៃគូអភិវឌ្ឍពាក់ព័ន្ធ |
| | | - ពង្រឹងតួនាទីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងស្ថាប័នពាក់ព័ន្ធ ក្នុងយន្តការផ្សះផ្សាវិវាទនៅកម្រិតរោងចក្រ សហគ្រាស និងកម្រិតក្រសួង និងលើកកម្ពស់ ការចូលរួមប្រកបដោយវិជ្ជាជីវៈរបស់តំណាងភាគីវិវាទ ជាពិសេសភាគីកម្មករ និយោជិតក្នុងការដោះស្រាយវិវាទការងារ។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន<br>- ដៃគូអភិវឌ្ឍពាក់ព័ន្ធ |
| | | - ផ្តល់លំហសម្រាប់ការចរចាអនុសញ្ញារួម(CBA) រវាងសហជីពកម្មករ និយោជិតនិងនិយោជក ក្នុងកម្រិតសហគ្រាស រោងចក្រនិងក្រុមម្ចាស់ម៉ាកផលិតផល តាមតម្រូវការនិងលទ្ធភាពជាក់ស្តែង។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន<br>- ដៃគូអភិវឌ្ឍពាក់ព័ន្ធ |
| | | - ជំរុញនិងលើកកម្ពស់សមត្ថភាពនិងការយល់ដឹងរបស់ប្រតិភូបុគ្គលិក ថ្នាក់ដឹកនាំសហជីពជាពិសេសថ្នាក់ដឹកនាំសហជីពមូលដ្ឋាននៅតាមរោងចក្រ សហគ្រាស ក៏ដូចជាអ្នកគ្រប់គ្រងធនធានមនុស្សនិងរដ្ឋបាលរបស់រោងចក្រ សហគ្រាស។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន<br>- ដៃគូអភិវឌ្ឍពាក់ព័ន្ធ |
| | | - បន្តពង្រឹងតួនាទីនិងផ្តល់ការគាំទ្រចាំបាច់ដល់យន្តការនិងដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីឱ្យបន្តស្ថិតនៅជាស្ថាប័នប្រកបដោយវិជ្ជាជីវៈ អព្យាក្រឹត និងឯករាជ្យក្នុងការដោះស្រាយវិវាទការងារ ស្របតាមស្មារតីនៃការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារពាក់ព័ន្ធនឹងការដោះស្រាយវិវាទការងារ រួមទាំងវិវាទការងារបុគ្គលផងដែរ។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - ពង្រឹងសុវត្ថិភាពនិងផាសុកភាពនៃមធ្យោបាយដឹកជញ្ជូនកម្មករ និយោជិត តាមរយៈការបង្កើតយន្តការគាំទ្រមួយជាក់លាក់ រួមមាន ការពិនិត្យលទ្ធភាពផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដោយត្រង់ពីនិយោជកដល់អ្នកផ្តល់សេវាដឹកជញ្ជូនដែលប្រើប្រាស់មធ្យោបាយ | - ក្រសួងមហាផ្ទៃ<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | |
|---|---|---|---|
| | | ដឹកជញ្ជូនថ្មីមានលក្ខខណ្ឌសុវត្ថិភាពប្រសើរជាងមុន ផ្តល់កម្ចីដែលមានការប្រាក់ទាបសមរម្យជូនអ្នកផ្តល់សេវាបើកបរឱ្យមានលទ្ធភាពប្រើប្រាស់រថយន្តដឹកជញ្ជូនកម្មករនិយោជិត ប្រកបដោយសុវត្ថិភាពនិងតម្រូវឱ្យមានធានារ៉ាប់រង និងផ្តល់ការលើកទឹកចិត្តផ្នែកពន្ធគយសម្រាប់ការនាំចូលមធ្យោបាយដឹកជញ្ជូន ដើម្បីបម្រើឱ្យវិស័យនេះជាដើម។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - ពង្រឹងសុវត្ថិភាពការដឹកជញ្ជូនកម្មករ និយោជិត តាមរយៈការពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ ដោយធ្វើការសម្របសម្រួលចរាចរណ៍នៅមុខរោងចក្រ ជាពិសេសនៅអំឡុងពេលចេញនិងចូលធ្វើការ ដើម្បីកាត់បន្ថយការកកស្ទះនិងគ្រោះថ្នាក់ និងការផ្តល់នូវវគ្គបណ្តុះបណ្តាលសម្រាប់អ្នកបើកបរអំពីការអនុវត្តការបើកបរសុវត្ថិភាព/គ្មានសុវត្ថិភាព បញ្ហាសុវត្ថិភាពចរាចរណ៍ និងអាកប្បកិរិយាដែលមានការទទួលខុសត្រូវក្នុងចំណោមអ្នកបើកបរនិងកម្មករ និយោជិតជាដើម។ | - ក្រសួងមហាផ្ទៃ<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - ពង្រឹងការគ្រប់គ្រងការបញ្ចេញសំណល់រឹង រាវ និងឧស្ម័ន ដើម្បីរួមចំណែកក្នុងកិច្ចគាំពារបរិស្ថាននិងសុខុមាលភាពប្រជាពលរដ្ឋ។ | - ក្រសួងបរិស្ថាន<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - ពង្រឹងសុខភាពនិងសុវត្ថិភាពការងារ(OSH) នៅតាមរោងចក្រ សហគ្រាស ដើម្បីលើកកម្ពស់លក្ខខណ្ឌការងារ រួមមានសុវត្ថិភាពផ្នែកសំណង់ ផ្នែកសារធាតុគីមី ផ្នែកអគ្គីភ័យ ផ្នែកជំងឺឆ្លងរាលដាល និងការត្រៀមខ្លួនពេលមានអាសន្នណាមួយជាដើម។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន<br>- ដៃគូអភិវឌ្ឍពាក់ព័ន្ធ |
| | | - ពង្រឹងសុខុមាលភាពនៅកន្លែងធ្វើការងាររបស់កម្មករ និយោជិត តាមរយៈការធ្វើឱ្យប្រសើរឡើងនូវខ្យល់ បរិយាកាសនៅក្នុងអគារការងារ និងការគ្រប់គ្រងការបញ្ចេញសំណល់រឹង រាវ និងឧស្ម័នពីរោងចក្រ រួមទាំងការបោះចោលសំណល់និងសំរាមពីសំណាក់កម្មករ និយោជិត។ | - ក្រសួងបរិស្ថាន<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |

| | | | |
|---|---|---|---|
| | | - ពង្រឹងសុខុមាលភាពអាហារូបត្ថម្ភរបស់កម្មករ និយោជិត តាមរយៈការផ្ដោតសំខាន់លើទិដ្ឋភាព÷ សេវាកម្មផ្គត់ផ្គង់តម្រូវការអាហារូបត្ថម្ភ ថ្លៃសមរម្យនៃអាហារូបត្ថម្ភ និងការផ្ដល់កន្លែងអាហារដ្ឋានស្តង់ដារមួយ តាមរយៈការអនុវត្តការសាងសង់អាហារដ្ឋាននៅតាមរោងចក្រឱ្យបានតឹងរ៉ឹង។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - ជំរុញនិងលើកទឹកចិត្តភាគីពាក់ព័ន្ធឱ្យគាំទ្រដល់ការអនុវត្តគម្រោងលំនៅឋានតម្លៃសមរម្យ ជាពិសេស ផ្តល់ការលើកទឹកចិត្តដល់កម្មករ និយោជិតឱ្យមានលទ្ធភាពទិញលំនៅឋានតម្លៃសមរម្យ ដើម្បីទទួលបានកន្លែងស្នាក់នៅសមរម្យនិងលើកកម្ពស់ការធានាបានផ្ទៃកការងារ ស្របតាម**គោលនយោបាយស្តីពីការលើកទឹកចិត្តនិងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ**។ | - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | ២០២៥-<br>២០២៧ | - ពិនិត្យលទ្ធភាពពង្រីកវិសាលភាពនៃការផ្តល់របបសន្តិសុខសង្គម ដែលផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម(បសស)បច្ចុប្បន្ន ជូនកម្មករ និយោជិត តាមការវិវត្តជាក់ស្តែងនៃវិស័យនេះ រួមមានការគិតគូរពីលទ្ធភាពនៃការផ្តល់អត្ថប្រយោជន៍ធានារ៉ាប់រងការងារជូនកម្មករ និយោជិតជាដើម។ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - បន្តពង្រឹងវិធានការរយៈពេលខ្លីពាក់ព័ន្ធខាងលើ ដើម្បីលើកកម្ពស់លក្ខខណ្ឌការងារនិងសុខុមាលភាពរបស់កម្មករ និយោជិត។ | - ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន<br>- ដៃគូអភិវឌ្ឍពាក់ព័ន្ធ |
| ៣. លើកកម្ពស់ការវិនិយោគក្នុងស្រុកនិងបរទេសក្នុងឧស្សាហកម្មដែល | ២០២២-<br>២០២៤ | - សិក្សាជាយុទ្ធសាស្ត្រស្តីពីតម្រូវការទីផ្សារនិងតម្រូវការវិនិយោគ(ទាំងការវិនិយោគថ្មីនិងការវិនិយោគឡើងវិញ) លើការផលិតនូវផលិតផលកាត់ដេរ ឬ/និងផលិតផលគាំទ្រមានថ្លៃខ្ពស់ មានតម្លៃបន្ថែមខ្ពស់ និង មានលក្ខណៈពិសេស ដើម្បីរៀបចំសកម្មភាពទាក់ទាញវិនិយោគិនមានសក្តានុពលទាំងនោះមកកម្ពុជា។ | - ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រុមការងារអន្តរស្ថាប័ន |

| | | | |
|---|---|---|---|
| មានតម្លៃបន្ថែមខ្ពស់ | | – ជំរុញនិងលើកកម្ពស់ការវិនិយោគលើរោងចក្រកែច្នៃរោមសត្វ ផលិតផលស្បែក និង ផលិតផលមានសក្តានុពលផ្សេងទៀត សម្រាប់បម្រើឱ្យឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូប និងទីផ្សារបរទេស ដូចជាទីផ្សារប្រទេសចិនជាដើម។ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | – រៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រទំនាក់ទំនងនិងទីផ្សារ ដើម្បីបន្តលើកកម្ពស់កេរ្តិ៍ឈ្មោះនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា តាមរយៈការផ្សព្វផ្សាយពីការវិវត្តវិជ្ជមាននៅក្នុងវិស័យនេះឱ្យបានទូលំទូលាយនៅលើប្រព័ន្ធផ្សព្វផ្សាយ ការបោះពុម្ពផ្សាយនិងការចេញសេចក្តីប្រកាសព័ត៌មាន និងក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិទៅកាន់វិនិយោគិនសក្តានុពល និងតួអង្គពាក់ព័ន្ធក្នុងវិស័យនេះ។ | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | – ជំរុញការតភ្ជាប់កាន់តែប្រសើររវាងរោងចក្រនាំចេញនិងរោងចក្រ សហគ្រាសម៉ៅការបន្តក្នុងវិស័យនេះ ដូចជាការវិនិយោគរួមគ្នា តាមរយៈយន្តការលើកទឹកចិត្តដែលមានស្រាប់និងថ្មី ដោយសហការយ៉ាងជិតស្និទ្ធជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) សមាគមស្បែកជើងកម្ពុជា(CFA) ម្ចាស់ម៉ាកផលិតផល ម្ចាស់រោងចក្រ និងតួអង្គពាក់ព័ន្ធ។ | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |

| | | | |
|---|---|---|---|
| | | - ពិនិត្យលទ្ធភាពរៀបចំយន្តការគាំទ្រផ្នែកហិរញ្ញប្បទាន បច្ចេកទេស និងធុរកិច្ច សម្រាប់រោងចក្រ សហគ្រាសកាត់ដេរខ្នាតតូចនិងមធ្យម តាមរយៈធនាគារអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព និងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលធុរកិច្ចថ្មីតេជោ ដើម្បីជួយគាំទ្រដល់ការរៀបចំផែនការ ការគ្រប់គ្រង ការពង្រីក ឬ/និង ការបើករោងចក្រ សហគ្រាសជាដើម។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន<br>- ធនាគារអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម<br>- មជ្ឈមណ្ឌលបណ្ដុះបណ្ដាលធុរកិច្ចថ្មីតេជោ |
| | | - ពិនិត្យលទ្ធភាពរៀបចំនិងដាក់ឱ្យអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រចីរភាពបរិស្ថាន ដើម្បីពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃ កាត់បន្ថយផលប៉ះពាល់ និងអាចសម្របខ្លួនទៅនឹងការវិវត្តនៃឧស្សាហកម្មនេះ។ | - ក្រសួងបរិស្ថាន<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - ពង្រឹងការផ្ដល់ការលើកទឹកចិត្តលើការវិនិយោគមូលធន ការផ្ទេរបច្ចេកវិទ្យា ឬ/និង ការប្រើប្រាស់ថាមពលកកើតឡើងវិញជាដើម ស្របតាមការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធ។ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | ២០២៥-២០២៧ | - បន្តលើកកម្ពស់កេរ្តិ៍ឈ្មោះនៃឧស្សាហកម្មនេះនៅកម្ពុជា ជាគោលដៅផលិតកម្ម ប្រកបដោយអនុលោមភាព ក្រមសីលធម៌ ចីរភាពបរិស្ថាន និងជាគោលដៅនៃការបញ្ជាទិញសម្រាប់ផលិតផលមានតម្លៃបន្ថែមខ្ពស់។ | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - ផ្ដល់យន្តការលើកទឹកចិត្តដែលមានស្រាប់និងថ្មី ដល់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យនេះ ឱ្យវិនិយោគលើទំនើបកម្មផលិតកម្មរបស់ខ្លួន ដើម្បីពង្រឹងគុណភាពផលិតផល បង្កើនផលិតភាព និងឈានទៅប្រែខ្លួនទៅជារោងចក្រនាំចេញជាដើម។ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |

| | | | |
|---|---|---|---|
| | | - លើកទឹកចិត្តឱ្យរោងចក្រ សហគ្រាសមានបំណងប្រែក្លាយខ្សែច្រវាក់ផលិតកម្មរបស់ខ្លួនទៅជាការផលិតនូវផលិតផលពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ និងផលិតផលមានលក្ខណៈពិសេស តាមលទ្ធភាពនិងតម្រូវការជាក់ស្តែង។ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - បន្តពង្រឹងវិធានការរយៈពេលខ្លីពាក់ព័ន្ធខាងលើ ដើម្បីលើកកម្ពស់ការវិនិយោគក្នុងស្រុក និងបរទេសដែលផលិតនូវផលិតផលមានបន្ថែមតម្លៃខ្ពស់។ | - ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន<br>- ដៃគូអភិវឌ្ឍពាក់ព័ន្ធ |
| ៤. ទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រសម្រាប់បម្រើឱ្យវិស័យនេះ | ២០២២-២០២៤ | - ជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសសម្រាប់រោងចក្រផលិតកំណាត់និងរោងចក្រផលិតផលវាយនភណ្ឌផ្សេងទៀត ដើម្បីបម្រើឱ្យវិស័យនេះនិងតម្រូវការទីផ្សារក្នុងតំបន់ ដោយមានយន្តការលើកទឹកចិត្តវិនិយោគពិសេស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការរៀបចំក្របខ័ណ្ឌនិយតកម្មច្បាស់លាស់ រួមមានការគ្រប់គ្រងប្រព័ន្ធប្រព្រឹត្តិកម្មសំណល់ឧស្សាហកម្មនិងគ្រោះថ្នាក់ ដើម្បីកិច្ចការពារបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព។ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - ជំរុញការបង្កើតរោងចក្រឧស្សាហកម្មបន្ទាប់បន្សំ ដើម្បីគាំទ្រដល់វិស័យនេះ តាមរយៈការផ្តល់ការលើកទឹកចិត្តដែលមានស្រាប់និងថ្មី ស្របតាមច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានិងបទប្បញ្ញត្តិពាក់ព័ន្ធ។ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |

| | | | |
|---|---|---|---|
| | | | - ក្រសួងបរិស្ថាន<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - លើកកម្ពស់ការប្រើប្រាស់ធនធានទៅក្នុងឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូប ស្របតាមមូលដ្ឋានសេដ្ឋកិច្ចចក្រា(Circular Economy) និងការកែច្នៃឡើងវិញលើកំណាត់ សម្ភារៈបន្ទាប់បន្សំ និងវត្ថុធាតុដើមផ្សេងទៀត ប្រកបដោយប្រសិទ្ធភាព និងចីរភាព។ | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - ធ្វើឱ្យប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្មនៅតាមច្រកពាណិជ្ជកម្មអន្តរជាតិ ជាអាទិ៍ផ្លូវអាកាស ផ្លូវគោក និងផ្លូវទឹក ព្រមទាំងកាត់បន្ថយចំណាយធុរកិច្ច ស្របតាមការអនុវត្តវិធានការកែទម្រង់ស៊ីជម្រៅពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។ | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |
| | | - លើកទឹកចិត្តនិងជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញតាមជម្រើសមួយ ដែលមានប្រសិទ្ធភាព និងបន្តពិនិត្យថ្លៃអគ្គិសនីបន្តទៀត តាមពេលវេលាសមស្រប។ | - ក្រសួងរ៉ែនិងថាមពល<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមការងារអន្តរស្ថាប័ន |

| | | | |
|---|---|---|---|
| | | – ផ្តល់ការគាំទ្រដល់ឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូបក្នុងការសម្របខ្លួន និងឆ្លើយតបទៅនឹងការប្រែប្រួលទីផ្សារ និងតម្រូវការបច្ចេកវិទ្យាក្នុងក្របខ័ណ្ឌបដិវត្តន៍ឧស្សាហកម្មទី៤ ដែលអាចប៉ះពាល់យ៉ាងខ្លាំងដល់ខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃនៅក្នុងវិស័យកាត់ដេរសកលនិងនៅកម្ពុជា។ | – ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>– ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>– ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>– ក្រុមការងារអន្តរស្ថាប័ន |
| | ២០២៥-២០២៧ | – បន្តផ្តល់ការគាំទ្រដល់ឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូប ក្នុងការសម្របខ្លួននិងឆ្លើយតបទៅនឹងការប្រែប្រួលទីផ្សារនិងតម្រូវការបច្ចេកវិទ្យាក្នុងក្របខ័ណ្ឌបដិវត្តន៍ឧស្សាហកម្មទី៤។ | – ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>– ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>– ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>– ក្រុមការងារអន្តរស្ថាប័ន |
| | | – បន្តពង្រឹងវិធានការរយៈពេលខ្លីខាងលើ ដើម្បីទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រសម្រាប់បម្រើឱ្យវិស័យនេះ។ | – ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>– ក្រុមការងារអន្តរស្ថាប័ន |
| ៥. ជំរុញការធ្វើពិពិធកម្មទីផ្សារសម្រាប់ការនាំចេញផលិតផលកាត់ដេរ ផលិតផលស្បែកជើង និងកាបូប | ២០២២-២០២៤ | – សិក្សាពីនិន្នាការតំបន់និងសកលលើតម្រូវការទីផ្សារនៃផលិតផលកាត់ដេរ ស្បែកជើង និងកាបូប ដែលមានមូលដ្ឋានផលិតកម្មនិងការបញ្ជាទិញនៅកម្ពុជា ព្រមទាំងសិក្សាលើសមត្ថភាពប្រកួតប្រជែងរបស់វិស័យនេះនៅកម្ពុជា ដើម្បីជាមូលដ្ឋានក្នុងការពិនិត្យលទ្ធភាពរៀបចំនិងស្នើសុំអាណត្តិធ្វើការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី(FTA)។ | – ក្រសួងពាណិជ្ជកម្ម<br>– ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>– ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>– ក្រុមការងារអន្តរស្ថាប័ន |
| | | – ត្រៀមលក្ខណសម្បត្តិចរចាជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីរក្សានូវប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP)។ | – ក្រសួងពាណិជ្ជកម្ម<br>– ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>– ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>– ក្រុមការងារអន្តរស្ថាប័ន |

| | | | |
|---|---|---|---|
| | | – ជំរុញការអនុវត្តវិធានការពាក់ព័ន្ធនឹងវិស័យនេះនៅក្នុង**យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០១៩-២០២៣** សម្រាប់គាំទ្រការធ្វើពិពិធកម្មទីផ្សារនាំចេញរបស់កម្ពុជា។ | – ក្រសួងពាណិជ្ជកម្ម<br>– ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>– ក្រុមការងារអន្តរស្ថាប័ន |
| | **២០២៥-២០២៧** | – ពិនិត្យលទ្ធភាពស្នើសុំចរចាជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីដាក់បញ្ចូលផលិតផលប្រភេទស្បែកជើងទៅក្នុងប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP) ដែលបច្ចុប្បន្នផ្តល់ជាចម្បងលើផលិតផលធ្វើដំណើរ។ | – ក្រសួងពាណិជ្ជកម្ម<br>– ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>– ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>– ក្រុមការងារអន្តរស្ថាប័ន |
| | | – បង្កើនលទ្ធភាពក្នុងការបន្តចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី(FTA) ដើម្បីជំរុញការធ្វើពិពិធកម្មទីផ្សារនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងកាបូបកម្ពុជា។ | – ក្រសួងពាណិជ្ជកម្ម<br>– ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>– ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>– ក្រុមការងារអន្តរស្ថាប័ន |